# អង្គការ អភិវឌ្ឍន៍ និង ការពារបរិស្ថាន

Environmental Protection and Development Organization

(EPDO)

# របាយការណ៍

# វឌ្ឍនៈភាពគម្រោងប្រចាំឆ្នាំ



## ខែកុម្ភៈ ឆ្នាំ ២០២០

# មាតិកា


សាររពីអ្នកគ្រប់គ្រង (នាយកប្រតិបត្តិ) 4
អារម្មណ៍កថា 5
ប្រវត្តិអង្គការ អភិវឌ្ឍន៍ និង ការពារបរិស្ថាន 5
ទស្សនះវិស័យ 6
បេសកកម្ម 6
គុណតំលៃ 6
ការចូលរួម 6
តម្លាភាព 6
ផលប៉ះពាល់ 6
បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង 6
គោលដៅ 7
គោលបំណងសំខាន់ៗរបស់EPDO 7
យុទ្ធសាស្រ្ត 7
ក្រុមគោលដៅ 7
បុគ្គលិក 8
១ គម្រោង លើកកម្ពស់ផលិតភាពកសិកម្មដែលធន់នឹងអាកាសធាតុ 9
១.១ សេចក្តីផ្តើម 9
១.២ តំបន់គោលដៅ និងប្រជាពលរដ្ឋ 10
១.៣ លទ្ធផលសំរេចបានរបស់គំរោង 10
២. គម្រោងបង្កើតបណ្តុំអាជីវកម្មវារីវប្បកម្ម ខេត្តពោធិ៍សាត់ 17
២.១ សេចក្តីផ្តើម: 17
២.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង 17
២.៣ លទ្ធផលសម្រេចបាន: 17
២.៤ លទ្ធផលរយៈពេលខ្លី: 20
២.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង 20
២.៦ .និរន្តរភាពនៃគម្រោង 21
៣. គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ខេត្តពោធិ៍សាត់ 22
៣.១ សេចក្តីផ្តើម: 22
៣.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង 22

៣.៣  លទ្ធផលសម្រេចបានៈ ......22
៣.៤ លទ្ធផលរយៈពេលខ្លីៈ ......24
៣.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង ......25
៣.៦.និរន្តរភាពនៃគម្រោង ......26
៤. គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ខេត្តបាត់ដំបង ......27
៤.១ សេចក្តីផ្តើម ......27
៤.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង ......27
៤.៣ លទ្ធផលសម្រេចបានៈ ......28
៤.៤. លទ្ធផលរយៈពេលខ្លី ......29
៤.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង ......30
៤.៦. និរន្តរភាពនៃគម្រោង ......30
៥. គម្រោងបង្កើតបណ្តុំអាជីវកម្មបន្លែ  ខេត្តបាត់ដំបង ......31
៥.១ សេចក្តីផ្តើមៈ ......31
៥.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង ......31
៥.៣  លទ្ធផលសម្រេចបានៈ ......32
៥.៤. លទ្ធផលរយៈពេលខ្លី ......34
៥.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង ......34
៥.៦. និរន្តរភាពនៃគម្រោង ......35
កិច្ចសហការ ......35
មេរៀនបទពិសោធន៍......35
ការសន្និដ្ឋាន ......36
ករណីសិក្សាទី១៖ ភាពជោគជ័យនៃការដាំបន្លែតាមបច្ចេកទេសរបស់គ្រួសារ ជុំ សុភា......37
ករណីសិក្សាទី២៖ ការលើកកម្ពស់ប្រាក់ចំណូលគ្រួសារពិកាលោក ម៉ន សុខឡើន ......39
ករណីសិក្សាទី៣៖ បច្ចេកទេសថ្មីនៃការចិញ្ចឹមកង្កែបដែលធននឹងការប្រែប្រួលអាកាសធាតុ......41
ករណីសិក្សាទី៤៖ចំណាប់អារម្មណ៍របស់បណ្តុំអាជីវកម្មបន្លែ ចំពោះការធ្វើកសិកម្មតាមកិច្ចសន្យា ......43
ករណីសិក្សាទី៥៖ការអនុវត្តបច្ចេកទេសចិញ្ចឹមមាន់គំរូរបស់លោក សឿង ឡាត់......46

# សារពីអ្នកគ្រប់គ្រង (នាយកប្រតិបត្តិ)



របាយការណ៍នេះ បានបង្កើតឡើង និងបង្ហាញពីការអនុវត្តគម្រោងចាប់ពីឆ្នាំ ២០២០ ដោយក្រុមអ្នកគ្រប់គ្រង និងបុគ្គលិកបច្ចេកទេសរបស់ EPDO ដែលមានទីតាំងនៅភូមិក្បាលហុង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ពោធិ៍សាត់។ រឿងរ៉ាវដែលបានសរសេរនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២០ ដែលបានបន្លិចផលប៉ះពាល់នៃកម្មវិធី អង្គការ EPDO ក្នុងការធ្វើការជាមួយប្រជាជននៅតាមជនបទដែលយើងបម្រើ។ នៅក្នុងឯកសារកម្មវិធីអង្គការ EPDO ២០២០ ការប្រែប្រួលអាកាសធាតុគឺបញ្ជ្រាបល្អិតល្អន់ចូលទៅក្នុងកម្មវិធីរួមមួយ និងគោលបំណងនៃគម្រោងនិមួយៗផងដែរ។ ផ្តល់សិទ្ធិអំណាចដល់ប្រជាជននៅតាមជនបទដែលរងផលប៉ះពាល់បំផុត ដើម្បីក្លាយជាអ្នកយល់ដឹងកាន់តែខ្លាំងឡើង អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងដើម្បីរកវិធីក្នុងការកាត់បន្ថយហានិភ័យទាំងនោះ។ គំនិតច្នៃប្រឌិតថ្មីមួយទៀតគឺការផ្តោតអារម្មណ៍ ស្តីពីការលើកកម្ពស់ការ ផ្តល់សិទ្ធិអំណាចដល់មេដឹកនាំសំខាន់ៗក្នុងតំបន់រួមមាន គណៈកម្មាធិការអភិវឌ្ឍន៍ (VDCs) និងសហគមន៍កសិកម្ម (ACs) ក្រុមបណ្តុំអាជីវកម្មកសិកម្ម (ស្រូវ បន្លែ សត្វ វារីវប្បកម្ម) ផ្តោតអារម្មណ៍ជាច្រើននៅលើកម្មវិធីអង្គការ EPDO ពីព្រោះយើងមានជំនឿថា មេដឹកនាំក្នុងតំបន់ដែលបានផ្តល់អំណាច នឹងមានគណនេយ្យភាព និងការអភិវឌ្ឍ ប្រកបដោយនិរន្តរភាព នៃកម្មវិធីនេះ។

ការពង្រឹងសមត្ថភាពដល់ VDCs ភ្នាក់ងារសុខភាពសត្វភូមិ(VAHWs) សហគមន៍កសិកម្ម(ACs)អ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៍ បានកើនឡើងបន្តិចម្តងៗ តាមរយៈការអន្តរាគមន៍របស់យើង។ អង្គការ EPDO បានបន្តផ្តល់ការយកចិត្តទុកដាក់ដល់គ្រួសារដែលងាយរងគ្រោះជាក់លាក់បំផុតនៅក្នុងសហគមន៍គោលដៅរួមទាំងស្ត្រីជាមេគ្រួសារ និងប្រជាជនទូទៅនៅក្នុងសហគមន៍ដែលយើងកំពុងបម្រើផងដែរ។

យើងបានផ្លាស់ប្តូរវិធីសាស្ត្ររបស់យើងធ្វើការជាមួយនឹងអ្នកដែលនៅក្នុងភាពងាយរងគ្រោះបំផុត ពីការគាំទ្រចំពោះបុគ្គល ឆ្ពោះទៅរកក្រុមពួកគេនៅក្នុងគោលបំណងដើម្បីគ្របដណ្តប់គ្រួសារជាដៃគូបន្ថែមទៀត។ ជាលទ្ធផលយើងអាចគាំទ្រ បានល្អប្រសើរជាងមុន ដោយភ្ជាប់រវាង VDCs និងអ្នកដឹកនាំសំខាន់ៗនៅក្នុងសហគមន៍ ឲ្យពួកគេធ្វើការជាមួយគ្នា ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអ្នកដែលងាយរងគ្រោះ តាមរយៈការពង្រឹងសមត្ថភាព និងការគាំទ្រនានាបានធ្វើឲ្យពួកគេ មានការផ្លាស់ប្រែទាំងចំណេះដឹង ជំនាញ អាកប្បកិរិយា និងជីវភាពរបស់ ប្រសើរជាងមុន។

ក្នុងនាមអង្គការEPDO និងក្នុងនាមខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណដល់ រាជរដ្ឋាភិបាលកម្ពុជា ដៃគូផ្តល់មូលនិធិរបស់យើងដែលបានគាំទ្រ បានធ្វើឱ្យអង្គការ EPDO អាចបម្រើដល់សហគមន៍គោលដៅទទួលបានលទ្ធផលគួរជាទីមោទនៈរហូតមកដល់ពេលនេះ។ វាជាការសំខាន់ដើម្បីចងចាំថា សមិទ្ធផលទាំងនេះ មិនអាចធ្វើបានទេប្រសិនបើគ្មានការគាំទ្រ ពីសំណាក់ភ្នាក់ងារផ្តល់ជំនួយ អង្គការជាតិ អន្តរជាតិ រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ជាពិសេសដល់ដៃគូអភិវឌ្ឍន៍របស់យើងទាំងអស់ រួមទាំងសហគមន៍គោលដៅក្នុងតំបន់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការសហការ និងការគាំទ្រល្អ។

ខ្ញុំសូមអរគុណយ៉ាងខ្លាំងដល់មិត្តរួមការងាររបស់ខ្ញុំទាំងអស់សម្រាប់អង្គការ EPDO ដែលមានស្មារតីធ្វើការបម្រើផលប្រយោជន៍ដល់សហគមន៍ដៃគូរបស់យើង ដោយសេចក្តីស្រឡាញ់ ការគោរពវិជ្ជាជីវៈការងារ មានតម្លាភាព គណនេយ្យភាព និងការងារជាក្រុម ដែលបានធ្វើឲ្យមានការកើតឡើងនូវសមិទ្ធផលទាំងអស់របស់ឆ្នាំ២០២០នេះ ខ្ញុំសូមបញ្ចប់សាររបស់ខ្ញុំតែត្រឹមនេះ។

សង្ឃឹមថា EPDO នឹងទទួលបានការគាំទ្រជាបន្ត ពីអ្នកដែលមានការពាក់ព័ន្ធទាំងអស់ ដែលមិនអាចកាត់ថ្លៃបាន ដើម្បីរួមគ្នាកសាង និងការពារសមិទ្ធផលបច្ចុប្បន្ន និងអនាគត និងដើម្បីបង្កើតវិធីសាស្រ្ត ប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រសម្រាប់ប្រជាជនកម្ពុជារាប់ពាន់នាក់ជួបការលំបាករួមទាំងស្ត្រី និងកុមារដែលរស់នៅក្នុងតំបន់ជនបទដាច់ស្រយាលផងដែរ។

## អារម្ភកថា

សមិទ្ធផលទាំងនេះនឹងមិនអាចទៅរួចទេ បើគ្មានការប្តេជ្ញាចិត្តដ៏អស្ចារ្យរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង សមាជិកបុគ្គលិក និងការគាំទ្រប្រភពថវិកាពីភ្នាក់ងារផ្តល់ជំនួយនានា។

សម្រាប់ឆ្នាំ ២០២០ សមិទ្ធផលទាំងឡាយត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងធំធេងពីដៃគូផ្តល់ជំនួយដូចជា៖ Australian Catholic Relief / Caritas Australia (ACR/ CA) កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធនទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) តាមរយៈមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។

យើងសូមថ្លែងអំណរគុណចំពោះបុគ្គលិកបច្ចេកទេសទាំងអស់ សម្រាប់ការប្រមូលផ្តុំពត៌មានពីវិស័យនេះ ហើយដែលបានដើរតួយ៉ាងសំខាន់នៅក្នុងការងារដ៏លំបាកបំផុតរបស់ពួកគេ និងដៃគូផ្តល់ជំនួយដែលតែងតែគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ EPDO ជាពិសេសដល់អ្នកទទួលផលដែលបានចូលរួមក្នុងកម្មវិធី ដើម្បីកែលំអជីវភាពរស់នៅ និងបច្ចេកវិជ្ជាថ្មី។ សម្លេងរបស់ពួកគេត្រូវបានឮ អ្នកក្រក៏មានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការចូលរួមធ្វើផែនការ ការចូលរួមអនុវត្តគម្រោង និងការចូលរួមតាមដានត្រួតពិនិត្យ និងកែលម្អរកម្មវិធីទាំងអស់គ្នា ហើយនេះគឺជាបេសកកម្ម និងគោលដៅរបស់យើង។

ចុងក្រោយយើងសូមថ្លែងអំណរគុណចំពោះ អង្គការដៃគូ ម្ចាស់ជំនួយ ស្ថាប័នរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងប្រជាពលរដ្ឋ សម្រាប់កិច្ចសហការល្អរបស់ពួកគេ និងជោគជ័យដ៏អស្ចារ្យដែលនឹងបន្ត។

## ប្រវត្តិអង្គការ អភិវឌ្ឍន៍ និង ការពារបរិស្ថាន

អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន EPDOគឺជាអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមិនពាក់ព័ន្ធនឹងនយោបាយ ឬគណបក្សណាមួយឡើយ។ អង្គការ EPDO បានបង្កើតឡើងនៅដើមឆ្នាំ១៩៩៨ ដើម្បីធ្វើការទៅលើការការពារបរិស្ថាន ការអភិរក្សអភិវឌ្ឍន៏ធនធានធម្មជាតិ លើកកំពស់នូវជីវភាពប្រចាំថ្ងៃ ការឆ្លើយតបទៅនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ។ EPDO បានចុះឈ្មោះ នៅក្រសួងមហាផ្ទៃតាមលិខិតលេខ ៤៩៤សជណ ចុះថ្ងៃ ទី៦ ខែកក្កដាឆ្នាំ ១៩៩៨។

អង្គការEPDOមានបទពិសោធន៍២២ឆ្នាំក្នុងប្រទេសកម្ពុជាក្នុងការអនុវត្តកម្មវិធី គ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន បន្សុំាការប្រែប្រួលអាកាសធាតុ លើកកំពស់នូវជីវរស់នៅរបស់

ប្រជាពលរដ្ឋតាមរយៈការបញ្ចូលបច្ចេកវិជ្ជាវិស័យកសិកម្ម (ដំណាំស្រូវ ចិញ្ចឹមសត្វ វ៉ារីវប្បកម្ម និងដាំបន្លែ) ទឹកស្អាតអនាម័យ ការអប់រំសិទ្ធិកុមារ និងអភិបាលកិច្ចល្អ។

## ទស្សនៈវិស័យ

សង្គមមួយដែលពលរដ្ឋកម្ពុជាគ្រប់រូបរស់នៅដោយមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខុមាលភាពល្អប្រសើរ។

## បេសកកម្ម

រួមចំណែកដល់ការអភិវឌ្ឍសហគមន៍ និងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា ដែលមានការរស់នៅក្នុងបរិយាកាសល្អ តាមរយៈការកសាងសមត្ថភាព និងពង្រឹងភាពអង់អាចពួកគេ ដើម្បីធ្វើឲ្យប្រសើរឡើងនូវជំនាញបច្ចេកទេស និងវិជ្ជាជីវៈដែលបង្កើតឲ្យមានកំណើនប្រាក់ចំណូល។

## គុណតំលៃ

ការចូលរួម តម្លាភាព ផលប៉ះពាល់ បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង។

### ការចូលរួម

គោលការណ៍ការងាររបស់ EPDO ធានាឲ្យមានការចូលរួមពីអ្នកភូមិ និងអាជ្ញាធរមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍ និងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាព និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌។ បុគ្គលិក EPDO ត្រូវពិគ្រោះជាមួយអ្នកពាក់ព័ន្ធជាច្រើន ក្នុងការរៀបចំ និង ការអនុវត្តកម្មវិធី ដើម្បីជួយធានាថា តម្រូវការរបស់ពួកគេត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធី។

### តម្លាភាព

បុគ្គលិក EPDO ទទួលស្គាល់តម្លៃនៃតម្លាភាពដែលជាប្រតិបត្តិការតាមវិធីសាស្រ្តមួយដែលអនុញ្ញាតឱ្យអ្នកដទៃពិនិត្យមើលថាតើសកម្មភាពអ្វីខ្លះត្រូវបានអនុវត្ត។ EPDOជឿជាក់ថាតម្លាភាពគឺមានសារៈសំខាន់ណាស់ សម្រាប់ការផ្តល់កម្មវិធីដែលទទួលបានជោគជ័យ ទាំងការគ្រប់គ្រង និងការអនុវត្ត។

### ផលប៉ះពាល់

EPDO ឲ្យតំលៃលើគណនេយ្យភាព និងការតាមដានការងាររបស់ខ្លួនដើម្បីធានានូវភាពប្រសើរឡើងវិជ្ជមានក្នុងជីវភាពរស់នៅ និងសហគមន៍ដែលយើងធ្វើការជាមួយ។

### បទពិសោធន៍ក្នុងមូលដ្ឋាន និងចំណេះដឹង

បុគ្គលិករបស់ EPDO ត្រូវបានចុះមូលដ្ឋានជាមួយសហគមន៍ ចែករំលែក និងរៀនសូត្រក្នុងចំណោមអ្នកពាក់ព័ន្ធ ដែលពួកគេធ្វើការជាមួយ ហើយនឹងបង្កើនភាពជឿជាក់ គោរពគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងបង្កើនចំណេះដឹង តាមរយៈការអនុវត្តសកម្មភាពនៅមូលដ្ឋាន។

# គោលដៅ

ដើម្បីលើកកំពស់សិទ្ធអំណាចដល់សហគមន៍ ក្នុងការគ្រប់គ្រងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន និង លើកកម្ពស់គំរូនៃវិស័យកសិកម្ម និងមិនមែនកសិកម្ម ដែលធន់ទ្រាំនឹងអាកាសធាតុ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ តាមរយៈការអនុវត្តចម្រុះកម្មសេដ្ឋកិច្ច និងការគ្រប់គ្រងធនធានធម្មជាតិ។

# គោលបំណងសំខាន់ៗរបស់EPDO

- បង្កើនសមត្ថភាពសមត្ថភាពរបស់អ្នកដឹកនាំអភិវឌ្ឍ ក្នុងការសំរបសំរួលគំនិតផ្តួចផ្តើមរបស់សហគមន៍ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានដោយផ្អែកលើសិទ្ធិជាមូលដ្ឋាន។
- ពង្រឹកភាពជាដៃគូនៅថ្នាក់ក្រោមជាតិ និងសហគមន៍ ដោយមានកិច្ចសហប្រតិបត្តិការពេញលេញពីស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីធានាថាការអភិវឌ្ឍន៍សហគមន៍ដោយផ្អែកលើធនធានជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។
- កសាងសមត្ថភាពដល់គ្រួសារក្រីក្រ និងគ្រួសារដែលងាយរងគ្រោះអំពីជំនាញ ចំណេះដឹងបច្ចេកទេសក្នុងការប្រកបមុខរបរ និងការធ្វើជំនួញ ដើម្បីធានាថា ការកែលំអជីវភាពរស់នៅ និងកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព។
- កែលម្អបច្ចេកទេស និងបច្ចេកវិជ្ជានៃវិស័យកសិកម្ម ធន់ទ្រាំនឹងអាកាសធាតុ ច្នៃប្រឌិតសម្រាប់ផលិតភាពការធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្មដើម្បីដោះស្រាយបញ្ហាប្រឈមទីផ្សារ និងកសាងលក្ខខណ្ឌទីផ្សារអំណោយផលក្នុងភាពជាដៃគូពាណិជ្ជកម្ម។

# យុទ្ធសាស្រ្ត

- ពង្រឹងកម្មវិធីដែលរៀបចំឡើងដើម្បីលើកកម្ពស់សន្តិសុខស្បៀងសម្រាប់ទាំងអស់គ្នា
- ស្វែងរកការគាំទ្រដើម្បីឲ្យមានការទទួលស្គាល់សិទ្ធិរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ
- បង្កើនសមត្ថភាពសហគមន៍ និង រដ្ឋបាលមូលដ្ឋានក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និង គ្រោះមហន្តរាយ តាមរយៈការពង្រឹងភាពជាដៃគូ និងដំណើរការសង្គ្រោះបន្ទាន់។
- គាំទ្រ និងអប់រំ សកម្មភាពទឹកស្អាត និងអនាម័យសម្រាប់ទាំងអស់គ្នា។
- ពង្រឹងប្រព័ន្ធផ្ទៃក្នុង ដំណើរការ និងការរៀបចំកម្មវិធី។

# ក្រុមគោលដៅ

ដោយផ្អែកលើបេសកកម្មរបស់ខ្លួន EPDO នឹងផ្តល់នូវសកម្មភាពអាទិភាពដល់ប្រជាជនកម្ពុជាដែលរស់នៅក្នុងតំបន់គោលដៅរបស់ខ្លួន ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ឱកាសជីវភាពដែលមាននិរន្តរភាពសម្រាប់ជនក្រីក្រ និងប្រជាពលរដ្ឋទូទៅរួមមាន សមាជិកសហគមន៍ ស្រ្តី យុវជន កុមារ ចាស់ជរា ជនពិការ កុមារកំព្រា និងងាយរងគ្រោះ ក្រុមជួយខ្លួនឯង ភ្នាក់ងារសុខភាពពេទ្យសត្វភូមិ សហគមន៍កសិកម្ម អាជ្ញាធរមូលដ្ឋានភូមិ ឃុំ និងស្រុក ។ រចនាសម្ព័ននៃកម្មវិធីដែលអនុវត្តដោយ EPDO គឺថាបន្ទាប់ពីបញ្ចប់កម្មវិធីនីមួយៗមនុស្សដែលមានគោលដៅអាចរស់នៅប្រកបដោយចីរភាពដោយគ្មានការគាំទ្រពី EPDO ។

ផ្តោតលើវិស័យកម្មវិធី / គម្រោង:

- វិស័យកសិកម្មរួមមាន៖ ដំណាំស្រូវ បន្លែ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ
- ទឹកស្អាត និងអនាម័យ
- គ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

# បុគ្គលិក

បច្ចុប្បន្ន EPDO មានកម្លាំងបុគ្គលិកចំនួន ១៦នាក់ (ស្រី៨នាក់):

| | | |
|---|---|---|
| - នាយកប្រតិបត្តិ | ១នាក់ | |
| - ប្រធានកម្មវិធី | ១នាក់ | |
| - អ្នកសម្របសម្រួលគម្រោង | ២នាក់ | ស្រី១នាក់ |
| - មន្ត្រីរដ្ឋបាលហិរញ្ញវត្ថុ | ២នាក់ | ស្រី១នាក់ |
| - មន្ត្រីបច្ចេកទេស | ៧នាក់ | ស្រី៤នាក់ |
| - មន្ត្រីគម្រោង | ២នាក់ | ស្រី៣នាក់ |
| - អ្នកសំអាត | ១នាក់ | ស្រី១នាក់ |

# ១ គម្រោង លើកកម្ពស់ផលិតភាពកសិកម្មដែលធន់នឹងអាកាសធាតុ

**Promote Climate-resilient Agricultural Productivity (PCAP)**

**គាំទ្រថវិកាដោយ** Australian AID ACR CARITAS AUSTRALIA

## ១.១ សេចក្តីផ្តើម

លើកកម្ពស់ផលិតភាពកសិកម្មដែលធន់នឹងអាកាសធាតុ បានអនុវត្តនៅក្នុងភូមិគោលដៅចំនួន៦ ភូមិកោះក្រសាំង ឃុំអន្លង់វិល ភូមិសន្លុង ឈើទាល ឃុំស្វាយលួង ភូមិត្រពាំងថ្ម ឃុំស្យា និងភូមិព្រែកត្របែក ភូមិផ្លូវលួង ឃុំកញ្ជរ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ តាមការចុះសម្របសម្រួល ការតាមដានត្រួតពិនិត្យ និងការសង្កេតផ្ទាល់ បានបង្ហាញថា ភូមិគោលដៅចំនួន៦ ទាំងអ្នកដឹកនាំ និងសមាជិកសហគមន៏បានធ្វើការផ្លាស់ប្តូរមួយចំនួនដូចខាងក្រោមៈ

អ្នកដឹកនាំសហគមន៏ មានសាមគ្គីភាព បង្កើតគំនិតផ្តួចផ្តើម ចូលរួមកៀគរធនធាន ក្នុងការអភិវឌ្ឍន៏សហគមន៏មានទំនាក់ទំនងល្អទាំងខាងក្នុង និងក្រៅសហគមន៏ មានការទទួលខុសត្រូវជាក់លាក់ មានការផ្លាស់ប្តូរការគិត ដោយផ្តោតទៅលើការអភិវឌ្ឍន៏ដែលផ្អែកលើធនធានជាមូលដ្ឋាន ជាជាងការផ្តោតទៅលើបញ្ហា ឬការរង់ចាំទទួលតែជំនួយ។

សមាជិកសហគមន៏ មានការចូលរួមក្នុងដំណើរការអភិវឌ្ឍសហគមន៏ ចាប់តាំងពីពេលចាប់ផ្តើមគម្រោង ការតាមដានត្រួតពិនិត្យ និងឆ្លុះបញ្ចាំងឡើងវិញ។ តាមរយៈការឆ្លុះបញ្ចាំងនេះសមាជិកសហគមន៏ ម្នាក់ៗបានចូលរួមត្រួតពិនិត្យនូវលទ្ធផលដែលបានអនុវត្តកន្លងមក ចំណុចដែលធ្វើបានល្អ ចំណុចដែលបានអនុវត្តខ្លះ និងចំណុចដែលមិនទាន់បានអនុវត្ត ព្រមទាំងចូលរួមធ្វើផែនការសម្រាប់រយៈពេល៣ខែបន្ត។ ក្នុងដំណើការនេះសមាជិកសហគមន៏បានដឹងអំពីពេលវេលា តួនាទី ការទទួលខុសត្រូវក្នុងការចូលរួមកែលំអរស្ថានភាពធ្វើឲ្យប្រសើរឡើងដើម្បីសម្រេចការរំពឹងទុករបស់ពួកគាត់។

EPDO បានយកចិត្តទុកដាក់ទៅលើការលើកកំពស់ស្រ្តីឲ្យចូលរួមរាល់សកម្មភាពរបស់គម្រោង ជាពិសេស ការជ្រើសអ្នកដឹកនាំ អ្នកសម្របសម្រួលតែងតែផ្តល់ឱកាសឲ្យស្រ្តីឈរឈ្មោះធ្វើជាអ្នកដឹកនាំក្រុម/សហគមន៍ និងពង្រឹងបន្ថែមអំពីតួនាទី ការទទួលខុសត្រូវ ដើម្បីឲ្យពួកគាត់មានលទ្ធភាពធ្វើការសម្របសម្រួលក្នុងការអប់រំផ្សព្វផ្សាយអំពីអនាម័យសុខភាព ការត្រៀមបង្ការគ្រោះមហន្តរាយ ធ្វើបទបង្ហាញសម្រាប់ភ្ញៀវ ទស្សកិច្ចសិក្សា/សិក្ខាសាលាដៃគូរ សម្របសម្រួលកិច្ចប្រជុំក្រុម សម្របសម្រួលដំណើរការ ចុះបញ្ជីរ និងគ្រប់គ្រងបញ្ជីរក្រុមសន្សំ ការចលនាកៀគរការចូលរួម របស់សមាជិកសហគមន៍ ដំណើរការនេះបានលើកទឹកចិត្តសមាជិកសហគមន៍ ជាពិសេសស្រ្តីចូលរួមយ៉ាងសកម្ម និងដោយសេរីនៅក្នុងដំណើរការរៀបចំផែនការ ការអនុវត្ត និងការតាមដាន។

គម្រោងបានគិត និងបញ្ចូលគំនិតយោបល់ ការបញ្ចេញមតិរបស់សមាជិកសហគមន៍រួមមានក្រុម បុរស ស្រ្តីកុមារ ជនពិការ ចាស់ជរា គណៈកម្មការផ្សេងៗ និងអាជ្ញាធរ តាមរយៈការប្រមូលពត៌មាន ការកសាងផែនការបញ្ចូលក្នុងផែនការវិនិយោគឃុំ ការសម្រេចចិត្ត ការរៀបចំគម្រោង សរសេរសំណើរ របាយការណ៌ តាមដានត្រួតពិនិត្យគម្រោងរៀងរាល់ត្រីមាស។ ការឆ្លុះបញ្ចាំងគម្រោង៦ខែម្តង អ្នកសម្របសម្រួលបានបែងចែកក្រុមពិភាក្សា ដូចជា ក្រុម

បុរស ស្ត្រី កុមារ ចាស់ព្រឹទ្ធាចារ្យ ពួកគាត់សុទ្ធតែបានបញ្ចេញនូវគំនិតយោបល់ល្អៗ ហើយគំនិតទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងលទ្ធផលនៃការឆ្លុះបញ្ចាំង និងការរៀបចំផែនការបន្ត។

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ អ្វីដែលEPDO បានយកចិត្តទុកដាក់ គឺការពង្រឹងសមត្ថភាពដល់គណៈកម្មការ ដែលមានស្រាប់នៅក្នុងភូមិគោលដៅទៅតាមលទ្ធផលនៃការប៉ាន់ប្រមាណសមត្ថភាពរបស់អ្នកដឹកនាំសហគមន៍ មានដូចជាភាពជាអ្នកដឹកនាំ ការងារជាក្រុម ការប្រាស្រ័យទាក់ទង វិធីសាស្ត្រដោះស្រាយទំនាស់។ល។ ជាពិសេសរំលឹកអំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការសម្របសម្រួល ចាត់ចែង ដឹកនាំ ការកៀគធនធានក្នុងការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ធ្វើឲ្យប្រជាជនមានទំនុកចិត្ត មានសាមគ្គីភាព និងរួមគ្នាលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសហគមន៍ឲ្យបានកាន់តែប្រសើរឡើង។

## ១.២ តំបន់គោលដៅ និងប្រជាពលរដ្ឋ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនប្រជាពលរដ្ឋក្នុងភូមិ | | |
|---|---|---|---|---|---|---|
| | | | | គ្រួសារ | មនុស្សសរុប | ស្រី |
| ពោធិ៍សាត់ | កណ្ដៀង | ឃុំស្យា | ត្រពាំងថ្ម | ១៧៩ | ៨០៩ | ៤៤៩ |
| | | ឃុំអន្លង់វិល | កោះក្រសាំង | ៨៨ | ៣៨៧ | ២០៤ |
| | | ឃុំស្វាយលួង | ឈើទាល | ១៦៨ | ៦០៨ | ៣៤១ |
| | | | សន្លុង | ៨៥ | ៣២៦ | ១៦៥ |
| | | ឃុំកញ្ជរ | ព្រែកត្របែក | ៣៨៣ | ១៦០៦ | ៨១៨ |
| | | | ផ្លូវលួង | ២៣០ | ១១៣៨ | ៥៥៤ |
| | | ៤ ឃុំ | ៦ ភូមិ | ១១៣៣ | ៤៨៧៤ | ២៥៣១ |

**គោលបំណងទី ១៖** គិតត្រឹមខែកញ្ញាឆ្នាំ ២០២៤ កំណើនសេដ្ឋកិច្ចប្រសើរសម្រាប់សមាជិកសហគមន៍ចំនួន ៣៣៣ នាក់ប្រជាជន៣១៦២ នាក់ស្រី១៤១០នាក់ ក្នុងក្រុមផលិតចំនួន៣៩ តាមរយៈអាជីវកម្មកសិកម្មដែលរកប្រាក់ចំណេញ និងមានភាពធន់នៅក្នុងភូមិចំនួន៦ ឃុំចំនួន៤ ក្នុងស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។

## ១.៣ លទ្ធផលសំរេចបានរបស់គំរោង



**ក្រុមចិញ្ចឹមមាន់៖**គម្រោងបានគាំទ្រក្រុមកសិករចិញ្ចឹមមាន់ ការវិនិយោគសម្ភារៈមានសំណាញ់ ពោងទឹក សម្រាប់ធ្វើទ្រុងមាន់តាមបច្ចេកទេសដោយចែកជា៤ប្លុក ចំនួន៧២គ្រួសារ នៅភូមិកោះក្រសាំង៧គ្រួសារព្រែកត្របែក១៤គ្រួសារ ឈើទាល១២គ្រួសារ សន្លុង១៤គ្រួសារ ផ្លូវលួង១៣គ្រួសារ និងភូមិត្រពាំងថ្ម១២គ្រួសារ បន្ទាប់ពីការការចងក្រងក្រុម EPDOបានគាំទ្របច្ចេកទេសចិញ្ចឹមមាន់តាមរយៈវគ្គបណ្ដុះបណ្ដាល ទស្សនកិច្ចសិក្សាក្រៅគម្រោង ក្នុងគម្រោង ដូចជាការសាងសង់ទ្រុងមេពងខ័ណ្ឌជា៤ប្លុក ទ្រុងមានសាច់១ប្លុក ទ្រុងកូនមាន់ទើបញាស់ ការធ្វើចំណី ការធ្វើអនាម័យ ការថែទាំ និងវិធានការការពារជម្ងឺសត្វ។ល។ ព្រមទាំងវិនិយោគទូរភ្ញាស់ចំនួន៣គ្រឿង ដើម្បីភ្ញាស់កូនមាន់ចែកជូនកសិករចិញ្ចឹមមាន់សាច់ទាំង៦ភូមិ។ តាមរយៈនៃការចុះតាមដាន និងបង្ហឹកបានបង្ហាញថា ក្នុងចំណោមកសិករ៧២គ្រួសារ

មាន៥២គ្រួសារស្មើនឹង៧២%បានផ្លាស់ប្តូរពីការចិញ្ចឹមតាមយថាផល មកចិញ្ចឹមមាន់តាមបច្ចេកទេស ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និង២៨%ទៀតនៅបន្តអនុវត្តបច្ចេកទេសខ្លះ និងយថាផលខ្លះ។ បច្ចុប្បន្នគ្រួសារដែលចិញ្ចឹមមាន់តាមបច្ចេកទេសបានកាត់បន្ថយនូវអត្រាស្លាប់ និងជម្ងឺមាន់ និងមានការកើនឡើងនូវប្រាក់ចំណូល ក្នុងមួយគ្រួសារជាមធ្យមពី៩០០,០០០៛ ទៅ១,៥០០,០០០៛ ក្នុងរយៈពេល៤ខែនៃវដ្តចិញ្ចឹមមាន់។ តាមសំដី លោកស្រ៊ុន សុខជា នៅភូមិឈើទាល ឃុំស្វាយលួង លោកបានរៀបរាប់ អំពីការចិញ្ចឹមមាន់តាមបច្ចេកទេសមានការចែកប្លុកមាន់មេពង មាន់សាច់ ដោយមានទ្រុងសុវត្ថិភាព និងទ្រុងកូនមានដាច់ដោយឡែក ព្រមទាំងធ្វើវ៉ាក់សាំងតាមបច្ចេកទេស និងផ្សំចំណីធម្មជាតិតាមបច្ចេកទេស លទ្ធផលនៃការចិញ្ចឹមមាន់ទទួលបានប្រាក់ចំណូលសរុបចំនួន២,៨៧០,០០០៛ ប្រាក់



ចំណូលទាំងអស់នេះបានមកពីការលក់មាន់សាច់បាន២លើកបាន១,៨០០,០០០៛ ចំណូលពីការលក់កូនមាន់បានចំនួន៥២០,០០០៛ ចំណូលពីការលក់ពងមាន់ ៥៥០,០០០៛ បច្ចុប្បន្នគាត់កំពុងបន្តការចិញ្ចឹមមាន់ មានមេមាន់ពងចំនួន២០ក្បាល បាមាន់៤ក្បាល មាន់ជំទង់ចំនួន១០០ក្បាល កូនមាន់ចំនួន១២០ក្បាល។ គ្រប់មាន់ទាំងអស់គាត់បានធ្វើវ៉ាក់សាំងរួចរាល់ហើយម្យ៉ាងវិញទៀតគឺមាន់របស់គាត់កំពង់ពង និងក្រាបជាបណ្តើរៗចំនួន១០ក្បាល។ ប្រាក់ចំណូលនេះពួកគាត់ប្រើប្រាស់ទៅលើការទិញសម្ភារៈ សម្លៀកបំពាក់សិក្សាកូន ទិញស្បៀងអាហារ សម្រាប់ពង្រីកមុខរបរ និងបំពេញតម្រូវការផ្សេងៗក្នុងគ្រួសារ។

**ក្រុមដាំបន្លែ៖** ក្រុមដាំបន្លែដែលសមាជិកក្រុមចំនួន៧២គ្រួសារ ក្នុងនោះ នៅភូមិកោះក្រសាំង៧គ្រួសារព្រៃកត្របែក១៤គ្រួសារ ឈើទាល១២គ្រួសារ សន្លុង១៤គ្រួសារ ផ្លូវលួង១៣គ្រួសារ និងភូមិត្រពាំងថ្ម១២គ្រួសារ ពួកគាត់ទទួលបានវគ្គបណ្តុះបណ្តាល ពង្រឹង បង្វឹកសមត្ថភាពអំពីបច្ចេកទេសដាំបន្លែ មានដូចជាការប្រើប្រាស់ថ្នាំកម្ចាត់សត្វល្អិត ការធ្វើរងបន្លែតាមរដូវកាល ទទួលបានការវិនិយោគធុងទឹកសម្រាប់កសិកម្ម វិនិយោគការបោះបង្គោលស្នាក់ទឹក និងទុនវិនិយោគ ព្រមទាំងសម្ភារៈកសិកម្ម សម្រាប់ដាំបន្លែ ក្នុងនោះមានគ្រួសារចំនួន៦២គ្រួសារ(ពិការសរុប៤គ្រួសារ ស្ត្រីពិកា២គ្រួសារ ក្នុងនោះ ភូមិផ្លូវលួង១០/១១គ្រួសារ កោះក្រសាំង២១/២១គ្រួសារ ភូមិព្រៃកត្របែកគ្រួសារ៨/១០គ្រួសារ ភូមិឈើទាល៩/១២គ្រួសារ ភូមិសន្លុង៥/៧គ្រួសារ ភូមិត្រពាំងថ្ម៩/១១គ្រួសារ រហូតមកទល់ពេលនេះដំណាំបន្លែតាមគ្រួសារ





មាន ពោត ឪឡឹក សណ្តែកគួរ ត្រសក់ ត្រឡាច ស្ពៃស ស្ពៃមើម ខាត់ណា ល្ពៅ ត្រកួន ក្នុងនោះគ្រួសារចំណូលពីការលក់បន្លែចំនួន៦២គ្រួសារ ស្ត្រីជាមេគ្រួសារចំនួន២៤គ្រួសារ ក្នុងនោះគ្រួសារទទួលប្រាក់ចំណូលចន្លោះពីចំនួន ៦០០,០០០រៀល ដល់១,៥០០,០០០រៀលចំនួន៣៣គ្រួសារ និងប្រាក់ចំណូលចាប់ពីចំនួន១,៦០០,០០០រៀល ទៅដល់៩,០០០,០០០រៀលចំនួន២៩គ្រួសារ។ ទន្ទឹមនឹងភាពរីកចម្រើននៃការដាំបន្លែ ក៏នៅមានគ្រួសារចំនួន១០គ្រួសារ ពួកគាត់មិនអនុវត្តតាមបច្ចេកទេស EPDOបន្តចុះបង្វឹក និងធ្វើផែនការដាំដុះសារជាថ្មី ដោយនាំពួកគាត់ជាក្រុមតូចៗរៀនសូត្រពីគ្រួសារដែលអនុវត្តបានជោគជ័យតាមបច្ចេកទេស មានការធ្វើដី ការលើករង ការៀបតម្លើងប្រពន្ធ័ដំណក់ទឹក និងរៀបចំផែនការផលិតកម្មតាមគ្រួសារទាំងនោះ។

**<u>ក្រុមទីផ្សារៈ</u>**



EPDO ធ្វើការចងក្រងក្រុមទីផ្សារ បានចំនួន៦ក្រុម ភូមិត្រពាំងថ្ម១ក្រុម ភូមិសន្លុង១ក្រុម ភូមិឈើទាល១ក្រុម ភូមិកោះក្រសាំង១ក្រុម ភូមិព្រៃកត្របែក១ក្រុម និងភូមិផ្លូវលួង១ក្រុម សមាជិកក្រុមចូលរួមសរុបចំនួន៣៣នាក់ ស្រី១៧នាក់ ពួកគាត់ទទួលបានការពង្រឹងសមត្ថភាព អំពីការទំនាក់ទំនងពត៌មានទីផ្សារ អ្នកលក់ធាតុចូល អ្នកប្រមូលទិញ ការសិក្សាអំពីតម្លៃផលិតផល តម្រូវការរបស់ទីផ្សារ ការធ្វើជម្រើសក្នុងការរកឈ្មួញក្នុងការលក់ទិញផលិតផល ការកត់ត្រា និងធ្វើវេទិកាពហុភាគី ដើម្បីការវិភាគខ្សែច្រវ៉ាក់តម្លៃ សម្រាប់ក្រុមអ្នកផលិត ជាមួយអ្នកលក់ធាតុចូល អ្នកប្រមូលទិញផលិតផល ដើម្បីឲ្យពួកគាត់ជជែកពិភាក្សា និងធ្វើការចែករំលែកពត៌មានទីផ្សារ ធ្វើជម្រើសទីផ្សារ អ្នកលក់ធាតុចូលកសិកម្ម អ្នកប្រមូលទិញ។ល។ គណៈកម្មការដំណើរការធ្វើការចុះឈ្មោះ និងលេខទូរសព្ទ័នៅលើក្តារព័តមានតាមភូមិ សមាជិកក្រុមផលិតបន្លែ មានចំនួន១០២គ្រួសារ ស្ត្រីជាមេគ្រួសារចំនួន៣៤គ្រួសារ(ពិការសរុប១០គ្រួសារ ស្ត្រីពិកា៤គ្រួសារ) ពួកគាត់មានសមត្ថភាពធ្វើជម្រើសតម្លៃលក់ផលិតផលជាមួយឈ្មួញ ការធ្វើការចរចារតម្លៃផលិតផលជាមួយក្រុមប្រមូលទិញលក់ ព្រមទាំងធ្វើការទំនងពត៌មានតម្លៃជាមួយក្រុមហ៊ុនបន្លែសុវត្ថិភាព និងបានធ្វើការចរចារក្នុងតម្លៃសមរម្យ។ ចំពោះបន្លែមានការកើនឡើងនូវបរិមាណផលិតដូចជា សណ្តែកគួរ ត្រសក់ ត្រប់ ស្ពៃ និងសាលាដ។ល។ ចំពោះតម្លៃផលិតផលកសិកម្មរបស់ពួកគាត់ក៏មានការកើនឡើងជាងមុនផងដែរ ។



**ក្រុមសន្សំដើម្បីផ្លាស់ប្តូរ**

EPDO មានក្រុមសន្សំសរុបទាំងអស់ចំនួនចងក្រងក្រុមសន្សំដើម្បីផ្លាស់ប្តូរ ចំនួន៨ក្រុម មានអ្នកដឹកនាំក្រុមចំនួន៣២នាក់ ស្ត្រីជាអ្នកដឹកនាំក្រុមចំនួន២២នាក់ សមាជិកចំនួន១៥២នាក់ ស្រី២៨១នាក់ ក្នុងនោះភូមិផ្លូវលួង១ក្រុម សមាជិកចំនួន៣៩នាក់ ស្រី៣៥នាក់(អ្នកដឹកនាំក្រុម៤នាក់ ស្រី៣នាក់) ភូមិកោះក្រសាំង១ក្រុម សមាជិក១៣នាក់ ស្រី៨នាក់ (អ្នកដឹកនាំក្រុម៤នាក់ ស្រី២នាក់) ភូមិសន្លុង២ក្រុម សមាជិក៣០នាក់ ស្រី២៤នាក់(អ្នកដឹកនាំក្រុម៨នាក់ ស្រី៦នាក់) ភូមិឈើទាល២ក្រុម សមាជិក៣៥នាក់ ស្រី៣២នាក់(អ្នកដឹកនាំ៨នាក់ ស្រី៥នាក់) ភូមិត្រពាំងថ្ម២ក្រុម សមាជិក៣៥នាក់ ស្រី៣០នាក់(អ្នកដឹកនាំក្រុម៨នាក់ ស្រី៦នាក់)។ ក្នុងចំណោម៨ក្រុមនេះមានចំនួន៦ក្រុមអនុវត្តបានល្អ ស្របទៅតាមគោលការណ៏ក្រុមសន្សំទាំង៦ជំហាន និងកំពុងអនុវត្តការសន្សំ ជារៀងរាល់សប្តាហ៍ ព្រមទាំងមានសមាជិកខ្ចីថវិកាសន្សំចំនួន៣៨គ្រួសារ អស់ថវិកាចំនួន៣.៦៤៥.០០០៛ ប្រើប្រាស់ទៅលើការពង្រីកមុខរបរខ្នាតតូច១៣គ្រួសារ ចិញ្ចឹមមាន់៧គ្រួសារ ដាំបន្លែ១៥គ្រួសារ និងពង្រីកការធ្វើស្រែចំនួន៣គ្រួសារ ។



**ភ្នាក់ងារសុខភាពសត្វភូមិ:**



គម្រោងបានធ្វើការពង្រឹងសមត្ថភាពដល់ភ្នាក់ងារសុខភាពសត្វភូមិ ក្នុងនោះពួកគាត់ចំនួន៦នាក់ បានប្រើប្រាស់នូវសមត្ថភាពរបស់ខ្លួនក្នុងការចុះចាក់វ៉ាក់សាំង និងព្យាបាលសត្វ មានសត្វជ្រូក មាន់ គោ និងក្របីក្នុងសហគមន៍ មិនតែប៉ុណ្ណោះពួកគាត់មានការសហការគ្នា សាមគ្គីភាព ប្រឹក្សាយោបល់ជាមួយសមាជិកសហគមន៍ រួមចំណែកក្នុងការដោះស្រាយបញ្ហាសុខភាពសត្វតាមភូមិគោលដៅ ដើម្បីបង្កើនមានការគ្រប់គ្រងថែទាំសត្វក្នុងសហគមន៍ បានប្រសើរជាងមុន ។

***គោលបំណងទី២៖ សហគមន៍មានគ្រោះមហន្តរាយចំនួន៦ ដែលមានថ្នាក់ដឹកនាំ១០០នាក់ ស្រី២០នាក់ និងសមាជិកសហគមន៍ចំនួន៧៨០គ្រួសារមនុស្សសរុបចំនួន៣.៥៤០នាក់ និងស្ត្រី១៨៦៣នាក់ មានសមត្ថភាពទប់និងធន់នឹងហានិភ័យអាកាសធាតុនិងគ្រោះមហន្តរាយនៅឃុំចំនួន៤នៃស្រុកកណ្តៀងខេត្តពោធិ៍សាត់។***

អង្គការEPDO បានធ្វើការសម្របសម្រួល បង្វឹក បំពេញបន្ថែមមួយចំនួនដល់CCDMs ទាំងបួនឃុំ គឺឃុំកញ្ចរ អន្លង់វិល ស្វាយលួង ឃុំស្យា និងបណ្តុះបណ្តាល/ផ្សព្វផ្សាយ/ ធ្វើផែនការកាត់បន្ថយហានីភ័យគ្រោះសមាជមហន្តរាយដល់សមាជិកសហគមន៍ ជាលទ្ធផលបានបង្ហាញឲ្យឃើញថា:

១. EPDO ពង្រឹងសមត្ថភាពស្តីពីភាពជាអ្នកដឹកនាំដល់ VDC គណៈកម្មការប្រើប្រាស់ទឹក អ្នកចូលរួមសរុបទាំង៤ឃុំ មានចំនួនសរុប៨១នាក់ ស្រី៣១នាក់(ពិការប្រុស១នាក់) ក្នុងនោះឃុំកញ្ចរចំនួន២១នាក់ ស្រី៤នាក់(ពិការប្រុស១នាក់) ឃុំស្យាចំនួន១៩នាក់ ស្រី១០នាក់ ឃុំស្វាយលួងចំនួន១៨នាក់ ស្រី៤នាក់ និងឃុំអន្លង់វិលចំនួន២៣នាក់ ស្រី១៣នាក់ ក្នុងគោលបំណងៈបង្កើនការយល់ដឹងរបស់សមាជិក CCDM ពង្រឹងនូវការការគ្រប់គ្រងកំរិតសហគមន៍ ការរៀបចំផែនការឆ្លើយតប ការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ ការធ្វើការងារក្រុម ការដោះស្រាយទំនាស់ និងការធ្វើសេចក្តីសម្រេចចិត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ លទ្ធផលយើងសង្កេតឃើញថា ប្រជាពលរដ្ឋចំនួន៣៨០គ្រួសារកំពុងធ្វើការរៀបចំផែនការឆ្លើយតប ការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ ដែលជាការកាត់បន្ថយគ្រោះថ្នាក់អាយុជីវិតមនុស្ស ជាពិសេសកុមារតូចៗ។ តាមភូមិនិមួយៗបានលើកផែនការរបស់ខ្លួនដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ មិនតែប៉ុណ្ណោះ បុគ្គលិកEPDOសហការជាមួយCCDMs ចុះបង្វឹកតាមគ្រួសារបន្ថែមទៀត ធ្វើយ៉ាងណាឲ្យពួកគាត់មានការផ្លាស់ប្តូរទម្លាប់ប្រសើជាងមុន ដើម្បីកាត់បន្ថយហានីភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍។

២.បណ្តុះបណ្តាលពីរបៀបនៃការសរសេរគម្រោងសំណើសហគមន៍ខ្នាតតូច ដល់គណៈកម្មការអភិវឌ្ឍន៍ភូមិ និងCCDMsសរុបចំនួន៨១នាក់ ស្រី១៤នាក់ នោះឃុំកញ្ចរចំនួន២១នាក់ ស្រី៤នាក់ ឃុំស្យាចំនួន១៩នាក់ ស្រី១០នាក់ ឃុំស្វាយលួងចំនួន១៨នាក់ ស្រី៤នាក់ និងឃុំអន្លង់វិលចំនួន២៣នាក់ ស្រី១៣នាក់ ជាលទ្ធផល ពួកគាត់ចេះពីរបៀបសរសេរកំណត់ហេតុប្រជុំ របៀបនៃការប្រមូលព័ត៌មានសហគមន៍ របៀបសរសេរគម្រោងសំណើរសហគមន៍។ ជាក់ស្តែងសហគមន៍ភូមិត្រពាំងថ្ម មានសមត្ថភាពសរសេរសំណើ គំនិតផ្តួចផ្តើមសហគមន៍ គឺការសាងសង់ទំនប់ស្នាក់ទឹកព្រៃកក្នុងភូមិដាក់ជូនមកអង្គការEPDO ដើម្បីគាំទ្រដល់សហគមន៍ ហើយគម្រោងនេះបានដំណើការសាងសង់ក្រោយពីបានឯកភាពក្នុងការវិនិយោគរួមគ្នារវាងសហគមន៍ និងអង្គការ។ ទំនប់ស្នាក់ទឹកនៅចុងភូមិបានជួយឆ្លើយដល់តម្រូវការរបស់ប្រជាពលរដ្ឋចំនួន៣៩៣គ្រួសារ មនុស្សសរុប១៤១៤នាក់ ស្រី៧១៥នាក់ អាចយកទឹកប្រើប្រាស់ក្នុងគ្រួសារ ស្រោចស្រពបន្លែ ចិញ្ចឹមសត្វ និងដំណាំស្រូវផងដែរ ។

**សមត្ថភាពគ្រប់គ្រង:**CCDMsចំនួន៥៧នាក់ ស្រី១០នាក់ ពួកគាត់មានការផ្លាស់ប្តូរប្រកបដោយគុណភាពទៅលើការគិត មានសមត្ថភាពក្នុងការគ្រប់គ្រង ការធ្វើផែនការ ការឆ្លើយតបតម្រូវការការកាត់បន្ថយហានីយភ័យគ្រោះ

មហន្តរាយ ព្រមទាំងសម្របសម្រួលសមាជិកសហគមន៍ចូលរួមធ្វើផែនការតាមភូមិ ដើម្បីដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំ ដឹកនាំកិច្ចប្រជុំសាមញ្ញ/វិសាមញ្ញដោយមានរបៀបវារៈ មានក្រឡួទុកដាក់ឯកសារតាមឃុំនីមួយៗ មានការចូលរួមបញ្ចេញមតិយោបល់ ការធ្វើសេចក្តីសម្រេចចិត្ត ពីគ្រប់សមាជិកCCDMs មានការកត់ត្រា កំណត់ហេតុរបាយការណ៍ត្រឹមត្រូវ CCDMs មានសមត្ថភាពក្នុងការផ្សព្វផ្សាយបន្តដល់សមាជិកសហគមន៍ សម្របសម្រួល ដឹកនាំការប្រជុំគណៈកម្មការ និងរៀបចំចាត់ចែងការទទួលខុសត្រូវពេលគ្រោះរាំងស្ងួតកើតឡើងក្នុងអំឡុងពេលនេះ ពួកគាត់បានរៀបចំឯកសារសំណើរទៅ DCDM និងអង្គការដើម្បីសុំជំនួយមកជួសជុលរបាំងទ្វារទឹកនៅភូមិស្បា ឃុំស្បា និងសាង់សង់របាំងទប់នៅភូមិកូនក្រាយ ពួកគាត់ទាំង២ឃុំបានរក្សា និងទុកដាក់ឯកសារមានសុវត្ថិភាព ដែលជាការងាយស្រួលរក ហើយក៏ជាភស្តុតាងបញ្ជាក់អំពីការឆ្លើយតបតម្រូវការប្រជាពលរដ្ឋក្នុងភូមិគោលដៅទាំងពីរឃុំគឺឃុំកញ្ចរ និងឃុំស្បា។ ពួកគាត់ក៏បានធ្វើការកែសម្រួលរចនាសម្ព័ន្ធបំពេញបន្ថែមនូវសមាជិកដែលបាត់បង់សមត្ថភាព អសកម្ម និងលាឈប់ ដោយធ្វើការបោះឆ្នោតដើម្បីបំពេញបន្ថែម។

៣. EPDOធ្វើការសម្របសម្រួលដល់CCDMs ចុះផ្សព្វផ្សាយអំពីការត្រៀមបង្ការ ដើម្បីកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ និងការបន្សាំខ្លួននឹងការបម្រែបម្រួលអាកាសធាតុ អ្នកចូលរួមសរុបចំនួន៦១១នាក់ ស្រី៣៨០នាក់ ក្នុងនោះ(នៅភូមិគោលដៅ៦ភូមិ អ្នកចូលរួមចំនួន៤៣៦នាក់ ស្រី២៤០នាក់) ភូមិក្រៅគោលដៅ អ្នកចូលរួមចំនួន ១៧៥នាក់ ស្រី១៤០នាក់ (ភូមិជ្រៃងអ្នកចូលរួម៤៥នាក់ ស្រី៣២នាក់ ភូមិស្វាយចាន់អ្នកចូលរួម២៨នាក់ ស្រី២២នាក់ ភូមិស្វាយយាង៥៧នាក់ ស្រី៤៤នាក់ ភូមិស្វាយចំបក់៤៥នាក់ ស្រី៤២នាក់)។

ក្រោយពីបានទទួលការផ្សព្វផ្សាយ និងការបង្វឹកតាមគ្រួសារ ពីCCDMs ក្នុងភូមិគោលដៅទាំង៦ អ្នកភូមិ ជាពិសេសក្រុមផលិតមាន់ និងបន្លែ ពួកគាត់មានការផ្លាស់ប្តូរទម្លាប់នៃការចិញ្ចឹម ឬដាំបន្លែតាមយថាផល មកអនុវត្តតាមបច្ចេកទេស និងបច្ចេកវិទ្យាថ្មីដែលធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ គ្រួសារចំនួន៣៧២គ្រួសារ ស្ត្រីជាមេគ្រួសារចំនួន៨៩គ្រួសារ ជនពិការ១២នាក់ ស្ត្រីពិការ៣នាក់ មានសមត្ថភាពធន់នឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅឃុំចំនួន៤ នៃស្រុកកណ្តៀង ក្នុងនោះពួកកាត់មានការរៀបចំផែនការកាត់បន្ថយហានីយភ័យគ្រោះមហន្តរាយ ផែនការដាំដុះ តាមតម្រូវការទីផ្សារ ចេះជ្រើសរើសពូជដាំ ប្រភេទបន្លែដែលប្រើប្រាស់ទឹកតិចដូចជា ននោងត្រឡាច សណ្តែកគួរ និងត្រសក់ជាដើមនៅផ្នែកខាងលើ និងផ្នែកខាងក្រោមគាត់អាចដាំជី និងស្ពៃ ពួកគាត់ដាំបន្លែដោយប្រើប្រព័ន្ធដំណក់ទឹក ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ការរៀបចំដី ការលើករង ការបណ្តុះកូន ស្របតាមបច្ចេកទេសកសិកម្ម ដែលធន់នឹងអាកាសធាតុប្រសើរជាងមុន ដោយហេតុថា ពួកគាត់អាចធ្វើការបត់បែនទៅតាមស្ថានភាពនៃអាកាសធាតុដូចជា នៅរដូវប្រាំងខ្សត់ទឹក រីឯការចិញ្ចឹមមាន់ពួកគាត់ចិញ្ចឹមដោយប្រើដំបូលគ្របដោយស្លឹកដូង ស្លឹកត្នោត និងបាញ់ទឹកដើម្បីការពារកំដៅកុំឲ្យប៉ះពាល់ដល់សត្វចិញ្ចឹម។ តាមរយៈនៃការសង្កេតផ្ទាល់លទ្ធផលបានបង្ហាញថា ពួកគាត់មានការយល់ដឹង និងអនុវត្តបានល្អ និងទទួលបានប្រាក់ចំណូលប្រសើរជាងមុន។

**គោលចំណងទីបី:ស្ត្រីមានឥទ្ធិពលកាន់តែខ្លាំងក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលដល់សហគមន៍ និងគ្រួសាររបស់ពួកគេរួមទាំងការគ្រប់គ្រងលើធនធាន:**

**គណៈកម្មការស្ត្រី និងកុមារឃុំ CCWC**



អង្គការEPDOបានធ្វើការពង្រឹងសមត្ថភាពគណៈកម្មការស្ត្រី និងកមារថ្នាក់ឃុំCCWC ចំនួន៤ឃុំ ស្តីពីយេនឌ័រ ការបញ្ជ្រាបយេនឌ័រ សមភាពយេនឌ័រ យេនឌ័រនៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ដល់គណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារថ្នាក់ឃុំ(CCWC) មានអ្នកចូលរួមសរុបចំនួន ៨០នាក់ ស្រី៣៣នាក់ក្នុងនោះឃុំកញ្ជរ២១នាក់ ស្រី៤នាក់ ឃុំស្វាយលួង១៨នាក់ ស្រី៥នាក់ ឃុំអន្លង់វិល២២នាក់ ស្រី១៥នាក់ ឃុំស្សា ១៩នាក់ ស្រី៩នាក់ ។

ក្រោយពីទទួលបានការពង្រឹងសមត្ថភាពរួចមក ពួកគាត់មានសមត្ថភាពចុះធ្វើការអប់រំផ្សព្វផ្សាយ/ប្រឹក្សាយោបល់តាមគ្រួសារ លទ្ធផលបានបង្ហាញឃើញថាមានការកាត់បន្ថយអំពើហឹង្សាមិនសូវមានភាពញឹកញាប់ មានភាពអត់អោនលើកលែង បុរសជួយការងារផ្ទះច្រើនក្នុងគ្រួសារ ហើយមានការយកចិត្តទុកដាក់ចំពោះ កុមារជាងមុន ជាពិសេសកុមារតូចៗ។

EPDO បានផលិតប៉ាណូការគ្រប់គ្រងហានីភ័យគ្រោះមហន្តរាយ យេនឌ័រ និងកិច្ចការពារកុមារ សម្រាប់ផ្សព្វផ្សាយសារដល់សហគមន៍ ភូមិគោលដៅ៦ភូមិ ភូមិកោះក្រសាំងឃុំអន្លង់វិល ភូមិឈើទាល សន្លុង ឃុំស្វាយលួង ភូមិត្រពាំងថ្ម ឃុំស្សា ភូមិព្រែកត្របែក ភូមិផ្លូវលួង ឃុំកញ្ជរ។

EPDO សហការជាមួយមន្ត្រីការិយាល័យកិច្ចការនារី និងគណៈកម្មការទទួលបន្ទុកស្ត្រី កុមារថ្នាក់ឃុំ រៀបចំទិវានារីអន្តរជាតិ៨មីនានៅភូមិគោលដៅចំនួន៦ភូមិ អ្នកចូលរួមសរុប៥៣៩នាក់ ស្រី៣៧១នាក់ ក្នុងនោះភូមិសន្លុង១០១នាក់ ស្រី៧៣នាក់ ពិការ១នាក់ស្រី ភូមិត្រពាំងថ្ម១០០នាក់ ស្រី៦០នាក់ ភូមិកោះក្រសាំង៨៤នាក់ ស្រី៥៦នាក់ ភូមិផ្លូវលួង និងព្រែកត្របែក១៨០នាក់ ស្រី១៣១នាក់ ភូមិឈើទាល៩០នាក់ ស្រី៦០នាក់ សិស្ស១១នាក់ ស្រី៦នាក់។ គោលបំណង ដើម្បីរំលឹកខួបស្តីពីការតស៊ូរបស់នារីទូទាំងសកលលោក ក្នុងការទាមទារឲ្យមានការលើកកម្ពស់សមភាពយេនឌ័រ ដែលជាយុទ្ធសាស្ត្រគន្លឹះមួយ ផ្តល់ឱកាសដល់ស្ត្រី និងការអនុវត្តសិទ្ធិស្មើភាពរវាងបុរស និងស្ត្រី ដែលផ្តើមចេញពីស្ត្រីជាថ្នាក់ដឹកនាំ ប្រធានបទឆ្នាំនេះ(មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ )។



**ស្ត្រីមានមុខតំណែងជាអ្នកដឹកនាំ:** តាមរយៈការឆ្លុះបញ្ចាំងក្រុមនៅក្នុងសហគមន៍ទាំង៦ភូមិ លទ្ធផលបានបង្ហាញឲ្យឃើញថា ស្ត្រីចំនួន៥៥នាក់(ស្ត្រីពិកាចំនួន៥នាក់) ជាអ្នកដឹកនាំក្រុមសរុបចំនួន៣៩ក្រុម ក្នុងនោះក្រុមសន្សំដើម្បីផ្លាស់ប្តូរចំនួន ១១ក្រុម ចិញ្ចឹមសត្វ៦ក្រុម ដាំបន្លែ៦ក្រុម ក្រុមទីផ្សា៦ក្រុម និងគណៈកម្មការប្រើប្រាស់ទឹក៦ក្រុម ពួកគាត់មានសមត្ថភាព និងទទួលបានការលើកកំពស់ តួនាទីមានភាពប្រសើរឡើងនូវទំនាក់ទំនងយេនឌ័រ មានការចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចចិត្ត។

**ការកាត់បន្ថយអំពើហឹង្សា:** តាមរយៈការឆ្លុះបញ្ចាំងក្រុមនៅក្នុងសហគមន៍ទាំង៦ភូមិ និងការសម្ភាសន៍តាមគ្រួសារ បានបង្ហាញឲ្យឃើញថាៈ

សមាជិកសហគមន៍ចំនួន២៨៨នាក់ ស្ត្រីចំនួន១៥១នាក់ ពិការសរុប១២នាក់ ស្រីពិការ៤នាក់ បានរាយការណ៍ថាគ្រួសារដែលប្រវត្តិរងនូវអំពើហឹង្សាកាលពីមុនចូលគម្រោង ជាពិពេសគ្រួសារដែលងាយរងគ្រោះ នៅក្នុងសហគមន៍

ពួកគេមានភាពផ្លាស់ប្តូរ កាត់បន្ថយអំពើហឹង្សាមិនសូវមានភាពញឹកញាប់ មានភាពអត់អោន លើកលែង បុរសជួយការងារផ្ទះច្រើនក្នុងគ្រួសារ ហើយមានការយកចិត្តទុកដាក់ចំពោះកុមារជាងមុន ជាពិសេសកុមារតូចៗ។

**ស្ត្រីមានការគ្រប់គ្រងកាន់តែច្រើនលើធនធាន និងការសំរេចចិត្តនៅក្នុងគ្រួសារៈ** តាមរយៈការឆ្លុះបញ្ចាំងក្រុមនៅក្នុងសហគមន៍ទាំង៦ភូមិ និងការសម្ភាសន៍តាមគ្រួសារ បានបង្ហាញឲ្យឃើញថាៈ

ស្ត្រីចំនួន១៥១នាក់ ស្រីពិការ៤នាក់ ពួកគាត់ចូលរួមក្នុងការអនុវត្តគម្រោង មិនតែប៉ុណ្ណោះ ស្ត្រីកាន់តែមានសម្លេងខ្លាំង តាមរយៈការផ្តល់ឱកាសឲ្យពួកគាត់សម្របសម្រួលកិច្ចប្រជុំ ដឹកនាំក្រុមពិភាក្សា សម្រេចចិត្តក្នុងគ្រួសារបានកើនឡើងរួមមានៈការគ្រប់គ្រងលើការសម្រេចចិត្តទិញធនធាន ទ្រព្យសម្បត្តិ ដូចជាសត្វចិញ្ចឹម ម៉ូតូ គ្រឿងម៉ាស៊ីន ទូរទស្សន៍ ផ្ទះនិងដី។ គ្រប់គ្រងលើអាហារប្រចាំថ្ងៃកុមារ និងប្រាក់ចំណូលប្រចាំថ្ងៃក្នុងគ្រួសារ គ្រប់គ្រងលើការចំណាយប្រាក់លើពិធី ឬព្រឹត្តិការណ៍ផ្សេងទៀត ការធ្វើសេចក្តីសម្រេចចិត្ត និងត្រួតពិនិត្យការប្រមូលផលអំពីការដាំបន្លែ ចិញ្ចឹមសត្វ។ ទាំងអស់នេះជាលទ្ធផលបានបង្ហាញថា ស្ត្រីមានឥទ្ធិពលក្នុងការសម្រេចចិត្តដែលជះឥទ្ធិពលដល់សហគមន៍ និងគ្រួសាររបស់ពួកគេ លើគ្រប់គ្រងធនធាន។

# ២. គម្រោងបង្កើតបណ្តុំអាជីវកម្មវារីវប្បកម្ម ខេត្តពោធិ៍សាត់

គាំទ្រថវិកាដោយ

IFAD
Investing in rural people

## ២.១ សេចក្តីផ្តើម:

ក្នុងរបាយការណ៍នៃគម្រោង **បង្កើតបណ្តុំអាជីវកម្មវារីវប្បកម្ម** ក្នុងខេត្តពោធិ៍សាត់គឺ បានអនុវត្តន៍ជាមួយបណ្តុំអាជីវកម្មវារីវប្បកម្មចំនួន៥ ក្នុង៤ឃុំ ៣ស្រុក ក្នុងភូមិ ចំនួន៥ (ភូមិកំពង់ឡ ពោធិ៍កុដ ឃុំកំពង់ពោធិ៍ ស្រុកក្រគរ ភូមិស្យា ឃុំកណ្តៀង ភូមិសែនជ័យ ឃុំស្រែស្តុក ស្រុកកណ្តៀង ភូមិស្រែល្វា ឃុំត្រពាំងជង ស្រុកបាកាន)។ គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដល់សមាជិកបណ្តុំអាជីវកម្មវារីវប្បកម្ម និងការផ្សាភ្ជាប់ខ្សែច្រវ៉ាក់ផលិតកម្មទីផ្សារ។

គម្រោងនេះមានរយៈពេល៧ខែ គិតចាប់ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ ទទួលបានការគាំទ្រថវិកាពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់។

## ២.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះបណ្តុំ | សរុប | ស្រី |
|---|---|---|---|---|---|---|
| ពោធិ៍សាត់ | ក្រគរ | កំពង់ពោធិ៍ | កំពង់ឡ | បណ្តុំអាជីវកម្មកង្កែបកំពង់ឡ | 45 | 19 |
| ពោធិ៍សាត់ | ក្រគរ | កំពង់ពោធិ៍ | ពោធិ៍កុដ | បណ្តុំអាជីវកម្មកង្កែបពោធិ៍កុដ | 26 | 15 |
| ពោធិ៍សាត់ | ក្រគរ | កំពង់ពោធិ៍ | ចេកចៅ | បណ្តុំអាជីវកម្មកង្កែបចេកចៅ | 20 | 8 |
| ពោធិ៍សាត់ | កណ្តៀង | កណ្តៀង | ស្យា | បណ្តុំអាជីវកម្មកង្កែបស្យា | 31 | 17 |
| ពោធិ៍សាត់ | កណ្តៀង | ស្រែស្តុក | សែនជ័យ | បណ្តុំអាជីវកម្មកង្កែបសែនជ័យ | 30 | 22 |
| ពោធិ៍សាត់ | កណ្តៀង | ស្រែស្តុក | វាល | បណ្តុំអាជីវកម្មកង្កែបសែនជ័យ | 9 | 3 |
| ពោធិ៍សាត់ | បាកាន | ត្រពាំងជង | ស្រែល្វា | បណ្តុំអាជីវកម្មកង្កែបស្រែល្វា | 39 | 13 |
| សរុប | ៣ | ៤ | ៧ | ៥ | 200 | 97 |

## ២.៣ លទ្ធផលសម្រេចបាន:

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងលទ្ធផលរបស់គម្រោងបង្កើតបណ្តុំអាជីវកម្មវារីវប្បកម្មកង្កែប ខ្សែច្រវ៉ាក់តម្លៃ ក្នុងខេត្តពោធិ៍សាត់ EPDO បានអនុវត្តសកម្មភាពមួយចំនួន ដែលទទួលបានលទ្ធផលដូចខាងក្រោម៖



1. EPDO បានរៀបចំឯកសារទស្សនៈទានសម្រាប់អនុវត្តន៍គម្រោងមាន ផែនការសកម្មភាព វិធីសាស្ត្រអនុវត្តគម្រោង វិធីសាស្ត្រជ្រើសរើសតំបន់គោលដៅ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកទទួលផលដែលមានសក្តានុពលក្លាយជាកសិករគំរូក្នុងការចិញ្ចឹមកង្កែប និងជាលក្ខណៈអាជីវកម្ម ។ EPDO បានប្រជុំផ្សព្វផ្សាយពីសកម្មភាពគម្រោងចិញ្ចឹមកង្កែប/ត្រីដល់កសិករទូទៅក្នុងភូមិ និងជ្រើសរើសអ្នកទទួលផលគម្រោងក្នុងតំបន់គោលដៅចំនួន៥ភូមិ ក្នុង៤ឃុំ ៣ស្រុក បន្ទាប់ពីជ្រើសរើសកសិករបានហើយ ចងក្រងបណ្តុំវារីវប្បកម្មកង្កែប បានចំនួន៥បណ្តុំ មានសមាជិកសរុបចំនួន២០០គ្រួសារ ក្នុង៥ភូមិ ៤ឃុំ ៣ស្រុក បណ្តុំនិមួយៗមានគោលការណ៍ លក្ខខន្តិកៈបណ្តុំ រចនាសម្ព័ន្ធដឹកនាំ សម្រាប់សមាជិក និងអ្នកដឹកនាំអនុវត្តន៍ ក្នុងបណ្តុំនិមួយៗមានអ្នកធ្វើបង្ហាញចំនួនម្នាក់ ព្រមទាំងបញ្ចូលឈ្មោះគ្រួសារអ្នកទទួលផលក្នុងប្រពន្ធ័MISរបស់កម្មវិធី ASPIRE។ ធ្វើការប្រមូលទិន្នដើម និងទិន្នន័យចុងក្រោយចំនួន២០០គ្រួសារ និងទិន្នន័យសង្ខេប ដើម្បីកំណត់ការវាស់វែងទិន្នន័យ នៃបរិមាណលក់ និងកំណើនប្រាក់ចំណេញរបស់អ្នកទទួលផល (សំណាក១២%នៃគ្រួសារសរុបត្រូវបានជ្រើសរើស សម្រាប់ការវាយតម្លៃ) បានចំនួន២៤គ្រួសារ ស្រី១២គ្រួសារ។
2. EPDO បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មកង្កែបធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ ជាទ្រឹស្តី ការអនុវត្តផ្ទាល់ និងបង្វឹកជាប្រចាំបានចំនួន៥វគ្គ ដោយមានអ្នកចូលរួមចំនួន២០០នាក់/ស្រី៩៧នាក់ និងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសបង្កាត់ ភ្ញាស់កូនកង្កែប ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ការអនុវត្តន៍ការចិញ្ចឹមមេ បាកង្កែប និងថែទាំកូនកង្កែប ដល់កសិករគំរូចំនួន៥ ដើម្បីបង្កាត់ ភ្ញាស់កូនកង្កែបសម្រាប់លក់ដល់សមាជិក ។
3. EPDO រៀបចំគំរូប្លង់ស្រះចិញ្ចឹមកង្កែប (អាងប្លាស្ទិច)ចំនួន២ សម្រាប់ការចិញ្ចឹមកង្កែបដែលត្រូវនឹងលក្ខខណ្ឌអាកាសធាតុអំណោយផលដើម្បីគាំទ្រដល់កសិករគំរូចំនួន៥ និងសមាជិក យកទៅអនុវត្តន៍ទៅតាមបច្ចេកទេស ព្រមទាំងធ្វើការកៀគរធនធាន និងផ្តល់ការគាំទ្រសម្ភារៈសម្រាប់សាងសង់អាងបានចំនួន៥កសិករគំរូ និងតម្លើងស្រះប្លាស្ទិចសម្រាប់ចិញ្ចឹមកង្កែបក្នុងកសិដ្ឋានបង្ហាញបានចំនួន៥កន្លែង។ បានធ្វើការកៀគរធនធានដើម្បីសាងសង់អាងចិញ្ចឹមកង្កែបជាមួយសមាជិកបណ្តុំបានចំនួន១៩៥អាង ដោយអាងកង្កែបនិមួយៗមានដំបូលជួយការពារកំដៅផងដែរ។
4. EPDO បានផ្តល់ការគាំទ្រធនធានដល់កសិករគំរូទាំង៥រួមមានៈ កង្កែបពូជចំនួន៤០ក្បាល កូនកង្កែបចំនួន១000ក្បាល អាងប្លាស់ស្ទិចចំនួន១០ ចំណី PHវាស់ទឹក ថ្នាំសំអាតទឹក ថ្នាំសម្លាប់មេរោគ ថ្នាំវីតាមីន អ័រមូន Azolla ជាចំណីកង្កែបដែលសំបូរទៅដោយប្រូតេអ៊ីនចំនួន១០គក្រ សម្រាប់ផលិតកូនកង្កែប លក់ជូនសមាជិកបណ្តុំ និងក្រៅបណ្តុំ និងផ្តល់កូនកង្កែបដល់សមាជិកបណ្តុំវារីវប្បកម្មកង្កែបចំនួន១៩៥គ្រួសារ សរុបចំនួន៤៨.៧៥០ក្បាល(ម្នាក់ៗទទួលបានចំនួន២៥០ក្បាល)សម្រាប់ជាដើមទុនក្នុងការពង្រីកអាជីវកម្មវារីវប្បកម្មគ្រួសារ ។
5. ជ្រើសរើសកសិករឆ្នើមដែលមានសមត្ថភាពអាចផ្ទេរចំណេះដឹងដល់កសិករដទៃបានចំនួន៥គ្រួសារ និងកន្លែងសិក្សារៀនសូត្រ អនុវត្តជាក់ស្តែង និងគាំទ្របច្ចេកទេសរបស់កសិករ ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាល

ពីជំនាញTOT១វគ្គ មានអ្នកចូលរួមចំនួន១០នាក់/ស្រី២នាក់ ដើម្បីឱ្យគាត់ក្លាយជាគ្រូបង្គោលក្នុងបណ្តុំ មានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ល្អៗ បច្ចេកទេស និងជោគជ័យជាមួយសមាជិក និងសមាជិកដទៃទៀត ។ កសិករជាគ្រូបង្គោលតាមបណ្តុំនិមួយៗបានធ្វើការផ្សព្វផ្សាយចែករំលែកបទពិសោធន៍ចំណេះដឹងបច្ចេកទេសដែលទទួលបានពីវគ្គបណ្តុះបណ្តាល និងការអនុវត្តបានល្អដល់សមាជិកបណ្តុំវារីវប្បកម្មចំនួន៥បណ្តុំ មានអ្នកចូលរួមសរុប១៨៧នាក់/ស្រី១៣២នាក់។ រៀបចំទិវាបង្ហាញដើម្បីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ បង្ហាញពីលទ្ធផល ចំណុចខ្លាំង ខ្សោយ របស់បណ្តុំ ដែលសំរេចបានក្នុងរយៈពេល៧ខែកន្លងមក និងជំរុញការលក់កូនកង្កែបរបស់កសិករគំរូទៅសមាជិកបណ្តុំដែលចង់ពង្រីកការចិញ្ចឹមកង្កែបដោយមានការបញ្ចុះតម្លៃចំនួន២០%សម្រាប់សមាជិកបានចំនួន៥វគ្គ ដោយមានអ្នកចូលរួមចំនួន១៥៩នាក់/ស្រី៩៥នាក់ ។

6. EPDO ធ្វើការសម្របសម្រួលជាមួយជនបង្គោលទីផ្សារ និងអ្នកដឹកនាំបណ្តុំក្នុងការកំណត់ឈ្មួញសំខាន់ៗនឹងអ្នកទិញចល័តដែលមានសក្តានុពលចំនួន៥នាក់ អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មចំនួន១កន្លែង សម្រាប់ផលិតកម្មវារីវប្បកម្មផ្សាភ្ជាប់ទៅនឹងទីផ្សារ។ រៀបចំបង្កើតឲ្យមានទីតាំងលក់កង្កែបរួមគ្នាចំនួន៥កន្លែង ដើម្បីធានាឲ្យមានតម្លៃសមរម្យមួយអាចទទួលយកបាន។ ផ្តល់វគ្គបណ្តុះបណ្តាលដល់ជនបង្គោលទីផ្សារ និងសមាជិកបណ្តុំវារីវប្បកម្ម ស្តីពីគោលគំនិតទីផ្សារ ផែនការអាជីវកម្ម និងសៀវភៅកត់ត្រាផលិតកម្មកង្កែបផ្អែកលើតំរូវការទីផ្សារដោយមានអ្នកចូលរួមចំនួន១០នាក់/ស្រី២នាក់។ បង្កើតឲ្យមានផែនការអាជីវកម្ម និងសៀវភៅកត់ត្រាពីផលិតកម្មរបស់បណ្តុំនមួយៗ។ រៀបចំបណ្តាញទីផ្សារចំនួន១ ដោយមានសមាសភាពជាតំណាងមកពីបណ្តុំទាំង៥ អ្នកប្រមូលទិញ អ្នកលក់ធាតុចូលកសិកម្ម មានសមាជិកសរុបចំនួន១១នាក់/ស្រី២នាក់ សម្រាប់ធ្វើការទំនាក់ទំនងគ្នា ចែករំលែកព័ត៌មានទីផ្សារ ។ រៀបចំវេទិកាពហុភាគី (MSP) បានចំនួន៥បណ្តុំ ដោយមានអ្នកចូលរួមចំនួន១៦៨នាក់/ស្រី៦៩នាក់ វេទិកានេះធ្វើឡើងក្នុងគោលបំណង ដើម្បីឲ្យគ្រប់ភាគីពាក់ព័ន្ធមានឱកាសជួយគាំទ្រដល់ផែនការអាជីវកម្មតាមបណ្តុំនិមួយៗ។ ប្រជុំពិភាក្សាជាមួយសមាជិកបណ្តុំអាជីវកម្មវារីវប្បកម្មកង្កែបទាំង៥បណ្តុំ និងប្រជុំពិភាក្សាជាមួយតំណាងបណ្តុំ អ្នកប្រមូលទិញកង្កែប ដើម្បីបង្កើតកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាទិញ លក់កង្កែប និងបានចុះកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាបានចំនួន៥បណ្តុំ រវាងអ្នកប្រមូលទិញ និងសមាជិកបណ្តុំអាជីវកម្មផលិតកម្មកង្កែប។ បានផលិត និងតម្លើងក្តារព័ត៌មានទីផ្សារចំនួន៥ ដើម្បីកត់ត្រាផលិតកម្មនិងតម្លៃ ដាក់នៅតាមទីតាំងប្រមូលផ្តុំលក់កង្កែប

7. ដោយសារតែក្នុងខេត្តពោធិ៍សាត់មិនមានកម្មវិធី AIMs EPDO បានធ្វើការសម្របសម្រួលជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ (ប្រាសាក់ អេអឹមខេ និងពលរដ្ឋរុងរឿង) ដើម្បីឲ្យផ្តល់ប្រាក់កំចីសម្រាប់ពង្រីកមុខរបរផលិតកម្មវារីវប្បកម្មដោយមានការប្រាក់ទាប ផ្នែកមីក្រូហិរញ្ញវត្ថុ និងធនាគារគាត់មានគោលការណ៍នៃការខ្ចីប្រាក់ ដោយបានណែនាំថា ខ្ចីប្រាក់កាន់តែច្រើន ការប្រាក់កាន់តែទាប តែការខ្ចីមិនថា បុគ្គល ឬជាក្រុមត្រូវតែមានដាក់របស់បញ្ចាំ ទើបអនុញ្ញាតឲ្យខ្ចីបាន។

8. បណ្តុំនិមួយៗមានអាណត្តិប្រជុំជាមួយសមាជិកប្រចាំខែជាទៀងទាត់ ដើម្បីពង្រឹងការអនុវត្តបច្ចេកទេសការចិញ្ចឹកង្កែប ចែករំលែកព័ត៌មាន បទពិសោធន៍ពីការអនុវត្ត ធ្វើការកៀរគរធនធានសាងសង់អាង ពង្រឹងការរៀបចំអាងកង្កែប តម្លៃលក់កូនកង្កែប និងកង្កែបសាច់ ការដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការចិញ្ចឹមកង្កែប ជំរុញការពង្រីកមុខរបរចិញ្ចឹមកង្កែបដើម្បីងាយស្រួលក្នុងការស្វែងរកទីផ្សារ និងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់បណ្តុំ បានចំនួន២០លើក(១បណ្តុំ៥លើក)ដោយមានអ្នកចូលរួមចំនួន១៨១នាក់/ស្រី១០២នាក់។

## ២.៤ លទ្ធផលរយៈពេលខ្លី:

1) បណ្តុំវារីវប្បកម្មចិញ្ចឹមកង្កែបចំនួន៥ត្រូវបានបង្កើត ដោយមានសមាជិកចំនួន២០០នាក់ ស្រី៩៧នាក់ បាននឹងកំពុងអនុវត្តការចិញ្ចឹមកង្កែបតាមបច្ចេកទេស ស្របតាមលក្ខខន្តិកៈ បទបញ្ជាផ្ទៃក្នុង របស់បណ្តុំនិមួយៗ។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលមកសមាជិកបណ្តុំចំនួន៨៥% មានការយល់ដឹងច្បាស់ពីបច្ចេកទេសចិញ្ចឹមកង្កែប និងទីផ្សារ គ្រួសារនិមួយៗទទួលបានកូនកង្កែប២៥០ក្បាល សម្រាប់យកទៅចិញ្ចឹមតាមលក្ខណៈបច្ចេកទេស ដើម្បីពង្រីកផលិតកម្មកង្កែបក្នុងគ្រួសារ ព្រមទាំងយកចំណេះដឹងទាំងនេះទៅអនុវត្តក្នុងការពង្រឹងមុខរបរ និងស្វែងរកទីផ្សារលក់កង្កែបរបស់ខ្លួន។
2) កសិករគំរូចំនួន៥កន្លែងទទួលបានការគាំទ្រសំភារៈបរិក្ខា ថ្នាំសំរាប់ផលិតកម្មកង្កែប មេពូជកង្កែប និងកូនកង្កែប សម្រាប់ផលិតកូនលក់ជូនសមាជិកបណ្តុំ និងអ្នកភូមិដែលមានចំណាប់អារម្មណ៍ក្នុងការចិញ្ចឹមកង្កែបសម្រាប់ពេលអនាគត។ ពួកគាត់បានក្លាយជាគ្រូបង្គោលបណ្តុំ សម្រាប់សមាជិកបណ្តុំរៀនសូត្រ ចែករំលែកបទពិសោធន៍ល្អៗ ប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការចិញ្ចឹមកង្កែប ផលិតពូជ កូន និងផ្សព្វផ្សាយបច្ចេកទេសដល់កសិករដទៃទៀតក្នុងភូមិ។
3) ក្នុងកំឡុងពេលអនុវត្តបច្ចេកទេសចិញ្ចឹមកង្កែប រៀនសូត្របទពិសោធន៍បណ្តើរ ទោះបីកសិករបានជួបបញ្ហាកង្កែបមានជំងឺខ្លះៗមែនពិត តែអ្នកអ្នកបច្ចេកទេសវារីវប្បកម្មរបស់អង្គការ EPDO បានអន្តរាគមន៍ដោះស្រាយទាន់ពេល ដោយធ្វើការដឹកនាំឲ្យមានការប្រជុំនៅក្នុងបណ្តុំ និងបានដឹកនាំកសិករឲ្យអនុវត្តជាក់ស្តែងនៅកន្លែងចិញ្ចឹមតែម្តង ដោយធ្វើការណែនាំពីការប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលជំងឺកង្កែបទៅតាមប្រភេទនៃជំងឺនីមួយៗ ចំណែកគុណភាពទឹកវិញ បានធ្វើការណែនាំឲ្យកសិករផ្លាស់ប្តូរទឹកឲ្យបានញឹកញាប់ និងប្រើប្រាស់ជី EX-M ដើម្បីធ្វើការសម្លាប់មេរោគក្នុងទឹកផងដែរ។
4) បណ្តុំអាជីវកម្មវារីវប្បកម្មមានបណ្តាញទីផ្សារ និងកន្លែងប្រមូលផ្តុំទិញ លក់កង្កែប ដែលមានសមាសភាពដូចជាៈ អ្នកដឹកនាំបណ្តុំ ម្ចាស់ដេប៉ូលក់សម្ភារៈកសិកម្ម ឈ្មួញទទួលទិញ ក្នុងការទំនាក់ទំនងគ្នា ការផ្លាស់ប្តូរពូជ ការចរចារពីតម្លៃលក់កង្កែបសាច់ កូនកង្កែប ទីផ្សារដែលត្រូវលក់កង្កែប ការសិក្សាពីតម្លៃក្នុងការលក់ និងទិញសម្ភារៈកសិកម្ម ដើម្បីពង្រីកផលិតកម្មកង្កែបស្របតាមតម្រូវការទីផ្សារ ព្រមទាំងបានចុះកិច្ចព្រមព្រៀងក្នុងការលក់កង្កែបជាមួយឈ្មួញក្នុងស្រុក ដោយមានតម្លៃសមរម្យ។
5) មានអ្នកលក់ធាតុចូលកសិកម្មជាសមាជិកបណ្តាញ ការទិញលក់ធាតុចូលកសិកម្ម សម្រាប់ការចិញ្ចឹមកង្កែបបានធូរថ្លៃជាងមុន ដោយសារមានក្រុម និងបណ្តាញ ជាពិសេសទិញជាមួយដេប៉ូ ដែលបានចូលរួមជាមួយបណ្តាញទីផ្សារកង្កែបតែម្តង។

## ២.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង

1. បន្ទាប់ពីទទួលបានបច្ចេកទេសនៃការចិញ្ចឹម និងបង្កាត់ភ្ញាស់ពីអ្នកបច្ចេកទេសពីអង្គការ EPDO កសិករគំរូទាំង៥បណ្តុំ និងសមាជិកមួយចំនួនមានចំណាប់អារម្មណ៍បានទុកកង្កែបពូជ ដើម្បីធ្វើការផលិតនៅតាមបណ្តុំ និងនៅតាមផ្ទះ ដើម្បីងាយស្រួលយកមកចិញ្ចឹម និងលក់ដល់សមាជិកក្នុងបណ្តុំ និងកសិករដទៃដែលមានចំណាប់អារម្មណ៍ចង់ទិញកូនកង្កែបយកទៅចិញ្ចឹមបន្ត។ កសិករមួយចំនួនក្នុងបណ្តុំបានទៅធ្វើទស្សនៈកិច្ចសិក្សា រៀនសូត្រនៅកន្លែងកសិករគំរូ និង ជាសមាជិកបណ្តុំ ដែលអនុវត្តបានល្អ ដើម្បីស្វែងយល់ពីបច្ចេកទេស និងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកដែលពីមុនមកមិនធ្លាប់មាន។

2. ក្រោយពីបានចូលរួមជាមួយគម្រោង កសិករនៅក្នុងបណ្តុំអាជីវកម្មវារីវប្បកម្មទាំងអស់បានសហការគ្នាល្អ បានចូលរួមប្រជុំពិភាក្សា ការធ្វើសេចក្តីសម្រេចចិត្ត ការចែករំលែកចំណេះដឹង និងបទពិសោធន៍ពីការអនុវត្តជាក់ ស្តែងនៃការចិញ្ចឹមកង្កែប និងបានធ្វើការចែករំលែកពីការអនុវត្តល្អ និង មិនសូវល្អ ទៅវិញ ទៅមក ដើម្បីរួមគ្នាធ្វើការកែសម្រួលការចិញ្ចឹមកង្កែបឲ្យកាន់តែប្រសើរជាងមុន។
3. កសិករគំរូទាំង៥នាក់ និងសមាជិកបានរៀបចំផែនការផលិតកម្ម ពង្រីកការចិញ្ចឹមកង្កែបតាមរយៈការបង្កាត់ភ្ញាស់ដោយខ្លួនឯងក្នុងរដូវកាលថ្មីនៅឆ្នាំ២០២១ និងចង់បង្កើនការលក់កូនកង្កែបទៅឲ្យសមាជិកបណ្តុំរបស់ខ្លួន ដើម្បីទទួលបានប្រាក់ចំណូលបន្ថែម មានការងារធ្វើ កាត់បន្ថយការចេញទៅរកស៊ីនៅក្រៅស្រុក។
4. កណ្តុំអាជីវកម្មមានទីផ្សារល្អជាងមុន ពួកគេបានធ្វើការសិក្សាពីតម្រូវការទីផ្សារ ត្រូវការកង្កែបប្រភេទណា មានលក្ខខណ្ឌក្នុងការទិញយ៉ាងណាខ្លះ ដូចជាទំហំ អាយុកាល តម្លៃដោយភ្ជាប់ទំនាក់ទំនងជាមួយឈ្មួញក្នុងស្រុក និងក្រៅស្រុក ព្រមទាំងបានចុះកិច្ចសន្យាជាមួយអ្នកទិញ ទៀតផង

# ២.៦ .និរន្តរភាពនៃគម្រោង

ដើម្បីធានានូវនិរន្តរភាព EPDO បានធ្វើការសម្របសម្រួល និងបង្កើតជាបណ្តុំវារីវប្បកម្ម ព្រមទាំងធ្វើការពង្រឹងសមត្ថភាពដល់សមាជិកបណ្តុំ អ្នកដឹកនាំបណ្តុំ ដើម្បីឲ្យពួកគាត់មានសមត្ថភាពរឹងមាំក្នុងការគ្រប់គ្រង ចាត់ចែងនូវធនធាន និងសមិទ្ធិផលដែលបានគាំទ្រ ដូចជាៈ សម្ភារៈ ពូជកង្កែប និងចំណេះដឹង មិនតែប៉ុណ្ណោះពួកគាត់មានផែនការក្នុងការពង្រីកមុខរបរចិញ្ចឹមកង្កែប មានការទំនាក់ទំនងជាមួយឈ្មួញបានល្អ លក់បានតម្លៃសមរម្យ ព្រមទាំងមានការគាំទ្រលើកទឹកចិត្តពីអាជ្ញាធរ កសិកម្មស្រុក ខេត្ត អង្គការ វិស័យឯកជន ពួកគាត់បានចូលរួមតាំងពីចាប់ផ្តើមរហូតមកក្នុងអំឡុងពេលនៃការអនុវត្តគម្រោង បានធ្វើឲ្យពួកគាត់មានការផ្លាស់ប្តូរឥរិយាបទ ទទួលយកការចិញ្ចឹមកង្កែបដែលជាបច្ចេកទេសថ្មី ក្នុងការពង្រីកមុខរបររកប្រាក់ចំណូលបន្ថែ។ តាមរយៈនៃការចុះតាមដាន និងការបង្វឹកជាប្រចាំ យើងសង្កេតឃើញថា សមាជិកបណ្តុំ និងអ្នកដឹកនាំបណ្តុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រកបមុខរបរចិញ្ចឹមកង្កែប ដោយគាត់បានចុះកិច្ចសន្យាជាមួយឈ្មួញកណ្តាល មានតម្លៃសមរម្យ មានបណ្តាញទីផ្សារក្នុងការទំនាក់ទំនងគ្នា មានកន្លែងក្នុងការប្រមូលផ្តុំកល់កង្កែបរួមគ្នា យុទ្ធសាស្ត្រនេះយើងមើលឃើញថា អនាគត សមាជិកទាំងនោះនៅតែបន្ត និងពង្រីកមុខរបរចិញ្ចឹមកង្កែប ដោយហេតុថា ងាយស្រួលក្នុងការចិញ្ចឹម ចំណាយធនធានតិច ប្រើរយៈពេលចិញ្ចឹមខ្លី ឆាប់បានលក់ ងាយស្រួលក្នុងការរកទីផ្សារលក់ និងមានការជួយអន្តរាគមន៍គាំទ្រពីអ្នកពាក់ព័ន្ធ ជាពិសេសគឺមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត អាជ្ញាធរមូលដ្ឋាន និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំជាដើម។

# ៣. គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ខេត្តពោធិ៍សាត់

**គាំទ្រថវិកាដោយ**

IFAD
Investing in rural people

## ៣.១ សេចក្តីផ្តើម:

ក្នុងរបាយការណ៍នៃគម្រោង **គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់** ក្នុងខេត្តពោធិ៍សាត់គឺ បានអនុវត្តន៍ជាមួយបណ្តុំអាជីវកម្មចិញ្ចឹមមាន់ចំនួន៦ ក្នុង៣ឃុំ ២ស្រុក ក្នុងភូមិចំនួន៦ (ភូមិបឹងឈូក ស្វាយជ្រុំ និងភូមិត្រាំសេះ ឃុំបឹងបត់កណ្តាល ស្រុកបាកាន ភូមិបន្ទាយក្រង ឃុំអន្លង់ត្នោត ភូមិចាមចាស់ និងភូមិបំណាក់ ឃុំឈើតុំ ស្រុកក្រគរ)។ គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដល់សមាជិកបណ្តុំអាជីវកម្មមាន់ និងការផ្សាភ្ជាប់ខ្សែច្រវ៉ាក់ផលិតកម្មទីផ្សារ

គម្រោងនេះមានរយៈពេល៧ខែ គិតចាប់ពីថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ទទួលបានការគាំទ្រថវិកាពីគម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់។

## ៣.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ឈ្មោះបណ្តុំ | សរុប | ស្រី |
|---|---|---|---|---|---|---|
| ពោធិ៍សាត់ | ក្រគរ | អន្លង់ត្នោត | បន្ទាយក្រង | បណ្តុំអាជីវកម្មមាន់បន្ទាយក្រង | 40 | 31 |
| ពោធិ៍សាត់ | ក្រគរ | ឈើតុំ | ចាមចាស | បណ្តុំអាជីវកម្មមាន់ចាមចាស់ | 40 | 24 |
| ពោធិ៍សាត់ | ក្រគរ | ឈើតុំ | បំណាក់ | បណ្តុំអាជីវកម្មមាន់បំណាក | 40 | 26 |
| ពោធិ៍សាត់ | បាកាន | បឹងបត់កណ្តាល | ត្រាំសេះ | បណ្តុំអាជីវកម្មមាន់ត្រាំសេះរីកចំរើន | 40 | 23 |
| ពោធិ៍សាត់ | បាកាន | បឹងបត់កណ្តាល | ស្វាយជ្រុំ | បណ្តុំអាជីវកម្មមាន់ស្វាយជ្រុំ | 40 | 25 |
| ពោធិ៍សាត់ | បាកាន | បឹងបត់កណ្តាល | បឹងឈូក | បណ្តុំអាជីវកម្មមាន់បឹងឈូករីករាយ | 40 | 39 |
| **សរុប** | **2** | **3** | **6** | **6** | **240** | **168** |

**គោលបំណង:** ដើម្បីបង្កើនសមត្ថភាពដល់សមាជិកបណ្តុំអាជីវកម្មវារីវប្បកម្ម ក្នុងភូមិគោលដៅចំនួន៦ ឃុំចំនួន៣ និងស្រុកចំនួន២ នៃខេត្តពោធិ៍សាត់ ដែលមានសមាជិកសរុប ២៤០គ្រួសារ។

## ៣.៣ លទ្ធផលសម្រេចបាន:

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងលទ្ធផលរបស់គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ខ្សែច្រវ៉ាក់តម្លៃ ក្នុងខេត្តពោធិ៍សាត់ EPDO បានអនុវត្តសកម្មភាព និងទទួលបានលទ្ធផលដូចខាងក្រោម៖

1. EPDO បានរៀបចំឯកសារទស្សនៈទានសម្រាប់អនុវត្តន៍គម្រោងមាន ផែនការសកម្មភាព វិធីសាស្រ្តអនុវត្តគម្រោង វិធីសាស្រ្តជ្រើសរើសតំបន់គោលដៅ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកទទួលផលដែលមានសក្តានុពលក្លាយជាកសិករចិញ្ចឹមមាន់គំរូ និងជាលក្ខណៈអាជីវកម្ម ។ EPDO បានប្រជុំផ្សព្វផ្សាយពីសកម្មភាពគម្រោងចិញ្ចឹមមាន់ដល់កសិករទូទៅក្នុងភូមិ និងជ្រើសរើសអ្នកទទួលផលគម្រោងក្នុងតំបន់គោលដៅចំនួន៧ភូមិ ក្នុង៣ឃុំ ២ស្រុក បន្ទាប់ពីជ្រើសរើសកសិករបានហើយ ចងក្រងបណ្តុំអាជីវមកម្មមាន់ បានចំនួន៦បណ្តុំ មានសមាជិកសរុបចំនួន២៤០គ្រួសារ ក្នុង៧ភូមិ ៣ឃុំ ២ស្រុក បណ្តុំនិមួយៗមានគោលការណ៍លក្ខខន្តិកៈបណ្តុំ រចនាសម្ព័ន្ធដឹកនាំ សម្រាប់សមាជិក និងអ្នកដឹកនាំអនុវត្តន៍ ក្នុងបណ្តុំនិមួយមានអ្នកធ្វើបង្ហាញចំនួនម្នាក់ ព្រមទាំងបញ្ចូលឈ្មោះគ្រួសារអ្នកទទួលផលក្នុងប្រព័ន្ធMISរបស់កម្មវិធី ASPIRE។ ធ្វើការប្រមូលទិន្នដើម និងទិន្នន័យចុងក្រោយចំនួន២៤០គ្រួសារ និងទិន្នន័យសង្ខេប ដើម្បីកំណត់ការវាស់វែងទិន្នន័យ នៃបរិមាណលក់ និងកំណើនប្រាក់ចំណេញរបស់អ្នកទទួលផល (សំណាក១២%នៃគ្រួសារសរុបត្រូវបានជ្រើសរើស សម្រាប់ការវាយតម្លៃ) បានចំនួន២៦គ្រួសារ ស្រី១៤គ្រួសារ។
2. EPDO បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មមាន់ធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ ជាទ្រឹស្តីការអនុវត្តផ្ទាល់ និងបង្វឹកជាប្រចាំបានចំនួន១២វគ្គ(១បណ្តុំ២វគ្គ) ដោយមានអ្នកចូលរួមចំនួន២៤០នាក់/ស្រី១៧០នាក់ និងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ ជួសជុល និងថែទាំទូរភ្ញាស់ ១វគ្គដល់កសិករគំរូចំនួន១២នាក់/ស្រី៦នាក់ ឲ្យមានអនាម័យមាន់ ការអនុវត្តន៍ល្អសម្រាប់សុវត្ថិភាពចំណីអាហារ។
3. EPDO បានរៀបចំគំរូប្លង់ទ្រុងមាន់ជាលក្ខណៈបច្ចេកទេស១សម្រាប់កសិករគំរូទាំង៦ និងសមាជិកយកទៅអនុវត្តន៍ ព្រមទាំងធ្វើការកៀគរធនធានក្នុងការសាងសង់ទ្រុងមាន់ ដោយទ្រុងមាន់និមួយៗមានខ័ណ្ឌដាច់ដោយឡែកពីគ្នា មានកន្លែងដើរ និងដេក ក្នុងទ្រុងនិមួយៗមានស្នូកចំណី ពាងទឹក និងរណ្តៅជីកំប៉ុស្តសម្រាប់មាន់កាយ ។ បានធ្វើការកៀគរធនធាន ដើម្បីកែលម្អរទ្រុងមាន់ដែលមានស្រាប់ឲ្យប្រសើឡើងសម្រាប់ចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្មខ្នាតតូចបានចំនួន៦កសិដ្ឋានគំរូ ។
4. EPDO បានផ្តល់មាន់ពូជចំនួន២៤០ក្បាល និងទូរភ្ញាស់កូនមាន់ចំនួន១០ (សមត្ថភាពដាក់ស៊ុតបាន៣៥២គ្រាប់) សំណាញ់ពទ្ធ័ទ្រុងចំនួន៣០គក្រ ពាងទឹកចំនួន៦០ និងស្នូកដាក់ចំណីចំនួន៦០ និងផ្តល់ចក (Azolla) ជាចំណីមាន់ដែលសំបូរទៅដោយប្រូតេអ៊ីនចំនួន១៨គក្រ ដល់កសិករគំរូចំនួន៦នាក់ ដែលក្នុងម្នាក់ៗទទួលបាន៖ (ទូរភ្ញាស់ពងមាន់១ និងមេ បាពូជមាន់ចំនួន៤០ក្បាល ក្នុងនោះឈ្មោល៦ក្បាល សំណាញ់ចំនួន៥គក្រ ពាងទឹកចំនួន១០ និងស្នូកដាក់ចំណីចំនួន១០ ផ្តល់ចក (Azolla) ៣គក្រ) និងផ្តល់កូនមាន់ដល់សមាជិកបណ្តុំអាជីវកម្មមាន់ចំនួន២៣៤គ្រួសារ សរុបកូនចំនួន២៣៤០ក្បាល ដែលមានអាយុ២១ថ្ងៃឡើងបានធ្វើវ៉ាក់សាំងការពារ៣ដង។
5. ជ្រើសរើសកសិករឆ្នើមដែលមានសមត្ថភាពអាចផ្ទេរចំណេះដឹងដល់កសិករដទៃទៀតបានចំនួន៦គ្រួសារ និងកន្លែងសិក្សារៀនសូត្រ អនុវត្តជាក់ស្តែង និងគាំទ្របច្ចេកទេសរបស់កសិករ ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលពីជំនាញTOT១វគ្គ មានអ្នកចូលរួមចំនួន១២នាក់/ស្រី២នាក់ ដើម្បីឱ្យគាត់ក្លាយជាគ្រូបង្គោលក្នុងបណ្តុំ មានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ល្អៗ បច្ចេកទេស និងភាពជោគជ័យជាមួយសមាជិក និងអ្នកដ៏ទៃទៀត ។ សម្របសម្រួលជាមួយគ្រូបង្គោលផ្តល់ការបណ្តុះបណ្តាល/បង្វឹកផ្ទាល់ទាក់ទងនឹងបច្ចេកទេស ស្តីពីវិធីសាស្រ្តចិញ្ចឹមមាន់ និងចែករំលែកពីការអនុវត្តបានល្អ ដល់សមាជិកបណ្តុំអាជីវកម្មមាន់ចំនួន៦វគ្គ មានអ្នកចូលរួមចំនួន ១៦៤នាក់/ស្រី១៣១នាក់។ រៀបចំទិវាបង្ហាញដើម្បីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីធន់ទ្រាំនឹង

ការប្រែប្រួលអាកាស់ធាតុ បង្ហាញពីលទ្ធផល ចំណុចខ្លាំង ខ្សោយ របស់បណ្តុំ ដែលសំរេចបានក្នុងរយៈពេល៦ ខែកន្លងមក និងជំរុញការលក់កូនមាន់របស់កសិករគំរូទៅសមាជិកបណ្តុំដែលចង់ពង្រីកការចិញ្ចឹមមាន់ដោយមានការបញ្ចុះតម្លៃចំនួន១០% បានចំនួន៦វគ្គ ដោយមានអ្នកចូលរួមចំនួន១៦៨នាក់/ស្រី១៤៤នាក់ ។

6. EPDO ធ្វើការសម្របសម្រួលជាមួយជនបង្គោលទីផ្សារ និងអ្នកដឹកនាំបណ្តុំក្នុងការកំណត់ឈ្មួញសំខាន់ៗនឹងអ្នកទិញចល័តដែលមានសក្តានុពលចំនួន៧នាក់ អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មចំនួន៣កន្លែង សម្រាប់ផលិតកម្មមាន់ ផ្សាភ្ជាប់ទៅនឹងទីផ្សារ។ រៀបចំបង្កើតឲ្យមានទីតាំងលក់មាន់រួមគ្នាចំនួន៦កន្លែង ដើម្បីធានាឲ្យមានតម្លៃសមរម្យមួយអាចទទួលយកបាន។ ផ្តល់វគ្គបណ្តុះបណ្តាលដល់ជនបង្គោលទីផ្សារ និងសមាជិកបណ្តុំអាជីវកម្ម ស្តីពីគោលគំនិតទីផ្សារ ផែនការអាជីវកម្ម និងសៀវភៅកត់ត្រាផលិតកម្មមាន់ផ្អែកលើតំរូវការទីផ្សារ ដោយមានអ្នកចូលរួមចំនួន២១៦នាក់/ស្រី១៤៦នាក់។ បង្កើតឲ្យមានផែនការអាជីវកម្ម និងសៀវភៅកត់ត្រាពីផលិតកម្មរបស់បណ្តុំនមួយៗ។ រៀបចំបណ្តាញទីផ្សារចំនួន១ ដោយមានសមាសភាពជាតំណាងមកពីបណ្តុំទាំង៦ អ្នកប្រមូលទិញ អ្នកលក់ធាតុចូលកសិកម្ម មានសមាជិកសរុបចំនួន១៨នាក់/ស្រី៤នាក់ សម្រាប់ធ្វើការទំនាក់ទំនងគ្នា ចែករំលែកព័ត៌មានទីផ្សារ ។ រៀបចំវេទិកាពហុភាគី (MSP) បានចំនួន៦បណ្តុំដោយមានអ្នកចូលរួមចំនួន១៧៥នាក់/ស្រី១០៧នាក់ វេទិកានេះធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យគ្រប់ភាគីពាក់ព័ន្ធមានឱកាសជួយគាំទ្រដល់ផែនការអាជីវកម្មតាមបណ្តុំនិមួយៗ។ ប្រជុំពិភាក្សាជាមួយតំណាងបណ្តុំ អ្នកប្រមូលទិញមាន់ ដើម្បីបង្កើតកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាទិញ លក់មាន់ បានចុះកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាបានចំនួន៦បណ្តុំរវាងអ្នកប្រមូលទិញ និងសមាជិកបណ្តុំផលិតកម្មមាន់។ បានផលិត និងតម្លើងក្តារព័ត៌មានទីផ្សារចំនួន៦ ដើម្បីកត់ត្រាផលិតកម្មនិងតម្លៃ ដាក់នៅតាមទីតាំងប្រមូលផ្តុំលក់មាន់។

7. ដោយសារតែក្នុងខេត្តពោធិ៍សាត់មិនមានកម្មវិធី AIMs EPDO បានធ្វើការសម្របសម្រួលជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ប្រាសាក់ អេអឹមខេ និងពលរដ្ឋរុងរឿង ដើម្បីឲ្យផ្តល់ប្រាក់កំចីសម្រាប់ពង្រីកមុខរបរផលិតកម្មមាន់ ដោយមានការប្រាក់ទាប ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារមានគោលការណ៍ ការខ្ចីប្រាក់កាន់តែច្រើន ការប្រាក់កាន់តែទាប តែការខ្ចីប្រាក់ត្រូវតែមានដាក់របស់បញ្ចាំទើបអនុញ្ញាតឲ្យខ្ចី។

8. បណ្តុំនិមួយៗមានអាណត្តិប្រជុំជាមួយសមាជិកប្រចាំខែជាទៀងទាត់ ដើម្បីពង្រឹងការអនុវត្តបច្ចេកទេសការចិញ្ចឹមមាន់ ធ្វើការកៀគរធនធានសាងសង់ទ្រុង ពង្រឹងការរៀបចំទ្រុងមាន់ តម្លៃលក់កូនមាន់ និងមាន់សាច់ ការដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការចិញ្ចឹមមាន់ ជំរុញការពង្រីកមុខរបរចិញ្ចឹមមាន់ដើម្បីងាយស្រួលក្នុងការស្វែងរកទីផ្សារ និងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់បណ្តុំ បានចំនួន៣៦លើក(១បណ្តុំ៦លើក) ដោយមានអ្នកចូលរួមចំនួន២១២នាក់/ស្រី១៥៤នាក់។

## ៣.៤ លទ្ធផលរយៈពេលខ្លី:

កសិករគោលដៅចំនួន ២៤០គ្រួសារ ស្រី១៧០បានជ្រើសរើសចូលក្នុងគម្រោង និងរៀបចំជាបណ្តុំអាជីវកម្មមាន់ចំនួន ៦បណ្តុំ ក្នុងបណ្តុំនិមួយៗបានបង្កើតឲ្យមានលក្ខខន្តិកៈ បទបញ្ជាផ្ទៃក្នុង រចនាសម្ពន្ធ័ដឹកនាំ ក្រោយពីទទួលបានការបណ្តុះបណ្តាលមកសមាជិកបណ្តុំចំនួន៨៥% មានការយល់ដឹងបច្ចេកទេសចិញ្ចឹមមាន់ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងទីផ្សារ ព្រមទាំងបានយកចំណេះដឹងទាំងនេះទៅអនុវត្តក្នុងការពង្រឹងមុខរបរចិញ្ចឹមមាន់ ជាពិសេសគឺកសិករគំរូភ្ញាស់កូនមាន់ទាំង៦គ្រួសារ បានធ្វើការកែសម្រួលទ្រុងចិញ្ចឹមមាន់តាមលក្ខណៈបច្ចេកទេស និងស្វែងរកទីផ្សារលក់ផលិតផលរបស់ខ្លួន ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសាររបស់ពួកគេ។

កសិករគំរូចិញ្ចឹមមាន់/ភ្ញាស់កូនមាន់ចំនួន៦គ្រួសារ ទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេស ក្លាយជាគ្រូបង្គោលម្នាក់ ក្នុងការជួយផ្តល់ជាបច្ចេកទេស បទពិសោធន៍នៃការអនុវត្តល្អៗ និងប្រឹក្សាយោបល់ក្នុងការចិញ្ចឹមមាន់ និងទទួលបានពូជមាន់ សម្ភារៈ និងទូរភ្ញាស់ពងមាន់ ក្នុងការពង្រីកមុខរបរចិញ្ចឹមមាន់ ដើម្បីកំណើនប្រាក់ចំណូល របស់ពួកគេផងដែរ ។

សមាជិកបណ្តុំអាជីវកម្មផលិតកម្មមាន់ចំនួន២៣៤គ្រួសារ ទទួលបានកូនមាន់ពូជចំនួន២៣៤០ក្បាល (១គ្រួសារទទួលបាន១០ក្បាល) សម្រាប់យកទៅចិញ្ចឹមតាមលក្ខណៈបច្ចេកទេស ដើម្បីពង្រីកផលិតកម្មមាន់ក្នុងគ្រួសារ មានបណ្តាញទីផ្សារ និងកន្លែងប្រមូលផ្តុំទិញ លក់មាន់ ការផ្លាស់ប្តូរពូជ ការសិក្សាពីតម្លៃក្នុងការលក់ សម្រាប់ទំនាក់ទំនង និងចែករំលែកព័ត៌មានទីផ្សារមាន់ ការចរចារពីតម្លៃទិញ-លក់មាន់ ការលក់ធាតុចូលកសិកម្ម(សំភារៈ ចំណី) ដើម្បីពង្រីកផលិតកម្មមាន់ស្របតាមតម្រូវការទីផ្សារ និងបានចុះកិច្ចព្រមព្រៀងក្នុងការលក់មាន់ជាមួយឈ្មួញក្នុងស្រុក ដោយទទួលបានតម្លៃសមរម្យ។

ផលិតកម្មមាន់មានការកើនឡើង តាមរយៈការបញ្ជាទិញកាន់តែទូលំទូលាយ និងជាពិសេសការសហការក្នុងការផ្គត់ផ្គង់ពីបណ្តាញទីផ្សារមាន់ ដែលមានបណ្តុំជាច្រើនចូលរួមគ្នាបានផ្គត់ផ្គង់មានតាមតម្រូវការបញ្ជាទិញពីឈ្មួញ ឬអតិថិជនតាមការកំណត់។

អ្នកដឹកនាំបណ្តុំទទួលបានការបណ្តុះបណ្តាលបន្ថែម ពីការប្រើប្រាស់បណ្តាញសង្គមហ្វេសបុក ហ្វេសប៊ុកផេក តេឡេក្រាម មានក្រុមពិភាក្សាពីការចិញ្ចឹមមាន់ ដែលអាចជួយប្រឹក្សាបានភ្លាមៗនៅពេលការចិញ្ចឹមមាន់ជួបបញ្ហាណាមួយ និងសម្រាប់ការធ្វើទីផ្សារបែបថ្មី។

## ៣.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង

កសិករចិញ្ចឹមមាន់គំរូចំនួន៦កន្លែង បានផ្លាស់ប្តូរពីការចិញ្ចឹមមាន់បែបលក្ខណៈគ្រួសារ មកជាការចិញ្ចឹមលក្ខណៈកសិដ្ឋានខ្នាតតូចតាមបច្ចេកទេសដោយប្រើប្រាស់ឧបករណ៍ទំនើបដូចជា ការរៀបចំទ្រុងតាមស្តង់ដារបច្ចេកទេស ការប្រើទូរដើម្បីភ្ញាស់ពងមាន់ ការប្រើម៉ាស៊ីនកិនចំណីសត្វ ការធ្វើវ៉ាក់សាំងការពារ និងថ្នាំព្យាបាលជម្ងឺមាន់ ការលាយចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់សំរាប់មេបា និងកូនមាន់ ការថែទាំកូនមាន់ និងការដាំរុក្ខជាតិសំរាប់ធ្វើចំណីមាន់ ដូចជា ចក អាសូឡា ផ្លែក្រខប់ជាដើម និងលក់កូនមាន់ជាលក្ខណៈធ្វើកិច្ចសន្យាទិញលក់រវាងអ្នកប្រមូលទិញ និងក្រុមផលិត ។

សមាជិកបណ្តុំចិញ្ចឹមមាន់ចំនួន២០៤គ្រួសារក្នុង៦បណ្តុំ ពួកគាត់បានអនុវត្តន៍ការចិញ្ចឹមមាន់តាមការណែនាំរបស់គម្រោង(ដូចជាការសាងសង់ទ្រុងមេបា ទ្រុងមាន់សាច់ និងទ្រុងបំបែកកូនក្រោយពេលញាស់ ព័ទ្ធសំណាញ់តាមបច្ចេកទេស និងធ្វើវ៉ាក់សាំងមាន់) ព្រមទាំងមានជីវសុវត្ថិភាពបានត្រឹមត្រូវ និងមានលក់ពងមាន់ កូនមាន់ព្រមទាំងមាន់សាច់ជារៀងរាល់ខែ។

ដោយមើលឃើញភាពរីកចម្រើនរបស់កសិករគំរូក្នុងការភ្ញាស់កូនមាន់លក់ សមាជិកបណ្តុំអាជីវកម្មចិញ្ចឹមមាន់ចំនួន២គ្រួសារ បានចម្លងតាមដោយទិញទូរភ្ញាស់ពងមាន់វីដោយដៃ មកអនុវត្តក្នុងការភ្ញាស់ដើម្បីបង្កើនផលិតកម្មរបស់ខ្លួន ហើយក្នុងនោះផងដែរ មានសមាជិកបណ្តុំចំនួន២នាក់បានចេះតម្លើងទូរភ្ញាស់ពងមាន់វីដោយដៃសម្រាប់លក់ជូនសមាជិកបណ្តុំ និងអ្នកក្រៅបណ្តុំទៀតផង។ សមាជិកបណ្តុំអជីវកម្មចិញ្ចឹមមានចំនួន៥គ្រួសារ បានទិញម៉ាស៊ីនកែឆ្នៃចំណីផ្សំទៅជាចំណីគ្រាប់ សម្រាប់កូនមាន់ មេ បា និងលក់ជូនសមាជិកបណ្តុំ។ ការចិញ្ចឹមមាន់ស្របតាមតម្រូវការរបស់ទីផ្សារ ទទួលបានតម្លៃខ្ពស់សមរម្យ ព្រមទាំងបានចុះកិច្ចសន្យាជាមួយអ្នកទិញទៀតផង។

# ៣.៦.និរន្តរភាពនៃគម្រោង

ដើម្បីធានានូវនិរន្តរភាព EPDO បានធ្វើការសម្របសម្រួល និងបង្កើតជាបណ្តុំអាជីវកម្ម ព្រមទាំងធ្វើការពង្រឹងសមត្ថភាពដល់សមាជិកបណ្តុំ អ្នកដឹកនាំបណ្តុំ ដើម្បីឲ្យពួកគាត់មានសមត្ថភាពរឹងមាំក្នុងការគ្រប់គ្រង ចាត់ចែងនូវធនធាន និងសមិទ្ធិផលដែលបានគាំទ្រ ដូចជាសម្ភារៈ ពូជមាន់ និងចំណេះដឹង មិនតែប៉ុណ្ណោះពួកគាត់មានផែនការក្នុងការពង្រីកមុខរបរចិញ្ចឹមមាន់ មានការទំនាក់ទំនងជាមួយឈ្មួញបានល្អ លក់បានតម្លៃសមរម្យ ព្រមទាំងមានការគាំទ្រលើកទឹកចិត្តពីអាជ្ញាធរ កសិកម្មស្រុក ខេត្ត អង្គការ វិស័យឯកជន ពួកគាត់បានចូលរួមតាំងពីចាប់ផ្តើមរហូតមកក្នុងអំឡុងពេលនៃការអនុវត្តគម្រោង បានធ្វើឲ្យពួកគាត់មានការផ្លាស់ប្តូរឥរិយាបទ ពីការចិញ្ចឹមមាន់តាមទំលាប់ មកអនុវត្តន៍តាមលក្ខណៈបច្ចេកទេស។ តាមរយៈនៃការចុះតាមដាន និងការបង្វឹកជាប្រចាំ យើងសង្កេតឃើញថា សមាជិកបណ្តុំ និងអ្នកដឹកនាំបណ្តុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រកបមុខរបរចិញ្ចឹមមាន់ ដោយគាត់បានចុះកិច្ចសន្យាជាមួយ ឈ្មួញកណ្តាល មានតម្លៃសមរម្យ មានបណ្តាញទីផ្សារក្នុងការទំនាក់ទំនងគ្នា មានកន្លែងក្នុងការប្រមូលផ្តុំកល់មាន់រួមគ្នា យើងសង្ឃឹមថា អនាគត សមាជិកទាំងនោះនៅតែបន្ត និងពង្រីកមុខរបរចិញ្ចឹមមាន់ជារៀងរហូត ដោយសារងាយស្រួលរកទីផ្សារលក់ និងមានការជួយគាំទ្រពីអ្នកពាក់ព័ន្ធ ជាពិសេសគឺមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។

# ៤. គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ខេត្តបាត់ដំបង

**គាំទ្រថវិកាដោយ**

## ៤.១ សេចក្តីផ្តើម

របាយការណ៍ស្តីពីការអនុវត្តគម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ ក្នុងខេត្តបាត់ដំបង គឺបានអនុវត្តន៍ជាមួយបណ្តុំអាជីវកម្មក្នុងភូមិចំនួន៩ ក្នុង៥ឃុំ ២ស្រុក ៩ភូមិ ដែលមានបណ្តុំផលិតកម្មមាន់ចំនួន១០ (ភូមិសួស្តី ស្តីស្ទឹង ប្រឡាយស្តៅ ត្រស់ ឃុំតាលាស់ និងភូមិឬស្សីមួយ កោះចារ ឃុំមោង និងភូមិកោះថ្កូវ ឃុំគារ ស្រុកមោងឫស្សី ភូមិឆ្កែខាំប្រើស ឃុំព្រៃកជីក ភូមិព្រៃខ្លូត ឃុំព្រៃត្រឡាច ស្រុករុក្ខគីរី ខេត្តបាត់ដំបង) បញ្ជាក់:ភូមិព្រៃខ្លូតមាន២បណ្តុំ។ គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដល់កសិករគំរូផលិតកម្មចិញ្ចឹមមាន់ និងសមាជិកបណ្តុំផលិតមាន់ និងការផ្សាភ្ជាប់ខ្សែច្រវ៉ាក់ផលិតកម្មទីផ្សារ។

គម្រោងនេះមានរយៈពេល៧ខែ គិតចាប់ពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ទទួលបានការគាំទ្រថវិកាពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង។

តំបន់ដែលបានជ្រើសរើសទាំងនេះជាតំបន់ដែលមានសក្តានុពលសម្រាប់ការផលិតកម្មមាន់។

## ៤.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| លរ | ឈ្មោះក្រុម | ឈ្មោះភូមិ | ឃុំ | ស្រុក | ខេត្ត | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|
| | | | | | | សរុប | ស្រី |
| 1 | ក្រុមបណ្តុំអាជីវកម្មមាន់សួស្តី | សួស្តី | តាលាស់ | មោងឫស្សី | បាត់ដំបង | ២១ | ១២ |
| 2 | ក្រុមបណ្តុំអាជីវកម្មមាន់ត្រស់ | ត្រស់ | តាលាស់ | មោងឫស្សី | បាត់ដំបង | ២១ | ១៥ |
| 3 | ក្រុមបណ្តុំអាជីវកម្មមាន់ស្តីស្ទឹង | ស្តីស្ទឹង | តាលាស់ | មោងឫស្សី | បាត់ដំបង | ២១ | ១៤ |
| 4 | ក្រុមបណ្តុំអាជីវកម្មមាន់ប្រឡាយស្តៅ | ប្រឡាយស្តៅ | តាលាស់ | មោងឫស្សី | បាត់ដំបង | ២១ | ១១ |
| 5 | ក្រុមបណ្តុំអាជីវកម្មមាន់កោះថ្កូវ | កោះថ្កូវ | គារ | មោងឫស្សី | បាត់ដំបង | ២១ | ៩ |
| 6 | ក្រុមបណ្តុំអាជីវកម្មមាន់កោះចារ | កោះចារ | មោង | មោងឫស្សី | បាត់ដំបង | ២១ | ៩ |
| 7 | ក្រុមបណ្តុំអាជីវកម្មមាន់ឬស្សីមួយ | ឬស្សីមួយ | មោង | មោងឫស្សី | បាត់ដំបង | ២១ | ១២ |
| 8 | ក្រុមបណ្តុំអាជីវកម្មមាន់ឆ្កែខាំប្រើស | ឆ្កែខាំប្រើស | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ២១ | ៧ |
| 9 | ក្រុមបណ្តុំអាជីវកម្មមាន់ព្រៃខ្លូត១ | ព្រៃខ្លូត | ព្រៃត្រឡាច | រុក្ខគីរី | បាត់ដំបង | ២១ | ៧ |
| 10 | ក្រុមបណ្តុំអាជីវកម្មមាន់ព្រៃខ្លូត២ | ព្រៃខ្លូត | ព្រៃត្រឡាច | រុក្ខគីរី | បាត់ដំបង | ២១ | ៥ |
| | ១០ | ៩ | ៥ | ២ | ១ | ២១០ | ១០១ |

**គោលបំណងគម្រោង៖** ដើម្បីបង្កើនសមត្ថភាពដល់សមាជិកបណ្តុំអាជីវកម្មមាន់ នៅក្នុងភូមិចំនួន៩ ឃុំចំនួន៥ និង២ស្រុក នៃខេត្តបាត់ដំបង ដែលមានសមាជិកសរុប ២១០គ្រួសារ។

## ៤.៣ លទ្ធផលសម្រេចបាន៖

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងលទ្ធផលរបស់គម្រោងបង្កើតបណ្តុំអាជីវកម្មមាន់ស្រែ និងមាន់ក្នុងខេត្តបាត់ដំបង EPDO បានអនុវត្តសកម្មភាពមួយចំនួន ដែលទទួលបានលទ្ធផលដូចខាងក្រោម៖

1. ដើម្បីឆ្លើយតបទៅនគោលបំណង និងលទ្ធផលគម្រោង EPDO បានរៀបចំឯកសារទស្សនៈទានសម្រាប់អនុវត្តន៍គម្រោងមាន ផែនការសកម្មភាព វិធីសាស្រ្តអនុវត្តគម្រោង វិធីសាស្រ្តជ្រើសរើសតំបន់គោលដៅ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកទទួលផល ដែលមានសក្តានុពលក្លាយជាកសិដ្ឋានចិញ្ចឹមមាន់ និងចិញ្ចឹមមាន់ជាលក្ខណៈអាជីវកម្ម។ ធ្វើការប្រមូលទិន្នដើម និងទិន្នន័យចុងក្រោយចំនួន៥០៥គ្រួសារ និងទិន្នន័យសង្ខេប ដើម្បីកំណត់ការវាស់វែងទិន្នន័យ នៃបរិមាណលក់ និងកំណើនប្រាក់ចំណេញរបស់អ្នកទទួលផល (សំណាក១២%នៃគ្រួសារសរុបត្រូវបានជ្រើសរើស សម្រាប់ការវាយតម្លៃ)បានចំនួន៦០គ្រួសារ ស្រី២៦គ្រួសារ។
2. EPDO បានប្រជុំផ្សព្វផ្សាយពីសកម្មភាពគម្រោងចិញ្ចឹមមាន់ និងចិញ្ចឹមមាន់ដល់កសិករទូទៅក្នុងភូមិ និងជ្រើសរើសអ្នកទទួលផលគម្រោងក្នុងតំបន់គោលដៅចំនួន៩ភូមិ ៥ឃុំ ២ស្រុក បន្ទាប់ពីជ្រើសរើសកសិករបានហើយ ចងក្រងបណ្តុំបណ្តុំអាជីវមកម្មមាន់ និងមាន់បានចំនួន១០បណ្តុំ មានសមាជិកសរុបចំនួន៥០៥គ្រួសារក្នុង៩ភូមិ ៥ឃុំ ២ស្រុក បណ្តុំនិមួយៗមានគោលការណ៍ លក្ខខន្តិកៈបណ្តុំ រចនាសម្ព័ន្ធដឹកនាំ សម្រាប់សមាជិក និងអ្នកដឹកនាំអនុវត្តន៍ ក្នុងបណ្តុំនិមួយមានអ្នកធ្វើបង្ហាញចំនួនម្នាក់ ព្រមទាំងបញ្ចូលឈ្មោះគ្រួសារអ្នកទទួលផលក្នុងប្រពន្ធ័MISរបស់កម្មវិធី ASPIRE។
3. EPDO បានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតកម្មមាន់បានចំនួន១០វគ្គ ដោយមានអ្នកចូលរួមចំនួន៤២៧នាក់/ស្រី២០៩គ្រួសារ និងផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលមួយថ្ងៃស្តីពីការជួសជុល និងថែទាំទូរភ្ញាស់ដល់កសិករគំរូចំនួន១២នាក់ ស្រី៤នាក់ក្នុងនោះមានអ្នកលក់សំភារៈកសិកម្ម២នាក់។ វគ្គបណ្តុះបណ្តាលចំនួន១១វគ្គបានបញ្ជូនទៅឲ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដាក់បញ្ចូលក្នុងប្រពន្ធ័ MIS របស់កម្មវិធី ASPIRE។ បានដឹកនាំកសិករដែលមានសក្តានុពលសម្រាប់ការចិញ្ចឹមមាន់ មានសមត្ថភាពអាចយកចំណេះដឹងមកផ្សព្វផ្សាយបន្តដល់អ្នកភូមិបាន ទៅទស្សនៈកិច្ចសិក្សារៀនសូត្របទពិសោធន៍នៅខេត្តពោធិ៍សាត់បាន១លើកមានចំនួន២០គ្រួសារ ស្រី៥គ្រួសារ។
4. EPDO បានផ្តល់មាន់ពូជចំនួន៧៦៥ក្បាល និងទូរភ្ញាស់កូនមាន់ចំនួន១០ (សមត្ថភាពដាក់ស៊ុតបាន៣៥២គ្រាប់) ដល់កសិករគំរូចំនួន១០នាក់ (ទូរភ្ញាស់ពងមាន់១ និងមេ បាពូជមាន់ចំនួន៧៦ក្បាល ក្នុងនោះឈ្មោល១០ក្បាល) បានបង្កើតលក្ខណៈវិនិច្ឆ័យ និងបញ្ចីឈ្មោះអ្នកទទួលបានការគាំទ្រពូជមាន់ ដោយយើងកំណត់អ្នកដែលចូលរួមរៀនបច្ចេកទេស ចិញ្ចឹមមាន់ជាប្រចាំ និងផ្តល់ការគាំទ្រកូនមាន់ពូជដល់សមាជិកបណ្តុំចិញ្ចឹមមាន់បានបណ្តុំ មានសមាជិកចំនួន២០០គ្រួសារ សរុបកូនមាន់ចំនួន៣២០០ក្បាល (១៦ក្បាលក្នុង១គ្រួសារ) បន្ទាប់ពីទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេស។
5. បណ្តាញទីផ្សារមាន់១ត្រូវបានរៀបចំនៅក្នុងស្រុកមោងឫស្សី និងស្រុករុក្ខគីរី ដែលមានសមាជិកចំនួន១៣នាក់ ស្រី៤នាក់ មកពីតំណាងបណ្តុំចំនួន១០បណ្តុំ និងអ្នកទិញមាន់១គ្រួសារ អ្នកលក់ធាតុចូលចំនួន២នាក់។

ប្រជុំពិភាក្សាជាមួយបណ្តុំអាជីវកម្មមាន់ទាំង១០បណ្តុំ បានចំនួន១០លើកដែលមានអ្នកចូលរួមសរុបចំនួន ៥០០គ្រួសារ ស្រី៣០៦នាក់ ដើម្បីរៀបចំផែនការក្នុងការផលិតកូនមាន់ និងមាន់សាច់សម្រាប់ផ្គត់ផ្គង់ជូនអតិជន និងឈ្មួញកណ្តាលក្នុងស្រុក។ បានប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយសមាជិកបណ្តុំអាជីវកម្មមាន់ចំនួន១០ ដោយមានអ្នកចូលរួមសរុបចំនួនសរុប ១៩៨នាក់ ស្រី១២៩នាក់ ឈ្មួញ ៣នាក់ ស្រី២នាក់ និងប្រជុំពិភាក្សាជាមួយតំណាងបណ្តុំ អ្នកប្រមូលទិញមាន់ ដោយមានអ្នកចូលរួមចំនួន២៣នាក់ ស្រី៨នាក់ ដើម្បីបង្កើតកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាទិញ លក់មាន់។ បានចុះកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាបាន១០បណ្តុំ រវាងអ្នកទិញមាន់សាច់ និងកូនមាន់បានចំនួន១០ ក្នុង១០បណ្តុំបណ្តុំអាជីវកម្មមាន់។

6. EPDO បានសម្របសម្រួលកិច្ចប្រជុំបណ្តុំប្រចាំខែ ជាមួយសមាជិកបណ្តុំអាជីវកម្មបន្លែបានចំនួន១០បណ្តុំ ក្នុង១បណ្តុំ៧លើក ដោយមានអ្នកចូលរួមចំនួន ៤៨៣នាក់/ស្រី២៩១នាក់ ដើម្បីពង្រឹងការអនុវត្តលក្ខន្តិកៈ ព័ត៌មានតម្លៃលក់មាន់ប្រចាំថ្ងៃ ទីតាំងទីផ្សារត្រូវលក់ បញ្ហាកំពុងជួបប្រទះ ដំណោះស្រាយ និងចិញ្ចឹមមាន់របស់ពួកគេដោយប្រើជំនាញចិញ្ចឹមមាន់ និងចិញ្ចឹមមាន់ក្នុងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធនទៅនឹងការប្រែប្រួលអាកាសធាតុ យើងពិនិត្យមើលការអនុវត្តបច្ចេកទេសរបស់សមាជិកបណ្តុំ និងប្រាប់បន្ថែមនៅចំណុចខ្វះខាតដែលគាត់មិនបានអនុវត្តន៍ ព្រមទាំងរំលឹកឡើងវិញពីអ្វីដែលគាត់បានរៀនពីមុន។
7. តាមរយៈលទ្ធផលនៃការប្រមូលទិន្នន័យលើការស្ទង់មតិនេះ គ្រួសារដែលបានសម្ភាសន៍ទាំងអស់កំពុងចិញ្ចឹមមាន់ស្រុក មានចំនួន៦០គ្រួសារ ស្រី៤៣គ្រួសារ ក្នុង១០បណ្តុំ។ ចំពោះវិធីសាស្រ្តនៃការគណនាប្រាក់ចំណូលទម្រង់វិភាគនៃប្រាក់ចំណូល និងចំណាយគឺត្រូវបញ្ចូលទៅក្នុងទំរង់ Microsoft Excel ហើយបន្ទាប់មកគ្រាន់តែវិភាគចំនួននោះគឺការគណនា តម្លៃផលិតកម្មមាន់សម្រាប់គ្រួសារដែលបានសម្ភាសន៍ម្នាក់ៗត្រូវបានគណនាថាជាប្រាក់ចំណូលសុទ្ធបន្ទាប់ពីកាត់ការចំណាយលើចិញ្ចឹមមាន់ដូចខាងក្រោម។
   - មុនពេលអនុវត្តន៍គម្រោងគាត់ចិញ្ចឹមមាន់លក់បានចំនួន $90.58 គាត់ចំណាយដើមទុនអស់ $56.46 គិតជាមធ្យមគាត់លក់ចំណេញបានបានលុយចំនួន $35.88 ។ បន្ទាប់ពីចូលរួមក្នុងកម្មវិធីគាត់ចិញ្ចឹមមាន់លក់បានចំនួន $150.47 គាត់ចំណាយដើមទុនអស់ចំនួន $67.90 គិតជាមធ្យមគិតជាមធ្យមគាត់លក់បានលុយចំនួន $82.56។ ចំនួននៃការប្រែប្រួលនៃទំហំលក់ផលិត កម្មកើនឡើង $59.88 និងកំណើនប្រាក់ចំណេញជាធម្យមភាគចំនួន$82.56ក្នុង១គ្រួសារៗ។

# ៤.៤. លទ្ធផលរយៈពេលខ្លី

1. បណ្តុំអាជីវកម្មមាន់ចំនួន១០បណ្តុំមានសមាជិកចំនួន៥០៥គ្រួសារ ស្រី៣២៩គ្រួសារទទួលបានវគ្គបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមមាន់ ចិញ្ចឹមសត្វ និងទីផ្សារ។ បន្ទាប់ពីទទួលការបណ្តុះបណ្តាលមកសមាជិកបណ្តុំចំនួន៨០% មានការយល់ដឹងបច្ចេកទេសចិញ្ចឹមមាន់ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងទីផ្សារ ព្រមទាំងអាចយកចំណេះដឹងទាំងនេះមកប្រើប្រាស់ក្នុងការពង្រឹងមុខរបរ និងស្វែងរកទីផ្សារលក់ផលិតផលរបស់ខ្លួនបានប្រសើរជាងមុន។
2. សមាជិកបណ្តុំអាជីវកម្មផលិតកម្មមាន់ចំនួន២០០គ្រួសារ ទទួលបានកូនមាន់ពូជចំនួន៣២០០ក្បាល (១គ្រួសារទទួលបាន១៦ក្បាល) សម្រាប់យកទៅចិញ្ចឹម ដើម្បីពង្រីកផលិតកម្មមាន់ក្នុងសហគមន៍ ងាយស្រួលក្នុងការស្វែងរកទីផ្សារ។

3. កសិករគំរូចំនួន១០គ្រួសារ ទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេស ពូជមាន់ សម្ភារៈ និងទូរភ្ញាស់ពងមាន់ រហូតមកទល់អំឡុងពេលនេះកសិករគំរូទាំង១០នាក់ បានអនុវត្តបច្ចេកទេសភ្ញាស់កូនមាន់ និងបានលក់ចេញកូនមាន់ចែកជូនទៅសមាជិក និងទីផ្សារកូនមាន់ ក្នុងចំណោមកសិករគំរូទាំង១០នាក់ និងសមាជិករបស់ពួកគេចំនួន២០០គ្រួសារ ពួកគាត់បានពង្រីកទីផ្សារលក់មាន់ជាក្រុម តាមរយៈការផ្សព្វផ្សាយ ហ្វេសបុក តេលេក្រាម និងភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយឈ្មួញក្នុងមូលដ្ឋាន ស្រុក ខេត្ត តាមរយៈទូរស័ព្ទ រហូតមកទល់ពេលនេះក្រុមបណ្តុំអាជីវកម្មទាំងអស់មានទីផសាតទូលាយ អាចរកជម្រើសក្នុងការលក់មាន់ប្រសើរជាងមុន ព្រមទាំងបានចុះកិច្ចព្រមព្រៀងលក់មាន់ចំនួន១០បណ្តុំ ជាមួយឈ្មួញក្នុងស្រុក ដោយមានតម្លៃសមរម្យ។

# ៤.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង

ក្រោយពីបានចូលរួមក្នុងគម្រោងកន្លងមក ក្រុមបណ្តុំអាជីវកម្មមាន់ មានការសាមគ្គី ចេះចែករំលែកព័ត៌មានពាក់ព័ន្ធបច្ចេកទេសថ្មីដែលធននឹងអាកាសធាតុ ចែករំលែកព័ត៌មានទីផ្សារ ការជ្រើសរើសអ្នកផ្គត់ផ្គង់ថាតុចូលកសិកម្ម ការទំនាក់ទំនងជាមួយ អាជ្ញាធរ ស្ថាប័នជំនាញ និងវិស័យឯកជនបានល្អប្រសើរជាងមុន។

ការកើនឡើងនូវចំណេះជំនាញ បច្ចេកទេសក្នុងការចិញ្ចឹមមាន់ តាមរយៈការបណ្តុះបណ្តាល បង្វឹកពីអ្នកជំនាញ រៀនសូត្រតាមរយៈការទៅទស្សនាដោយផ្ទាល់របស់អ្នកផលិតដែលទទួលជោគជ័យ និងបានយកមេរៀន រៀនសូត្រមកអនុវត្ត និងកែទម្រង់ អភិវឌ្ឍន៍ការចិញ្ចឹមមាន់ស្របតាមស្ថានភាពអាកាសធាតុ ដើម្បីបង្កើនចំណូលក្នុងគ្រួសារ និងសហគមន៍។

សមាជិកបណ្តុំអាជីវកម្មមាន់ មានការកើនឡើងនូវធនធាន សំភារៈ ថវិកា តាមរយៈផលិតកម្មចិញ្ចឹមមាន់ ដែលធននឹងការប្រែប្រួលអាកាសធាតុ តាមរយៈនៃការសង្កេត និងការតាមដានត្រួតពិនិត្យ បានបង្ហាញថា ពួកគាត់នៅតែបន្តសកម្មភាពចិញ្ចឹមមាន់ ព្រោះជាការងារបន្ថែមសម្រាប់ការងារផ្ទះ និងទទួលបានប្រាក់ចំណូលដើម្បីដោះស្រាយជីវភាព និងពង្រីកធនធានដើម្បីអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ។

# ៤.៦. និរន្តរភាពនៃគម្រោង

ដើម្បីធានានូវនិរន្តរភាព EPDO បានធ្វើការសម្របសម្រួល និងបង្កើតជាបណ្តុំអាជីវកម្ម ព្រមទាំងធ្វើការពង្រឹងសមត្ថភាពដល់សមាជិកបណ្តុំ អ្នកដឹកនាំបណ្តុំ ដើម្បីឲ្យពួកគាត់មានសមត្ថភាពរឹងមាំក្នុងការគ្រប់គ្រង ចាត់ចែងនូវធនធាន និងសមិទ្ធិផលដែលបានគាំទ្រ ដូចជាសម្ភារៈពូជមាន់ និងចំណេះដឹង មិនតែប៉ុណ្ណោះពួកគាត់មានផែនការក្នុងការពង្រីកមុខរបរចិញ្ចឹមមាន់ មានការទំនាក់ទំនងជាមួយឈ្មួញបានល្អ លក់បានតម្លៃសមរម្យ ព្រមទាំងមានការគាំទ្រលើកទឹកចិត្តពីអាជ្ញាធរ កសិកម្មស្រុក ខេត្ត អង្គការ វិស័យឯកជន ពួកគាត់បានចូលរួមតាំងពីចាប់ផ្តើមរហូតមកក្នុងអំឡុងពេលនៃការអនុវត្តគម្រោង បានធ្វើឲ្យពួកគាត់មានការផ្លាស់ប្តូរឥរិយាបទ ពីការចិញ្ចឹមមាន់តាមទំលាប់ មកអនុវត្តន៍តាមលក្ខណៈបច្ចេកទេស។ តាមរយៈនៃការចុះតាមដាន និងការបង្វឹកជាប្រចាំ យើងសង្កេតឃើញថា សមាជិកបណ្តុំ និងអ្នកដឹកនាំបណ្តុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រកបមុខរបរចិញ្ចឹមមាន់ ដោយគាត់បានចុះកិច្ចសន្យាជាមួយ ឈ្មួញកណ្តាល មានតម្លៃសមរម្យ មានបណ្តាញទីផ្សារក្នុងការទំនាក់ទំនងគ្នា មានកន្លែងក្នុងការប្រមូលផ្តុំកលស់មាន់ យើងសង្ឃឹមថា អនាគត សមាជិកទាំងនោះនៅតែបន្ត និងពង្រីកមុខរបរចិញ្ចឹមមាន់ជារៀងរហូត ដោយសារងាយស្រួលរកទីផ្សារលក់ និងមានការជួយគាំទ្រពីអ្នកពាក់ព័ន្ធ ជាពិសេសគឺមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

# ៥. គម្រោងបង្កើតបណ្តុំអាជីវកម្មបន្លែ ខេត្តបាត់ដំបង

**គាំទ្រថវិកាដោយ**

## ៥.១ សេចក្តីផ្តើម:

របាយការណ៍នេះ បានលើកឡើងពីវឌ្ឍន៍ភាពនៃការអនុវត្ត **គម្រោងបង្កើតបណ្តុំអាជីវកម្មបន្លែ** ក្នុងខេត្តបាត់ដំបង គឺបានអនុវត្តន៍ជាមួយបណ្តុំផលិតក្នុងភូមិចំនួន៩ ក្នុង២ឃុំ ២ស្រុក ដែលមានបណ្តុំផលិតកម្មបន្លែចំនួន១០ (ភូមិរបស់មង្គល ព្រះធាតុ អន្លង់គូប ក្នុងឃុំរបស់មង្គល ស្រុកមោងឫស្សី ភូមិសៀម ឆ្កែខាំប្រើស ថ្មំ ថ្នួយ បឹងអំពិល និងភូមិខ្នាចអំព័រក្នុងឃុំព្រៃកជីក ស្រុករុក្ខគីរី) បញ្ជាក់ៈភូមិថ្មំមាន២បណ្តុំ។ គម្រោងមានគោលបំណងដើម្បីបង្កើនសមត្ថភាពដល់កសិដ្ឋានផលិតកម្មដាំបន្លែ និងសមាជិកបណ្តុំអាជីវកម្មបន្លែ និងការផ្សាភ្ជាប់ខ្សែច្រវ៉ាក់ផលិតកម្មទីផ្សារ។

គម្រោងនេះមានរយៈពេល៧ខែ គិតចាប់ពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ទទួលបានការគាំទ្រថវិកាពី កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង។

តំបន់ដែលបានជ្រើសរើសទាំងនេះជាតំបន់ដែលមានសក្តានុពលសម្រាប់ការផលិតកម្មបន្លែ

## ៥.២ តំបន់គោលដៅ និងអ្នកចូលរួមជាមួយគម្រោង

| No | ឈ្មោះក្រុម | ឈ្មោះភូមិ | ឃុំ | ស្រុក | ខេត្ត | អ្នកទទួលផល | |
|---|---|---|---|---|---|---|---|
| | | | | | | សរុប | ស្រី |
| 1 | ក្រុមបណ្តុំអាជីវកម្មអន្លងគូប | អន្លងគូប | របស់មង្គល | មោងឫស្សី | បាត់ដំបង | ២១ | ២១ |
| 2 | ក្រុមបណ្តុំអាជីវកម្មព្រះធាតុ | ព្រះធាតុ | របស់មង្គល | មោងឫស្សី | បាត់ដំបង | ២១ | ១៥ |
| 3 | ក្រុមបណ្តុំអាជីវកម្មរបោះមង្គល | របស់មង្គល | របស់មង្គល | មោងឫស្សី | បាត់ដំបង | ២០ | ១៣ |
| 4 | ក្រុមបណ្តុំអាជីវកម្មថ្មំទី១ | ថ្មំ១ | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ២១ | ២១ |
| 5 | ក្រុមបណ្តុំអាជីវកម្មថ្មំទី២ | ថ្មំ២ | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ១៨ | ១៤ |
| 6 | ក្រុមបណ្តុំអាជីវកម្មសៀម | សៀម | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ១៩ | ១៤ |
| 7 | ក្រុមបណ្តុំអាជីវកម្មឆ្កែខាំប្រើស | ឆ្កែខាំប្រើស | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ១៩ | ១០ |
| 8 | ក្រុមបណ្តុំអាជីវកម្មបឹងអំពិល | បឹងអំពិល | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ២១ | ២១ |
| 9 | ក្រុមបណ្តុំអាជីវកម្មខ្នាចអំពរ | ខ្នាចអំពរ | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ២០ | ២០ |
| 10 | ក្រុមបណ្តុំអាជីវកម្មបឹងថ្នួយ | បឹងថ្នួយ | ព្រៃកជីក | រុក្ខគីរី | បាត់ដំបង | ២០ | ៧ |
| | ១០ | ៩ | ២ | ២ | ១ | ២០០ | ១៥៦ |

**គោលបំណង:** ដើម្បីបង្កើនសមត្ថភាពដល់ សមាជិកបណ្តុំអាជីវកម្មបន្លែ នៅក្នុងភូមិចំនួន៩ ឃុំចំនួន២ និងស្រុកចំនួន ២ នៃខេត្តបាត់ដំបង ដែលមានសមាជិកសរុប២០០គ្រួសារ។

## ៥.៣ លទ្ធផលសម្រេចបាន:

ដើម្បីឆ្លើយតបទៅនឹងគោលបំណង និងលទ្ធផលរបស់គម្រោងបង្កើតបណ្តុំអាជីវកម្មបន្លែ ក្នុងខេត្តបាត់ដំបង EPDO បានអនុវត្តសកម្មភាពមួយចំនួន ទទួលបានលទ្ធផលដូចខាងក្រោម៖

8. EPDO បានរៀបចំឯកសារទស្សនៈទានសម្រាប់អនុវត្តន៍គម្រោងមាន ផែនការសកម្មភាព វិធីសាស្រ្តអនុវត្តគម្រោង វិធីសាស្រ្តជ្រើសរើសតំបន់គោលដៅ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកទទួលផល ដែលមានសក្តានុពលក្លាយជាកសិករផលិតបន្លែជាលក្ខណៈអាជីវកម្ម។ ធ្វើការប្រមូលទិន្នន័យដើម និងទិន្នន័យចុងក្រោយចំនួន៥០០គ្រួសារ និងទិន្នន័យសង្ខេប ដើម្បីកំណត់ការវាស់វែងទិន្នន័យ នៃបរិមាណលក់ និងកំណើនប្រាក់ចំណេញរបស់អ្នកទទួលផល (សំណាក១២%នៃគ្រួសារសរុបត្រូវបានជ្រើសរើស សម្រាប់ការវាយតម្លៃ) បានចំនួន៦០គ្រួសារ ស្រី៤៦គ្រួសារ។
9. EPDO បានប្រជុំផ្សព្វផ្សាយពីសកម្មភាពគម្រោង ដាំបន្លែដល់កសិករទូទៅក្នុងភូមិ និងជ្រើសរើសអ្នកទទួលផលគម្រោងក្នុងតំបន់គោលដៅចំនួន៩ភូមិ ក្នុង២ឃុំ ២ស្រុក បន្ទាប់ពីជ្រើសរើសកសិករបានហើយ ចងក្រងបណ្តុំអាជីវមកម្មបន្លែ បានចំនួន១០បណ្តុំ មានសមាជិកសរុបចំនួន៥០០គ្រួសារ ក្នុង៩ភូមិ ២ឃុំ ២ស្រុក បណ្តុំនិមួយៗមានគោលការណ៍ លក្ខខន្តិកៈបណ្តុំ រចនាសម្ព័ន្ធដឹកនាំ សម្រាប់សមាជិក និងអ្នកដឹកនាំអនុវត្តន៍ ក្នុងបណ្តុំនិមួយៗមានកសិករធ្វើបង្ហាញចំនួនម្នាក់ និងគ្រូបង្គោលម្នាក់សម្រាប់ធ្វើការផ្សព្វផ្សាយការអនុវត្តល្អ និងបច្ចេកទេសដល់សមាជិកបណ្តុំ និងក្រៅបណ្តុំ ព្រមទាំងបញ្ចូលឈ្មោះគ្រួសារអ្នកទទួលផលក្នុងប្រពន្ធ័MIS របស់កម្មវិធី ASPIRE។
10. បានរៀបចំវេទិកា MSP ជាមួយអ្នកពាក់ព័ន្ធច្រើនភាគីដើម្បីគាំទ្រដល់ផែនការផលិតកម្ម និងការផ្សារភ្ជាប់ទីផ្សារបានចំនួន១០បណ្តុំអាជីវកម្មបន្លែ ដោយមានអ្នកចូលរួមសរុបចំនួន៥៤១នាក់/ស្រី២៩៣នាក់ ក្នុងនោះសមាជិកបណ្តុំអាជីវកម្ម ៥០០នាក់/ស្រី២៦៦នាក់ អាជ្ញាភូមិ ឃុំចំនួន១២នាក់ អ្នកផ្គត់ផ្គង់ធាតុចូល៣នាក់ អ្នកប្រមូលទិញ១០នាក់ ស្ថាប័នមីក្រូហិរញ្ញវត្ថុ/ធនាគារ ២នាក់ កម្មវិធី AIMS២នាក់ និងស្ថាប័នជំនាញ៥នាក់ EPDO ៧នាក់/ស្រី៤នាក់ CEW ១នាក់។ ការរៀបចំវេទិកានេះឡើងក្នុងគោលបំណងដើម្បីឲ្យគ្រប់ភាគីពាក់ព័ន្ធមានឪកាសជួយគាំទ្រគ្នាទៅវិញទៅមក។ ក្រោយពីវេទិកាចប់មណ្តុំនិមួយៗបានរៀបចំផែនការអាជីវកម្មក្នុងការផលិតបន្លែ ដើម្បីបំពេញទៅតាមដំរូវការទីផ្សារបន្លែ។
11. EPDO បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសបន្លែសុវត្ថិភាព (GAP) ផែនការអាជីវកម្មចំនួន១០វគ្គ ដោយមានអ្នកចូលរួមចំនួន៤៨៣នាក់/ស្រី២៩១នាក់។ បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការជួសជុល/ថែទាំផ្ទះសំណាញ់ដែលបានជ្រើសរើសបានចំនួន១វគ្គដោយមានអ្នកចូលរួមចំនួន១០នាក់/ស្រី៣នាក់ ផ្តល់វគ្គបណ្តុះបណ្តាលអំពីTOT ១វគ្គមានអ្នកចូលរួមចំនួន១០នាក់/ស្រី៥នាក់ និងដឹកនាំសមាជិកបណ្តុំកសិករឆ្នើមដែលមានសក្តានុពលក្នុងការដាំបន្លែ ទៅទស្សនៈកិច្ចសិក្សាពីការដាំបន្លែនៅខេត្តពោធិ៍សាត់ ដើម្បីរៀនសូត្របទពិសោធន៍បន្ថែមពីការដាំបន្លែតាមលក្ខណៈបច្ចេកទេសធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងការលក់បន្លែដោយមានអ្នកចូលរួមចំនួន២០នាក់ ស្រី១០នាក់។ វគ្គបណ្តុះបណ្តាលទាំងនេះបានបញ្ជូនទៅឲ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដាក់បញ្ចូលក្នុងប្រពន្ធ័MIS របស់កម្មវិធី ASPIRE។

12. EPDO បានផ្ដល់ការគាំទ្រពូជបន្លែត្រសក់ ត្រឡាច និងត្រប់វែងដែលមានគុណភាពល្អដល់សមាជិកបណ្ដុំបានចំនួន២០០នាក់។ ផ្ទះសំណាញ់ចំនួន១០បានតម្លើង និងផ្ដល់ជូនកសិករចំនួន១០គ្រួសារ។ ផ្ដល់សម្ភារៈធ្វើបង្ហាញដល់កសិករដែលទទួលបានផ្ទះសំណាញ់រួមមានៈ (ទុយោសាច កែង បំពង់ចំរោះ ទុយោPVC និងពូជ ជីធម្មជាតិ ថ្នាំសម្លាប់សត្វល្អិត)។
13. បណ្ដាញទីផ្សារបន្លែ១ត្រូវបានរៀបចំនៅក្នុងស្រុកមោងឫស្សី និងស្រុករុក្ខគីរី ដែលមានសមាជិកចំនួន១៣នាក់ ស្រី៧នាក់ មកពីតំណាងបណ្ដុំចំនួន១០បណ្ដុំ អ្នកប្រមូលទិញបន្លែ២នាក់ និងអ្នកលក់ធាតុចូលកសិកម្ម១នាក់។ បានផ្ដល់វគ្គបណ្ដុះបណ្ដាលពីទីផ្សារដល់សមាជិកបណ្ដាញ និងអ្នកលក់ធាតុចូលកសិកម្ម អ្នកលក់ជំនិងអ្នកប្រមូលទិញបាន១វគ្គ ។ EPDO បានធ្វើការសម្របសម្រួលជាមួយសមាជិកបណ្ដាញបន្លែនៅស្រុកមោងឫស្សី និងរុក្ខាគីរី ដើម្បីភ្ជាប់ទៅនឹងឈ្មួញទិញបន្លែនៅខេត្តបាត់ដំបង និងនៅភ្នំពេញ ក្នុងគោលបំណងចរចារពីតម្លៃបន្លែ និងដើម្បីពង្រីកទីផ្សារលក់បន្លែរបស់បណ្ដុំ។ រៀបចំកិច្ចប្រជុំជាមួយបណ្ដុំអាជីវកម្មបន្លែទាំង១០ ដោយមានអ្នកចូលរួមសរុបចំនួនសរុប ២៩៣នាក់ ស្រី២២៦នាក់ ដើម្បីរៀបចំកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យា ។ កិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យាចំនួន៨បានចុះហត្ថលេខា/អនុវត្តកិច្ចសន្យាក្នុងការផលិត និងលក់បន្លែសុវត្ថិភាពជាមួយបណ្ដុំហ៊ុន Agri On ក្រោយពីបានប្រជុំពិភាក្សាគ្នាមក ។
14. EPDO បានសម្របសម្រួលកិច្ចប្រជុំបណ្ដុំប្រចាំខែជាមួយសមាជិកបណ្ដុំអាជីវកម្មបន្លែបានចំនួន១០បណ្ដុំក្នុង១បណ្ដុំ៧លើក ដោយមានអ្នកចូលរួមចំនួន ៤៨៣នាក់/ស្រី២៩១នាក់ ដើម្បីពង្រឹងការអនុវត្តលក្ខន្តិកៈ ព័ត៌មានតម្លៃលក់បន្លែប្រចាំថ្ងៃ ទីតាំងទីផ្សារត្រូវលក់ បញ្ហាកំពុងជួបប្រទះ ដំណោះស្រាយ ពីបច្ចេកទេសនៃការដាំបន្លែធនទ្រាំនឹងការប្រែប្រួលអាកាសធាតុ យើងពិនិត្យមើលការអនុវត្តបច្ចេកទេសរបស់សមាជិកបណ្ដុំនិងណែនាំបន្ថែមនៅចំណុចខ្វះខាតដែលគាត់មិនបានអនុវត្តន៍ ព្រមទាំងរំលឹកឡើងវិញពីអ្វីដែលគាត់បានរៀនពីមុន។
15. តាមរយៈលទ្ធផលនៃការប្រមូលទិន្នន័យលើការស្ទង់មតិនេះ គ្រួសារដែលបានសម្ភាសន៍ទាំងអស់កំពុងប្រកបមុខរបរដាំបន្លែ របស់ពួកគេដោយប្រើជំនាញដាំបន្លែក្នុងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធនទៅនឹងការប្រែប្រួលអាកាសធាតុ មានចំនួន៦០គ្រួសារ ស្រី៤៦គ្រួសារ ក្នុង១០បណ្ដុំ។ ចំពោះវិធីសាស្ត្រនៃការគណនាប្រាក់ចំណូលទម្រង់វិភាគនៃប្រាក់ចំណូល និងចំណាយគឺត្រូវបញ្ចូលទៅក្នុងទំរង់ Microsoft Excel ហើយបន្ទាប់មកគ្រាន់តែវិភាគចំនួននោះគឺការគណនា តម្លៃផលិតកម្មបន្លែ និងដំណាំបន្លែសម្រាប់គ្រួសារដែលបានសម្ភាសន៍ម្នាក់ៗត្រូវបានគណនាថាជាប្រាក់ចំណូលសុទ្ធ បន្ទាប់ពីកាត់ការចំណាយលើដាំបន្លែ ដូចខាងក្រោម៖
    - មុនពេលអនុវត្តន៍គម្រោងគិតជាមធ្យមគាត់ដាំបន្លែលក់បានចំនួន 605.13ដុល្លា គាត់ចំណាយដើមទុនអស់ 460.31ដុល្លា គិតជាមធ្យមគាត់លក់ចំណេញបានបានលុយចំនួន 144.81ដុល្លារ ។
    - ក្រោយពីចូលរួមក្នុងកម្មវិធីគាត់ដាំបន្លែលក់បានចំនួន 1,356.22 ដុល្លារ គាត់ចំណាយដើមទុនអស់ចំនួន 597.03ដុល្លារ គិតជាមធ្យមគិតជាមធ្យមគាត់លក់ចំណេញបានលុយចំនួន 759.19 ដុល្លារ ។ ចំនួននៃការប្រែប្រួលនៃទំហំលក់ផលិតកម្មកើនឡើង 751.10 ដុល្លារ និងកំណើនប្រាក់ចំណេញជាមធ្យមភាគចំនួន 759.19ដុល្លាក្នុង១គ្រួសារ។

## ៥.៤. លទ្ធផលរយៈពេលខ្លី

4. បណ្តុំអាជីវកម្មបន្លែចំនួន១០បណ្តុំមានសមាជិកចំនួន៥០០គ្រួសារ ស្រី២៦៦គ្រួសារទទួលបានវគ្គបណ្តុះបណ្តាលពីបច្ចេកទេសដាំបន្លែ និងទីផ្សារ។ បន្ទាប់ពីទទួលការបណ្តុះបណ្តាលមកសមាជិកបណ្តុំចំនួន៨០% មានការយល់ដឹងពីបច្ចេកទេសដាំបន្លែធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងទីផ្សារ ព្រមទាំងបានយកចំណេះដឹងទាំងនេះមកប្រើប្រាស់ក្នុងការពង្រឹងមុខរបរ និងស្វែងរកទីផ្សារលក់ផលិតផលរបស់ខ្លួន។
5. សមាជិកបណ្តុំអាជីវកម្ម ចំនួន២០គ្រួសារ បានរៀនសូត្របទពិសោធន៍ ការដាំបន្លែ ពីដំណើរទស្សនៈកិច្ច ហើយយកទៅអនុវត្តន៍ក្នុងកសិដ្ឋានរបស់ខ្លួន ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ។
6. កសិករគំរូដាំបន្លែចំនួន១០គ្រួសារទទួលបានផ្ទះសំណាញ់ និងសម្ភារៈកសិកម្មសម្រាប់ពង្រីកការដាំដំណាំបន្លែ បានពេញ១ឆ្នាំ ដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។
7. សមាជិកបណ្តុំអាជីវកម្មផលិតកម្មបន្លែចំនួន២០០គ្រួសារទទួលបានពូជបន្លែសម្រាប់ពង្រីកការដាំដុះដំណាំបន្លែ ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារ។
8. បណ្តុំអាជីវកម្មបន្លែមានបណ្តាញទីផ្សារថ្នាក់ស្រុក ដែលមានសមាសភាពដូចជាៈ អ្នកដឹកនាំបណ្តុំ ម្ចាស់ដេប៉ូលក់សម្ភារៈកសិកម្ម ឈ្មួញទទួលទិញ ក្នុងការទំនាក់ទំនងគ្នាសម្រាប់ព័ត៌មានដាំដុះ ការផ្លាស់ប្តូរពូជ ការសិក្សាពីតម្លៃក្នុងការលក់ និងទិញសម្ភារៈកសិកម្ម។
9. បណ្តុំអាជីវកម្មផលិតកម្មបន្លែចំនួន៨បណ្តុំបានចុះកិច្ចសន្យាផ្គត់ផ្គង់បន្លែសុវត្ថិភាពជាមួយបណ្តុំហ៊ុន Agri On ធ្វើឲ្យគាត់មានទំនុកចិត្តក្នុងការផលិតបន្លែ មានផែនការដាំដុះ ទទួលបានតម្លៃសមរម្យ ព្រមទាំងធ្វើឲ្យគាត់កាត់បន្ថយការប្រើប្រាស់ថ្នាំពុល និងមានការយល់ដឹងកាន់តែច្បាស់ពីផលប្រយោជន៍នៃការផលិតបន្លែសុវត្ថិភាព។
10. ក្រុមបណ្តុំអាជីវកម្មបន្លែចំនួន១២គ្រួសារបានដាក់ពាក្យខ្ចីលុយពីកម្មវិធី AIMs សំរាប់ដំណើរការខ្សែច្រវ៉ាក់ផលិតកម្មបន្លែ។

## ៥.៥ ការផ្លាស់ប្តូរកំឡុងពេលអនុវត្តគម្រោង

1. កសិករចំនួន២៩១គ្រួសារ ក្នុង១០បណ្តុំ បានយកបច្ចេកទេសដាំបន្លែទៅអនុវត្តន៍ បន្ទប់ពីទទួលបានវគ្គបណ្តុះបណ្តាលដូចជា ការជ្រើសរើសពូជឲ្យត្រូវតាមរដូវកាល បានរៀបចំដី បណ្តុះកូនដំណាំ ការប្រើប្រាស់ដី និងថ្នាំកសិកម្ម ការតាក់តែងមែក ការថែទាំ ការផ្តល់ទឹកដល់ដំណាំ។
2. សមាជិកបណ្តុំអាជីវកម្មបន្លែចំនួន១២គ្រួសារបានដាំដំណាំក្នុងផ្ទះសំណាញ់ទទួលបានទិន្នផលខ្ពស់ ងាយស្រួលក្នុងការថែទាំ គ្រប់គ្រងសត្វល្អិត ចំណេញពេលវេលា។
3. សមាជិកបណ្តុំអាជីវកម្មបន្លែចំនួន១០បណ្តុំមានបណ្តាញទីផ្សារក្នុងការចែករំលែកព័ត៌មានទីផ្សារ និងកន្លែងលក់បន្លែរួមគ្នា ទទួលបានតម្លៃសមរម្យ និងបានចុះកិច្ចសន្យាទិញ លក់បន្លែជាមួយក្រុមហ៊ុនប្រមូលទិញបន្លែ។
4. បណ្តុំអាជីវកម្មបន្លែចំនួន១០មានកសិករគ្រូចំនួន១០នាក់សម្រាប់ជួយផ្តល់ជាគំនិត យោបល់ ការប្រឹក្សាយោបល់ ចែករំលែកពីការអនុវត្តបានល្អ បច្ចេកទេសដាំបន្លែ ដល់សមាជិកក្នុងបណ្តុំ និងក្រៅបណ្តុំ។
5. សមាជិកបណ្តុំបានបង្កើនរដូវកាលនៃការដាំបន្លែ ដែលពីមុនគាត់ធ្លាប់ដាំតែម្តង ឬ២ដងក្នុង១ឆ្នាំ មកដាំជាប្រចាំ (វិលជុំ) ដោយមិនគិតពីរដូវកាល។

# ៥.៦. និរន្តរភាពនៃគម្រោង

ដើម្បីធានានូវនិរន្តរភាព EPDO បានធ្វើការសម្របសម្រួល និងបង្កើតជាបណ្តុំអាជីវកម្មបន្លែ ព្រមទាំងធ្វើការពង្រឹងសមត្ថភាពដល់សមាជិកបណ្តុំ អ្នកដឹកនាំបណ្តុំ ដើម្បីឲ្យពួកគាត់មានសមត្ថភាពរឹងមាំក្នុងការគ្រប់គ្រង ចាត់ចែងនូវធនធាន និងសមិទ្ធផលដែលបានគាំទ្រ ដូចជាសម្ភារៈពូជបន្លែ និងចំណេះដឹង មិនតែប៉ុណ្ណោះពួកគាត់មានផែនការក្នុងការពង្រីកមុខរបរដាំបន្លែផ្ទៃដីដាំបន្លែ មានការទំនាក់ទំនងជាមួយឈ្មួញបានល្អ លក់បានតម្លៃសមរម្យ ព្រមទាំងមានការគាំទ្រលើកទឹកចិត្តពីអាជ្ញាធរ កសិកម្ម ស្រុក ខេត្ត អង្គការ ស្ថាប័នឯកជន ពួកគាត់បានចូលរួមតាំងពីចាប់ផ្តើមរហូតមកក្នុងអំឡុងពេលនៃការអនុវត្តគម្រោង បានធ្វើឲ្យពួកគាត់មានការផ្លាស់ប្តូរឥរិយាបទ ពីការដាំបន្លែតាមទំលាប់ការដាំដុះមិនបានត្រឹមត្រូវ មកអនុវត្តន៍តាមលក្ខណៈបច្ចេកទេសថ្មីធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈនៃការចុះតាមដាន និងការបង្វឹកជាប្រចាំ យើងសង្កេតឃើញថា សមាជិកបណ្តុំ និងអ្នកដឹកនាំបណ្តុំបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការប្រកបមុខរបរដាំដំណាំបន្លែនេះ ដោយគាត់បានចុះកិច្ចសន្យាជាមួយបណ្តុំហ៊ុន មានតម្លៃសមរម្យ មានបណ្តាញទីផ្សារក្នុងការទំនាក់ទំនងគ្នា មានកន្លែងក្នុងការប្រមូលផ្តុំក្នុងការកល់បន្លែ យើងសង្ឃឹមថា អនាគត សមាជិកទាំងនោះនៅតែបន្ត និងពង្រីកមុខរបរដាំបន្លែជារៀងរហូត ដោយសារតែប្រើរយៈពេលខ្លី ទទួលបានផលកំរៃខ្ពស់ ងាយស្រួលរកទីផ្សារលក់ និងមានការជួយគាំទ្រពីអ្នកពាក់ព័ន្ធ ជាពិសេសគឺមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។

# កិច្ចសហការ

តារយៈនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០២០នេះ EPDO បានសហការជាមួយអ្នដែលមានការពាក់ព័ន្ធដូចជា៖ មន្ទីរ កសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទខេត្ត ការិយាល័យជំនាញ ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុកទាំង២ លោកអភិបាលស្រុក លោកមេឃុំ មេភូមិគ្រប់តំបន់គោលដៅ និងវិស័យឯកជនរួមមាន៖ ស្ថាប័នមីក្រូហិរញ្ញវត្ថុ ធនាគារ អ្នកលក់ធាតុចូលកសិកម្ម និងអ្នកប្រមូលទិញ។ល។ តាំងពីពេលចាប់ផ្តើមការអនុវត្តគម្រោង រហូតដល់ពេលបញ្ចប់គម្រោង ដូចជាសកម្មភាព ការចងក្រងក្រុម/បណ្តុំអាជីវកម្ម ការរៀបចំគោលការណ៍ក្រុម/បណ្តុំ ការបណ្តុះបណ្តាលបច្ចេកទេស ការគាំទ្រធនធាន ការធ្វើទិវាបង្ហាញ ទិវាពហុភាគី ការរៀបចំផែនការអាជីវកម្មជាដើម សុទ្ធតែមានការចូលរួម ការប្រឹក្សាយោបល់ និងអនុសាសន៍នានា ពីអ្នកពាក់ព័ន្ធខាងលើ ធ្វើឲ្យដំណើការនៃការអនុវត្តគម្រោងរបស់អង្គការ EPDO ទទួលបានជោគជ័យគួរជាទីពេញចិត្ត។ តាមរយៈនៃកិច្ចសហការនេះ ទោះជាមានបញ្ហាប្រឈមខ្លះ ក៏អាចរួមគ្នាដោះស្រាយបានទាន់ពេលវេលា ។

# មេរៀនបទពិសោធន៍

- មានកិច្ចសហការល្អជាមួយអ្នកពាក់ព័ន្ធ ធ្វើឲ្យដំណើការនៃការអនុវត្តគម្រោងមានភាពរលូន មានការចូលរួមដោះស្រាយបញ្ហា ឧបសគ្គនានាបានទាន់ពេលវេលា។
- អ្នកចូលរួមក្នុងគម្រោង មានការយល់ច្បាស់ពីគោលដៅ គោលបំណង សកម្មភាព គម្រោងតាំងពីពេលចាប់ ផ្តើម ធ្វើឲ្យពួកគាត់មានភាពរីករាយ និងចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសហគមន៍របស់ពួកគេ។
- បណ្តុំអាជីវកម្មនិមួយៗមានកសិដ្ឋានបង្ហាញគំរូ១កន្លែង ដែលអាចជួយដល់សមាជិកបណ្តុំរៀនសូត្រ និងផ្សព្វផ្សាយបច្ចេកទេស ចែករំលែកចំណេះដឹង បទពិសោធន៍ ដែលធននឹងការប្រប្រួលអាកាសធាតុ ការ

ទំនាក់ទំនងទីផ្សារ និងប្រឹក្សាយោបល់ជាមួយសមាជិកបណ្តុំ ដល់កសិករដទៃទៀតក្នុងភូមិ ធ្វើឲ្យបណ្តុំអាជីវកម្ម មានភាពសកម្ម ក្នុងការធ្វផលិតកម្ម និងឈានចូលទីផ្សារបានល្អ។

## ការសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការអនុវត្តគម្រោងក្នុង ឆ្នាំ២០២០ អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) បានប្រឹងប្រែងក្នុងការអនុវត្តន៍សកម្មភាពបានល្អ ព្រមទាំងមានការចូលរួមគ្រប់ភាគីពាក់ព័ន្ធ និងកសិករក្នុងតំបន់គោលដៅទាំងអស់ដើម្បីឆ្លើយតបទៅនឹងគោលដៅ និងគោលបំណងនៃគម្រោង ក្នុងអំឡុពេលនៃរបាយការណ៍នេះ អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) បានអនុវត្តសកម្មភាពដែលទទួលលទ្ធផលសំខាន់ៗគួរជាទីពេញចិត្ត។

តាមរយៈនៃការអនុវត្តគម្រោង សង្កេតឃើញថា ទាំងកសិករគំរូ សមាជិកបណ្តុំអាជីវកម្ម កសិករខាងក្រៅ និងអ្នកពាក់ព័ន្ធ មានចំណាប់អារម្មណ៍ខ្លាំងពីសកម្មភាព ផលិតកម្មសត្វ(មាន់) ផលិតកម្មបន្លែ និងសកម្មភាពវារីវប្បកម្ម និងចូលរួមអនុវត្តយ៉ាងសកម្ម ដើម្បីបង្កើនផលិតកម្មកសិកម្ម ការផ្គត់ផ្គង់ទីផ្សារ និងកំណើនប្រាក់ចំណូល។

មានកិច្ចសហការល្អក្នុងការអនុវត្តគម្រោង ដោយមានការគាំទ្រពីសំណាក់ មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្ត ការិយាល័យសហគមន៍កសិកម្ម ខ្សែតសាស្ត្រ ជលផល មន្ត្រីជំនាញនៃមន្ទីរកសិកម្ម ការិយាល័យកសិកម្មធាធានធម្មជាតិ និងបរិស្ថានស្រុក អាជ្ញាធរមូលដ្ឋាន វិស័យឯកជន អ្នកផ្គត់ធាតុចូលកសិកម្ម ក្រុមប្រមូលទិញផលិតផលកសិកម្ម បណ្តុំអាជីវកម្មទាំងអស់ បានចូលរួមចំណែកក្នុងការលើកកំពស់ផលិតកម្ម អាជីវកម្ម បន្លែ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ធ្វើឲ្យដំណើការនៃការអនុវត្តគម្រោងទទួលបានជោគជ័យគួរជាទីមោទនៈ។

## ថវិកាប្រចាំឆ្នាំ ២០២០

| ឈ្មោះគម្រោង | ម្ចាស់ជំនួយ/ដៃគូ | ខេត្ត | ថវិកា |
|---|---|---|---|
| លើកកម្ពស់ផលិតភាពកសិកម្មដែលធន់នឹងអាកាសធាតុ | ACR/Caritas Australia | | 85,151 |
| បង្កើបណ្តុំអាជីវកម្មមាន់ | ASPIRE/IFAD/PDAFF | ពោធិ៍សាត់ | 43,919 |
| បង្កើបណ្តុំអាជីវកម្មវារីវប្បកម្ម | ASPIRE/IFAD/PDAFF | ពោធិ៍សាត់ | 31,500 |
| បង្កើបណ្តុំអាជីវកម្មមាន់ | ASPIRE/IFAD/PDAFF | បាត់ដំបង | 37,512 |
| បង្កើបណ្តុំអាជីវកម្មបន្លែ | ASPIRE/IFAD/PDAFF | បាត់ដំបង | 47,591 |
| **សរុប** | | | **245,673** |

ថ្ងៃ សុក្រ ១១កើត ខែផល្គុណ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ពោធិ៍សាត់ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០២០

ឯកភាពដោយ
ប្រធានអង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន

អ្នកធ្វើរបាយការណ៍

**សំរិទ្ធ អ៊ុត**

**ស៊ីុន ផល្លា**

# ករណីសិក្សាទី១÷

## ភាពជោគជ័យនៃការដាំបន្លែតាមបច្ចេកទេសរបស់គ្រួសារ ជុំ សុភា

លោកជុំ សុភា ភេទប្រុសអាយុ ៣៦ឆ្នាំ ប្រពន្ធឈ្មោះ ងួន មុំ អាយុ២៧ឆ្នាំ មានសមាជិកសរុប៥នាក់ ស្រី៤នាក់ រស់នៅភូមិផ្លូវលួង ឃុំកញ្ជរ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ភូមិនេះនៅរដូវវស្សារងគ្រោះដោយសារទឹកជំនន់ ធ្វើឲ្យប៉ះពាល់ដល់បន្លែ ដំណាំ ស្រូវ រលួយខូចខាត ដោយឡែកនៅរដូវប្រាំងវិញក្តៅហួតហែងខ្សត់ទឹកប្រើប្រាស់ ពួកគាត់ដាំដំណាំបន្លែតាមទម្លាប់ ហើយជួបប្រទះនូវឧបសគ្គមួយចំនួនដូចជា សត្វល្អិតបំផ្លាញ រលួយ ទទួលបានទិន្នផលតិចតួច ឆ្នាំខ្លះស្ទើរពុំបានពូជវិញ។



គ្រួសារអ្នកស្រី ងួន មុំ ជាគ្រួសារក្រីក្រ គ្មានមុខរបរពិតប្រាកដ បើតាមសម្តីបងស្រី បានរៀបរាប់ថា មុនពេលចូលក្នុងគម្រោងគ្រួសារខ្ញុំ មានមុខរបរធ្វើស្រែ ប៉ុន្តែទទួលបានផលតិចតួច ឆ្នាំខ្លះស្ទើររកពូជមិនបានវិញផង ក្រៅពីធ្វើស្រែ គ្រួសារខ្ញុំដាំបន្លែតាមទម្លាប់ មុនចូលគម្រោង មួយវដ្តនៃការដាំត្រសក់ក្នុងផ្ទៃដី១៤អា ទទួលបានប្រាក់ចំណូលសុទ្ធចំនួន៣០០,០០០រៀល រីឯសណ្តែកកួរចន្លោះពី១០០,០០០រ ទៅ១៥០,០០០រ និងត្រកួន ជី ស្លឹកគ្រៃ បានត្រឹមហូបតែប៉ុណ្ណោះ។ រីឯប្តីខ្ញុំ ក្រៅពីធ្វើស្រែ គឺគាត់ធ្វើកម្មករសំណង់ ក្នុងមួយថ្ងៃទទួលបានប្រាក់កម្រៃចំនួន២៥,០០០រ ប្រាក់ចំណូលទាំងនោះមិនអាចផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារបានគ្រប់គ្រាន់ ហើយជាប់ជំពាក់បំណុលគេផងដែរ។

នៅខែកញ្ញា ឆ្នាំ២០១៩ គ្រួសារខ្ញុំបានចូលជាសមាជិកក្រុមដាំបន្លែ ទទួលបានវគ្គបណ្តុះបណ្តាលបច្ចេកទេសនៃការដាំបន្លែដូចជា៖ ការរៀបចំដី ការបាចកំបោរ ការលើករង បណ្តុះកូន ការប្រើប្រាស់ជី ការប្រើប្រាស់ទឹក ការជ្រើសរើសពូជដំណាំតាមរដូវកាល វិធានការចម្រុះការពារដំណាំ ការកំចាត់សត្វល្អិត និងជង្ហុំរដោយការប្រើថ្នាំកសិកម្ម ការថែទាំ និងការប្រមូលផល។ល។ មិនតែប៉ុណ្ណោះ រូបខ្ញុំជាប្រធានណៈកម្មការទីផ្សារនៅភូមិផ្លូវលួង ជាញឹកញាប់ អង្គការEPDO ធ្វើការបង្វឹកជាប្រចាំ នូវការដាំបន្លែតាមបច្ចេកទេស(ដោយប្រើប្រព័ន្ធដំណក់ទឹក) ដែលធ្វើឲ្យមានការចាប់អារម្មណ៍ជាខ្លាំង ព្រមទាំងទទួលបានការវិនិយោគជាសម្ភារៈ និងថវិកា សម្រាប់ដាំបន្លែរួមមាន៖ ត្រសក់ សណ្តែកកួរជាទម្រង់ទ្រាយមធ្យម ដោយអនុវត្តស្របតាមបច្ចេកទេស ធ្វើឲ្យគ្រួសារខ្ញុំទទួលបានប្រាក់ចំណូលមកពីការលក់បន្លែសរុបទាំងអស់មានចំនួន៨,១០០,០០០រ ក្នុងនោះ បន្លែត្រសក់ក្នុងផ្ទៃដី១៤អា ដាំប្រើប្រពន្ធ័តំណក់ទឹក ប្រមូលផលក្នុង១ថ្ងៃចន្លោះពី១៤០ ទៅ១៧០គីឡូ បើធៀបអំពីប្រាក់ចំណូលសុទ្ធនៃការលក់ផលិតផលក្នុងមួយវដ្តនៃការ ផលិតមានការកើនឡើងចន្លោះពីចំនួន២ ទៅ៣ដងនៃប្រាក់ចំណូលកាលពីមុនចូលគម្រោង។ ក្នុងផ្ទៃដី១៤អានេះ ដាំត្រសក់ដាំបាន២លើក មួយវដ្តនៃការដាំមានចំនួន៣ខែ ការប្រមូលផលត្រសក់លើកទីមួយទទួលបានប្រាក់ចំណូលសុទ្ធចំនួន ៣,៥០០,០០០រ ប្រមូលផលត្រសក់លើកទីពីរបានចំនួន៣,០០០,០០០រ តាំងពីខែតុលាឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ ២០២០ ក្នុងផ្ទៃដី១៤អា ទទួលបានចំណូលសរុបចំនួន៦,៥០០,០០០រ និងចំណូលមកពីការដាំសណ្តែកកួរមួយវដ្តមានរយៈពេល៣ខែដូចគ្នាបានចំនួន១,៤០០,០០០រ និងត្រកួនទទួលបានចំណូលចំនួន ២០០.០០០រ។






ប្រាក់ចំណូលទាំងនេះគ្រួសារខ្ញុំប្រើប្រាស់ទៅលើការដោះបំណុលចាស់បានចំនួន៤,០០០,០០០៛ ទិញសម្ភារៈពង្រីកការដាំបន្លែ(ប្រព័ន្ធទឹកសាចសម្រាប់បន្លែស្លែ) ទិញទុយយោតំណក់ទឹក ទិញគ្រាប់ពូជដាំបន្ត ទិញជី ថ្នាំពុលកសិកម្ម ទិញស្បៀងអាហារប្រចាំថ្ងៃ សន្សំប្រចាំសប្តាហ៍ និងសន្សំក្នុងគ្រួសារ ព្រមទាំងចំណាយលើតម្រូវការផ្សេងៗក្នុងគ្រួសារដូចជាបុណ្យ ការ។



គ្រួសារខ្ញុំកំពុងបន្តការដាំដុះជាលក្ខណៈបង្វិលជុំ ដោយឃើញប្រាក់ចំណូលពីការដាំបន្លែបានច្រើនជាងការធ្វើស្រែ ដូច្នេះហើយ គ្រួសារខ្ញុំ យកដីដែលធ្លាប់ធ្វើស្រែ មកធ្វើជាដាំបន្លែត្រសក់បន្ត ព្រោះទីផ្សារបន្លែមានតម្លៃខ្ពស់ ហើយប្រើរយៈខ្លី ទទួលបានផលច្រើនជាងការធ្វើស្រូវ។ លើសពីនេះទៅទៀត ការដាំរបស់នាងខ្ញុំក្លាយទៅជាកន្លែងសម្រាប់កសិករក្នុងភូមិមករៀនសូត្រពីការដាំបន្លែតាមបច្ចេកទេស។

តាមសម្តីអ្នកស្រី ងួន មុំ បាននិយាយប្រាប់ថា គ្រួសារខ្ញុំមានការសប្បាយរីករាយព្រមទាំងពេញចិត្តចំពោះគម្រោង ដែលបានជួយដល់គ្រួសារខ្ញុំទាំងចំណេះដឹង បច្ចេកទេស ធនធានសម្ភារៈ ការរកទីផ្សារលក់ផលិតផល ធ្វើឲ្យផលិតផលដែលផលិតបាន លក់ក្នុងតម្លៃខ្ពស់ មិនខ្វល់ពីការបន្ទាបតម្លៃ មានការជម្រើសរកអ្នកប្រមូលទិញក្នុងតម្លៃសមរម្យ គ្រួសារខ្ញុំមានការផ្លាស់ប្តូរទាំងជីវភាពរស់នៅ មានប្រាក់ចំណូលកើនឡើង និងចេះកែច្នៃពេលវេលា ប្រើប្រាស់ធនធានដែលមានស្រាប់ឲ្យអស់លទ្ធភាព បានធូស្បើយនូវការជំពាក់បំណុល សមាជិកក្នុងគ្រួសារមានសុខភាពប្រសើរ



ជាងមុន ហើយជាពិសេសខ្ញុំជាស្រ្តីបានទទួលនូវមុខដំណែងជាអ្នកដឹកនាំផ្នែកទីផ្សារ ហើយធ្វើការទំនាក់ទំនង បណ្តាញទីផ្សារជូនកសិករដាំន្លែក្នុងភូមិផ្លូវល្បួង ។ ទន្ទឹមនឹងនោះ គ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការ **ACR/ Caritas Australia** និងអង្គការ **EPDO** ដែលបានជួយបណ្តុះគំនិតបច្ចេកទេស និងវិនិយោគសម្ភារៈបង្កើនមុខរបរ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្តូរ រីកចម្រើនគួរជាទីពេញចិត្ត។

# ករណីសិក្សាទី២÷

## ការលើកកម្ពស់ប្រាក់ចំណូលគ្រួសារពិការ លោក ម៉ន សុខខឿន

លោក ម៉ន សុខឃឿន ភេទប្រុស អាយុ៤៧ឆ្នាំ ប្រពន្ធឈ្មោះរាជ ធា ភេទស្រី អាយុ៤៦ឆ្នាំ មានកូន៣នាក់ ស្រី ៣ រស់នៅភូមិកោះក្រសាំង ឃុំអន្លង់រិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។



តាមប្រសាសន៍របស់លោក ម៉ន សុខឃឿន គាត់ជាជនពិការបាន រៀបរាប់ប្រាប់ថា មុនពេលចូលក្នុងគម្រោង គ្រួសារខ្ញុំមានជីវភាពក្រលំបាក មានមុខរបរធ្វើស្រែ ដាំបន្លែតិចតួចនៅលើផ្ទៃដី៥អាដែលខ្ញុំមាន និងធ្វើកម្មករសំណង់ ហើយទទួលបានកម្រៃទាបបំផុតជាងជនដែលមានកាយសបម្បទាគ្រប់គ្រាន់ ប៉ុន្តែទោះជាប្រាក់កម្រៃទាបប៉ុណ្ណាក៏ខ្ញុំនៅតែធ្វើ ព្រោះគ្មានជម្រើស ជីវិតជាភាពពិកាទទួលរងនូវការរើសអើង ទាំងការរកការងារធ្វើ ទាំងការទទួលបានប្រាក់កម្រៃ ទាំងការទំនាក់ទំនង ការរាប់រកពីញាតិជិតខាង ហើយក៏មិនសូវបានទទួលព័ត៌មាន មិនមានឱកាសបានចូលរួមប្រជុំ រវល់បញ្ហារកប្រាក់ចំណូលចិញ្ចឹមជីវិត ដើម្បីរស់មួយថ្ងៃសម្រាប់មួយតែប៉ុណ្ណោះ។ បើក្រលេកមកមើលផ្ទះវិញ គ្រួសារខ្ញុំរស់នៅក្នុងផ្ទះដំបូលប្រក់ស្លឹកត្នោត និងជញ្ជាំងធ្វើអំពីស្លឹកដូងគៀបឬស្សី មានទំហំ3mx4m សង់ជាប់សំយាប ជង្រុករបស់ម្តាយមេម៉ាយ ពេលភ្លៀងម្តងៗ លិចសឹងតែរកកន្លែងជ្រកមិនបាន។ ក្នុងរយៈពេល១២ខែចុងក្រោយ មុនចូលគម្រោង ការដាំបន្លែតាមទម្លាប់ ទទួលទន្និផលតិចហើយ លក់ក្នុងតម្លៃទាប។ ក្នុងរយៈពេលមួយឆ្នាំ គ្រួសារខ្ញុំទទួលបានចំណូលសរុបទាំងអស់ប្រហែល១,២៥០,០០០៛ និងប្រាក់ចំណូលប្ដីខ្ញុំធ្វើសំណង់មួយឆ្នាំទទួលបានចន្លោះពី៥០០,០០០៛ ទៅ ១,០០០,០០០៛ (រយៈពេលនៃការធ្វើសំណង់ ក្នុងមួយខែធ្វើបានចន្លោះពី ៤ទៅ៥ថ្ងៃប៉ុណ្ណោះ)។



នៅក្នុងខែកក្កដា ឆ្នាំ២០១៩ គ្រួសារខ្ញុំបានចូលរួមជាមួយគម្រោងផលិតភាពកសិកម្មដែលធននឹងអាកាសធាតុដែលសម្របសម្រួលដោយអង្គការEPDO ឧបត្ថម្ភដោយអង្គការអេស៊ីអា ការីតាសអូស្ត្រាលី ចាប់តាំងពីពេលនោះមកគ្រួសារខ្ញុំ បានចូលជាសមាជិកក្រុមដាំបន្លែ ទទួលបានវគ្គបណ្ដុះបណ្ដាលបច្ចេកទេសផលិតកម្មបន្លែដូចជា ការរៀបចំដី ការបាចកំបោរដី ការលើករង ការបណ្ដុះកូន ការប្រើប្រាស់ដី ការជ្រើសរើសពូជបន្លែតាមរដូវកាល វិធានការកំចាត់សត្វល្អិត និងជង្គឺរដោយការប្រើថ្នាំកសិកម្ម ការថែទាំ និងការប្រមូលផល។

លោក ម៉ន សុឃឿន បាននិយាយបន្ថែមទៀតថា ខ្ញុំក្រៅពីទទួលវគ្គបណ្ដុះបណ្ដាល ក៏បានចូលរួមវគ្គសិក្ខាសាលាស្តីពីទីផ្សារ និងការវិភាគខ្សែសង្វាក់តម្លៃ ចូលរួមពិភាក្សាក្រុមឆ្លុះបញ្ចាំងគម្រោង និងរៀងរាល់កម្មវិធីជាមួយប្រជាពលរដ្ឋទូទៅ ក៏ដូចជាសមាជិកសហគមន៍។ គ្រួសារខ្ញុំទទួលបានការវិនិយោគសម្ភារៈ និងថវិកា សរុបទាំងអស់ចំនួន៨០០,០០០៛ពីអង្គការEPDO ដើម្បីធ្វើផលិតកម្មបន្លែ។ តាំងពីពេល នោះមក ខ្ញុំចាប់ផ្តើមធ្វើផែនការអាជីវកម្ម រូបខ្ញុំពិការដៃ ដាំបន្លែមើលថែទាំបន្លែជាមួយកូន ដោយជួលដីអ្នកនៅក្បែរប្រឡាយទុកទំនេរចោលចន្លោះពេលដែលគេមិនធ្វើស្រែ មកដាំបន្លែបន្ថែម រីឯប្រពន្ធរបស់ខ្ញុំប្រមូលទិញបន្លែក្នុងភូមិទៅលក់នៅទីផ្សារ ដើម្បីពង្រីកប្រាក់ចំណូលក្នុងគ្រួ



សារ។ ការចាប់ផ្ដើមអនុវត្តតាមផែនការដែលបានវិភាគមានដូចជា ការដាំត្រសក់ សណ្ដែកកួរ ត្រប់វែង ស្ពៃ ជាទ្រង់ទ្រាយមធ្យម។ រហូតមកទល់ពេលនេះខ្ញុំមានសមត្ថភាព មានបទពិសោធន៍ អាចធ្វើការចែករំលែកបច្ចេកទេសការដាំបន្លែ ការតម្លើងទ្រីប ដល់សមាជិកដាំបន្លែក្នុងភូមិកោះក្រសាំងចំនួន១១គ្រួសារបន្ថែមទៀត។

ជាក់ស្ដែងក្នុងរយៈពេលរហូតមកដល់ខែមិថុនា ឆ្នាំ២០២០នេះ គ្រួសារខ្ញុំទទួលបានប្រាក់ចំណូលពីការដាំបន្លែសរុបទាំងអស់ចំនួន **២៦,៥០០,០០០៛** និងទទួលបានប្រាក់ចំណូលមួយផ្នែកទៀត ពីការប្រមូលទិញបន្លែក្នុងសហគមន៍ទៅលក់នៅទីផ្សារពោធិ៍សាត់ ប្រពន្ធខ្ញុំត្រូវចំណាយពេលវេលាដ៏មានតម្លៃគឺត្រូវភ្ញាក់ពីម៉ោង៣ទៀបភ្លឺដឹកបន្លែចេញមកលក់ដុំ និងលក់រាយនៅទីផ្សារ ទទួលបានប្រាក់ចំណេញចន្លោះពី៤០០០០៛ ទៅ៦០០០០៛ក្នុងមួយថ្ងៃ។

ប្រាក់ចំណូលទាំងអស់នេះបានជួយគ្រួសារខ្ញុំ ធ្វើឲ្យខ្ញុំមានទឹកចិត្តដើម្បីបន្តការផលិតឲ្យកាន់តែប្រសើរជាងនេះ។ ប្រាក់ចំណូលទាំងនេះគ្រួសារខ្ញុំបានប្រើប្រាស់សម្រាប់សាងសង់ផ្ទះ ទំហំ6m x 8m ដំបូលប្រក់សង្ក័សី ជញ្ជាំងសង្ក័សី ខ្ពស់ផុតពីដីអស់ថវិកាចំនួន១០,០០០,០០០៛ សងបំណុលចាស់ ៨,០០០,០០០៛ ចូលរួមសន្សំប្រាក់ក្នុងសន្សំដើម្បីផ្លាស់ប្ដូររាល់សប្ដាហ៍ សន្សំក្នុងគ្រួសារ ទិញម្ហូបអាហារក្នុងគ្រួសារប្រចាំថ្ងៃ ផ្គត់ផ្គង់កូនៗរៀន និងមួយផ្នែកធំទិញសម្ភារៈសម្រាប់ពង្រីកការដាំបន្លែបន្ត។



តាមសម្ដីលោក ម៉ន សុខឿន បាននិយាយបន្តទៀតថា គ្រួសារខ្ញុំមានការសប្បាយរីករាយទាំងពេញចិត្តចំពោះគម្រោង ដែលបានជួយដល់គ្រួសារខ្ញុំ ជាពិសេសរូបខ្ញុំជាជនពិការទាំងចំណេះដឹង បច្ចេកទេស ធនធានសម្ភារៈ ការរកទីផ្សារលក់ផលិតផល ធ្វើឲ្យផលិតផលដែលផលិតបាន លក់ក្នុងតម្លៃខ្ពស់សមរម្យ មានជម្រើសរកអ្នកប្រមូលទិញក្នុងតម្លៃសមរម្យ គ្រួសារខ្ញុំមានការផ្លាស់ប្ដូរទាំងជីវភាពរស់នៅ មានប្រាក់ចំណូលកើនឡើង និងចេះប្រើប្រាស់ពេលវេលាធនធានដែលមានស្រាប់ឲ្យអស់លទ្ធភាព។ សមាជិកក្នុងគ្រួសារមានសុខភាពប្រសើរជាងមុន ហើយជាពិសេសខ្ញុំជាជនពិការបានទទួលនូវមុខដំណែងជាអ្នកដឹកនាំផ្នែកទីផ្សារ ហើយធ្វើការទំនាក់ទំនង បណ្ដាញទីផ្សារជូនកសិករដាំន្លែក្នុងភូមិកោះក្រសាំង។ ទន្ទឹមនឹងនោះគ្រួសារខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការ **ACR/ Caritas Australia** និងអង្គការ **EPDO** ដែលបានជួយបណ្ដុះគំនិតបច្ចេកទេស និងវិនិយោគសម្ភារៈបង្កើតមុខរបរ ធ្វើឲ្យគ្រួសារខ្ញុំមានការផ្លាស់ប្ដូរ រីកចម្រើនគួរជាទីពេញចិត្ត។



# ករណីសិក្សាទី៣៖

## បច្ចេកទេសថ្មីនៃការចិញ្ចឹមកង្កែបដែលធននឹងការប្រែប្រួលអាកាសធាតុ

ភូមិសែនជ័យ ជាភូមិមួយដែលស្ថិតនៅក្នុងស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ភូមិនេះមានប្រជាជនភាគច្រើនប្រកបរបរ ធ្វើស្រែ និងដាំដំណាំបន្ទាប់បន្សំតិចតួចសំរាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ភូមិនេះត្រូវបានជ្រើសរើសជាភូមិគោលដៅរបស់អង្គការ EPDO សំរាប់អនុវត្តន៍ គម្រោងបង្កើតបណ្តុំអាជីវកម្មកង្កែប ដើម្បីផ្សាភ្ជាប់ទីផ្សារដែលទទួលជំនួយគាំទ្រពីកម្មវិធីពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE) របស់មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ ដែលមានកសិករស្ម័គ្រចិត្តចូលរួមអនុវត្តន៍ជាមួយគម្រោងចិញ្ចឹមកង្កែបចំនួន៣៩គ្រួសារ ស្ត្រី២៥នាក់។



លោកស្រី **យស់ រិហិ** អាយុ២៤ឆ្នាំ និងប្តីគាត់ឈ្មោះ **ណា ខេន** អាយុ៣០ឆ្នាំ មានកូនប្រុស២នាក់ គាត់ត្រូវបានសមាជិកជ្រើសរើស ជាកសិករគំរូនៃបណ្តុំអាជីវកម្មកង្កែប ភូមិសែនជ័យ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ពីពេលមុនគាត់មានរបរជាអ្នកចិញ្ចឹមមាន់ និងធ្វើស្រែ និងប្តីជាជាងសំណង់។ តាមប្រសាសន៍អ្នកស្រីកន្លងមកគាត់មិនដែលចិញ្ចឹមកង្កែបទេ ពេលបានទទួលដំណឹងថា អង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន EPDO បានប្រជុំជ្រើសរើសកសិករចិញ្ចឹមកង្កែប គាត់បានចូលរួមក្នុងគម្រោងបណ្តុំអាជីវកម្មកង្កែប ដែលគាំទ្រដោយកម្មវិធីASPIRE តាមរយៈអង្គការ EPDO គាត់បានទទួលនូវវគ្គបណ្តុះបណ្តាលបច្ចេកទេស ការចិញ្ចឹមកង្កែកធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុពីអង្គការ EPDO ព្រមទាំងមានការវិនិយោគពីគម្រោងរួមមាន មេបាកង្កែប៨ក្បាល កូនកង្កែប២៥០កូន ចំណីគ្រាប់ ២៥គីឡូក្រាម ឧបករណ៍តេស្តគុណភាពទឹក pH ១ឈុត ថ្នាំវិតាមិនសេ ១គីឡូក្រាម ថ្នាំព្យាបាល និងការពារជម្ងឺ ១គីឡូក្រាម អក័ម៉ូនបង្កាត់ភ្ញាស់១ឈុត តង់ចិញ្ចឹមកង្កែប២តង់ទំហំ២មx៣ម អនុវត្តន៍លើផ្ទៃដីទំហំ២០ម៉ែត្រការ៉េ។ ក្នុងអំឡុងពេលនៃការចូលរួមជាមួយគម្រោងបណ្តុំអាជីវកម្មចិញ្ចឹមកង្កែប តាមការត្រួតពិនិត្យរបស់មន្ត្រីបច្ចេកទេសវារីវប្បកម្ម EPDO បានសង្កេតឃើញថាគាត់អនុវត្តន៍ល្អក្នុងការចិញ្ចឹមកង្កែបស្របតាមបច្ចេកទេស ដូចជា ការរៀបចំទីតាំង ការរៀបចំស្រះ ការពិនិត្យទឹក ការផ្តល់ចំណី ការត្រួតពិនិត្យសុខភាពកង្កែប ការលាយថ្នាំវិតាមិនសេប្រចាំសប្តាហ៍ ជាពិសេសទៀតគាត់បានទាក់ទងមកផ្ទាល់ដល់មន្ត្រី EPDO រាល់ពេលកង្កែបមានបញ្ហា។ល។ គាត់បានបន្តថាៈ ជាការចាប់ផ្តើម គាត់មានការលំបាកខ្លះៗដោយសារគាត់មិនដែលមានបទពិសោធន៍ ក្នុងការចិញ្ចឹមកង្កែបតែក្រោយពីបានចូលរួមរៀនពីបច្ចេកទេសនឹងការចុះបង្ហឹកផ្ទាល់



របស់មន្ត្រីអង្គការEPDOគាត់បានយកចិត្តទុកដាក់ក្នុងការថែទាំ ការផ្តល់ចំណីស្របតាមការណែនាំរបស់អ្នកបច្ចេកទេសទើបគាត់ទទួលបានជោគជ័យ អាត្រារស់បានច្រើន ធំលឿនរហូតមកទល់បច្ចុប្បន្នកង្កែបរបស់គាត់មានទំងន់ប្រហែល២ខាំក្នុង១ក្បាលរយៈពេលជាង១ខែកន្លងមក ហើយគាត់ក៏បានទិញកូនកង្កែបចំនួន២០០០ក្បាលបន្ថែម ក្នុងការពង្រីកអាជីវកម្មចិញ្ចឹកកង្កែបរបស់គាត់។ បន្ទាប់ពីបានអនុវត្តន៍បច្ចេកទេសចិញ្ចឹមកង្កែបទទួលបានលទ្ធផលល្អ គាត់បាន

ធ្វើការផ្សព្វផ្សាយចំណេះដឹងដល់សមាជិកក្នុងបណ្តុំ និងក្រៅបណ្តុំ។ អ្នកស្រីបានបន្តទៀតថាៈ ខ្ញុំបានយល់ដឹងពីផលប៉ះពាល់ពីជំងឺផ្សេងៗដល់ការចិញ្ចឹមកង្កែប និងបានអនុវត្តសំអាតស្រះ បង្ហូរទឹកចេញ និងបាញ់ថ្នាំសំលាប់មេរោគក្នុងស្រះកង្កែបជាប្រចាំ និងចេះប្រើប្រាស់ថ្នាំព្យាបាលកង្កែបឈឺបានល្អប្រសើរ ដែលជាហេតុធ្វើឲ្យកង្កែបរបស់ខ្ញុំមិនងាយនឹងរងនៅជំងឺផ្សេងៗ។

តាមការរៀបរាប់របស់គាត់បានប្រាប់យើងថាៈ កង្កែបចិញ្ចឹមយកសាច់២៥០ក្បាល គាត់ទុកហូបចំនួន១០គ.ក្រ ហើយគាត់បានលក់ចំនួន ៤០គ.ក្រ បានទឹកប្រាក់ ៤៨០.០០០រៀល។ មេបាដែលបានផ្តល់ជូនគាត់ចំនួន៤គូរនោះគាត់ផលិតបានកូនកង្កែបចំនួន១០០០កូន គាត់ទុកសម្រាប់ចិញ្ចឹមខ្លួនឯង ប្រសិនជាលក់កូនចេញចំនួន១០០០កូន អាចបានទឹកប្រាក់ ៤៥០.០០០រៀលដោយលក់មួយកូន ៤៥០រៀល។

សូមបញ្ជាក់ផងដែរថា គ្រួសារលោកស្រីជាគ្រួសារស្រុកស្រែម្នាក់ដែលមានភាពតស៊ូ ឧស្សាហ៍ ព្យាយាម ចាប់ដៃគ្នាមកជាមួយប្តីគាត់ឥឡូវគាត់បានសម្រេចបញ្ឈប់ឲ្យប្តីគាត់ទៅរកស៊ីចំណាកស្រុកទៀតហើយដោយសារគាត់បានរៀបចំស្រះចិញ្ចឹមត្រីប្រាបានពីរម៉ឺនក្បាល ត្រីអណ្តែងបានបីម៉ឺនក្បាល រៀបចំអាងផ្សាំកូនត្រីលក់ចំនួនប្រាំអាង អាងមេបាបង្កងចំនួនមួយអាង អាងផ្សាំកូនបង្កងចំនួនមួយអាង អាងមេបាកង្កែបចំនួនពីរអាង អាងបង្កាត់ភ្ញាស់កង្កែបចំនួនពីរអាង អាងចិញ្ចឹមកង្កែបសាច់ចំនួនបីអាង ដែលអាងនិមួយៗមានទំហំ ៣x៤ម។



**លោកស្រី យស់ ភិហិ** និងប្តីរបស់គាត់មានអារម្មណ៍ថា ការចិញ្ចឹមកង្កែបប្រើធនធានតិច រយៈពេលខ្លីក្នុងការចិញ្ចឹម ឆាប់បានលក់ ចំនែកទីផ្សារមានការងាយស្រួលលក់ចេញដោយភ្ញៀវមកទិញដល់ផ្ទះ និងបានតម្លៃថ្លៃរហូតដល់៨០០០រៀលក្នុងមួយគីឡូក្រាម ឯចំនែកទីផ្សារកូនកង្កែបវិញក៏មានតំរូវការទីផ្សារច្រើនដែរ ដែលអាចលក់បានពី៣០០រៀលដល់៥០០រៀលក្នុង១ក្បាល គាត់មានភាពសប្បាយរីករាយដែលបានចូលរួមជាមួយគម្រោងរបស់អង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន ដែលបានគាំទ្រថវិកាដោយកម្មវិធី ASPIRE ដោយបានអនុវត្តបានជោគជ័យតាមបច្ចេកទេសរបស់អង្គការ EPDO បានផ្តល់ឲ្យ ហើយគាត់ប្តេជ្ញាចិត្តបន្តការសិក្សាស្រាយជ្រាវជំនាញបច្ចេកទេសបន្ថែមទៀត និងអនុវត្តន៍បច្ចេកទេសដោយមានទំនុកចិត្តខ្លាំង ហើយក៏គ្រោងពង្រីកដាក់មេ និងបាពូជបន្ថែមទៀតផងដែរ និងធ្វើការផ្សព្វផ្សាយដល់សមាជិកបណ្តុំ និងក្រៅបណ្តុំឲ្យមានការចិញ្ចឹមដូចរូបខ្ញុំដែរ ។ បន្ថែមពីនោះគាត់សូមអរគុណសម្រាប់គម្រោងរបស់ អង្គការ អភិវឌ្ឍន៍ និងការពារបរិស្ថាន ដែលបានគាំទ្រថវិកាដោយកម្មវិធី ASPIRE ដែលបានផ្តល់បច្ចេកទេស ចែករំលែកចំណេះដឹង និងបទពិសោធន៍លើការចិញ្ចឹមចិញ្ចឹមកង្កែបដល់រូបគាត់ និងសមាជិកក្នុងបណ្តុំអាជីវកម្មចិញ្ចឹមកង្កែប។

# ករណីសិក្សាទី៤

## ចំណាប់អារម្មណ៍របស់បណ្តុំអាជីវកម្មបន្លែ ចំពោះការធ្វើកសិកម្មតាមកិច្ចសន្យា

ការដាំដុះបន្លែ ជាការងារមួយដែលប្រជាកសិករមួយចំនួនបានអនុតវត្តន៍ជាមុខរបរប្រចាំថ្ងៃ។ ក្នុងនោះផងដែរ ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកមោងឬស្សី និងរុក្ខគិរី ខេត្តបាត់ដំបង មួយចំនួនក៏បាន ប្រកបរបរដាំដុះបន្លែនេះផងដែរ។ ក៏ប៉ុន្តែរបរដាំដុះបន្លែហាក់ជួបនូវហានីភ័យច្រើនដូចជា: សមត្ថភាពក្នុងការដាំដុះតាមបច្ចេកទេសដែលសមស្រប ការប្រើប្រាស់ថ្នាំ ជីកសិកម្ម តាមការនឹកឃើញ ដាំតាមទម្លាប់តៗគ្នាពីបុរាណ ក្រៅពីនោះមានស្ថាប័នមួយចំនួនបានមកបណ្តុះបណ្តាលដែរ តែដោយសារតែចំណេះដឹង ឬបច្ចេកទេសថ្មី ទើបមិនសូវជាមានការចាប់អារម្មណ៍ ឬអនុវត្តន៍តាម ក្រៅពីនោះគឺបញ្ហាតម្លៃបន្លែតែម្តង ដែលតែងតែមានការប្រែប្រួលមិនទៀងទាត់ ទៅតាមការកំណត់របស់ឈ្មួញ និងជួនកាលអ្នកដាំខាតបង់យ៉ាងច្រើន រហូតដល់មានប្រជាកសិករមួយចំនួនបានបោះបង់ចោលរបរនេះ និងខ្លះចំណាកស្រុកទៅធ្វើការនៅតំបន់ផ្សេង ឬនៅប្រទេសថៃផងក៏មាន។




ស្របពេលជាមួយគ្នានេះ ក្នុងខែសីហា ឆ្នាំ២០១៩ ដោយការគាំទ្រពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង លើគម្រោងកម្មវិធីផ្សព្វផ្សាយពីបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) តាមរយៈអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន (EPDO) បានធ្វើការចងក្រងជាបណ្តុំអាជីវកម្មផលិតកម្មបន្លែសរុបទាំងអស់ចំនួន៧បណ្តុំ ដោយមានរៀបចំរចនាសម្ព័ន្ធយ៉ាងត្រឹមត្រូវ។ មិនត្រឹមតែប៉ុណ្ណោះ អង្គការ EPDO ក៏បានធ្វើការបណ្តុះបណ្តាល បង្ហឹកបង្ហាត់ផ្ទាល់ពីការផលិតបន្លែសុវត្ថិភាព រួមនឹងការចងក្រងជាបណ្តាញទីផ្សារទៀតផង។ បន្ទាប់ពីការសិក្សាពីផលិតភាព និងតម្រូវការទីផ្សារបន្លែឃើញថា បណ្តុំអាជីវកម្មបន្លែទាំងអស់មានលទ្ធភាពក្នុងការផលិតបន្លែចម្រុះសម្រាប់ផ្គត់ផ្គង់ទីផ្សារជាច្រើនតោនក្នុងមួយថ្ងៃៗ។ លោកស្រី **លុយ យ៉ាន** សមាជិកបណ្តុំអាជីវកម្មបន្លែ ភូមិកំរ៉ែង ឃុំបាសាក់ ស្រុករុក្ខគិរី បានមានប្រសាសន៍ថា *"ខ្ញុំពិតជាសប្បាយរីករាយដោយបានគម្រោង របស់អង្គការ EPDO ចូលមកអនុវត្តន៍ សកម្មភាពក្នុងភូមិរបស់ខ្ញុំ ជាក់ស្តែងកន្លងមក ក្រៅពីការងារដាំដុះ យើងបារម្ភណ៍ខ្លាំងពីការលក់ផងដែរ ពីព្រោះពេលខ្លះបន្លែដែលផលិតបាន មិនមានឈ្មួញពីក្រៅតំបន់មកទទួលទិញឡើយ។* ពិតណាស់ការដាំដុះបន្លែរបស់ប្រជាកសិករ ក៏ដូចជាសមាជិកបណ្តុំអាជីវកម្មបន្លែទាំងអស់ធ្វើការដាំដុះជាបន្លែធម្មតា (បន្លែដែលប្រើសារធាតុគីមីមិនត្រឹមត្រូវតាមបច្ចេកទេស) ដោយពឹងផ្អែកទាំងស្រុងលើឈ្មួញក្នុងតំបន់ ហើយតម្លៃទៀតសោតតែងតែឡើងចុះមិនទៀង និងជួនកាលមិនត្រឹមតែទទួលបានតម្លៃថោកនោះទេ តែថែមទាំងជុញបន្លែមិនមានអ្នកមកទទួលទិញផងក៏មាន។ ក្នុងឱកាសជួបពិភាក្សាជាមួយក្រុមហ៊ុនស្តែរំដេងទិញលក់បន្លែសុវត្ថិភាពលោក **វុន សុភា** ប្រធានបណ្តុំអាជីវកម្មបន្លែ ប្រឡាយ បានមានប្រសាសន៍ថា *"ខ្ញុំប្តេជ្ញាធ្វើការដាំដុះតាមការណែនាំពីមន្ត្រីជំនាញ EPDO និងធ្វើកិច្ចសន្យាទិញលក់ ពីព្រោះក្រោយពីទទួលការបណ្តុះបណ្តាលឃើញថា បន្លែសុវត្ថិ*



*ភាព មិនមានអ្វីពិបាកផលិតជាងបន្លែគីមីឡើយ គ្រាន់តែប្តូរពីការអនុវត្តន៍ការដាំដុះតាមទម្លាប់ ឬតាមការនឹកឃើញ មកអនុវត្តន៍តាមបច្ចេកទេសដែលសមស្របវិញ ហើយចំពោះតម្លៃវិញគឺល្អ មិនភ័យព្រួយរឿងទីផ្សារទៀតផង"។* ក្នុងការចុះសន្យាជាមួយក្រុមហ៊ុនស្តែរំដេង ជំហ៊ានដំបូងចំនួនបន្លែក្នុងការទិញលក់គឺមានកាចរចារជាប្រចាំ រីឯតម្លៃវិញមានដូចខាងក្រោម៖

- ត្រកួន ទិញក្នុងតម្លៃ១៥០០រ/គ.ក
- ស្ពៃក្រញ៉ាញ់ទិញក្នុង២០០០រ/គ.ក
- ស្ពៃចង្កឹះ ទិញ២០០០រ/គ.ក
- ស្ពៃតឿ ទិញ ២០០០រ/គ.ក
- ស្ពៃហាង ទិញ ២០០០រ/គ.ក
- ខ្ទឹមស្លឹក ទិញ ៤០០០រ/គ.ក

តារាងទី ១: ផលិតភាពបន្លែសុវត្ថិភាពដែលបណ្តុំនីមួយប្តេជ្ញារក្នុងការផលិត ដើម្បីផ្គត់ទីផ្សារ៖

| លរ. | ឈ្មោះបណ្តុំអាជីវកម្មបន្លែ | ចំនួនបន្លែដែលបណ្តុំអាជីវកម្មមានផែនការណ៍ផ្គត់ផ្គង់ប្រចាំថ្ងៃ (ក.គ) | | | | | |
|---|---|---|---|---|---|---|---|
| | | ត្រសក់ | ត្រប់វែង | ត្រប់ស្រួយ | សាលាដ | ស្ពៃ | សណ្តែកគួរ |
| ១ | កំរ៉ែង | ៥,000 | ៤,000 | ២,000 | 0 | 0 | ៥00 |
| ២ | អន្លង់តាម៉ុក | ៥,000 | ១,000 | ១,000 | 0 | 0 | ៥00 |
| ៣ | ព្រៃកជីក | ១0,000 | 0 | 0 | 0 | 0 | ១,000 |
| ៤ | ព្រៃកតាវេន | ៣,000 | ១,000 | ១,000 | 0 | ៥0 | 0 |
| ៥ | អន្លង់កូប | ៥00 | 0 | ២00 | 0 | 0 | ២00 |
| ៦ | វាល | ៥0 | 0 | 0 | ៥0 | ១៨0 | 0 |
| ៧ | ប្រឡាយ | 0 | 0 | 0 | ១00 | ១៧0 | 0 |
| សរុប | | ២៣,៥៥0 | ៦,000 | ៤,២00 | ១៥0 | ៤00 | ២,២00 |

ក្នុងកិច្ចប្រជុំពិភាក្សាពីការធ្វើកសិកម្មតាមកិច្ចសន្យា លោកស្រី **សាន សុភាក់** តំណាងក្រុមហ៊ុនបន្លែសុវត្ថិភាពខ្មែរ បានមានប្រសាសន៍ថា (ខ.ស.ប) *"យើងចុះកិច្ចសន្យាជាមួយគ្នាលើការទិញលក់បន្លែ មានន័យថាយើងកំពុងដើរលើផ្លូវនេះជាមួយគ្នា ដូចនេះភាពស្មោះត្រង់ជារឿងសំខាន់ ទាំងបរិមាណ គុណភាព និងសកម្មភាពផ្សេងៗទៀត ហើយរាល់បញ្ហាដែលកើតមានត្រូវឈរលើគោលការណ៍ដោះស្រាយរួម"។* ក្រោយពីការពិភាក្សា ការធ្វើកសិកម្មតាមកិច្ចសន្យារួចមក ឃើញថា សមាជិកបណ្តុំទាំងអស់ ហាក់មានការចាប់អារម្មណ៍ខ្លាំងលើការការដាំដុះបន្លែសុវត្ថិភាព ផ្គង់ផ្គង់ទីផ្សារ ដោយការដាំដុះមានការកើនឡើង ជាពិសេសបន្លែសុវត្ថិភាព ដោយសមាជិកបណ្តុំទាំងអស់មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផលិត។

តារាងទី ២: តម្លៃបន្លែដែលបានកុងត្រាជាមួយក្រុមហ៊ុនបន្លែសុវត្ថិភាពខ្មែរ៖

| តម្លៃបន្លែដែលបានឯកភាព | ប្រភេទ | ត្រសក់ | ត្រប់វែង | ត្រប់ស្រួយ | សាលាដ | ស្ពៃ | សណ្តែកគួរ |
|---|---|---|---|---|---|---|---|
| | លេខ ១ | ១,២00 | ១,៥00 | ១,៤00 | ៣,000 | ២,៥00 | ២,000 |
| | លេខ ២ | ៨00 | ១,000 | ១,000 | ២,៥00 | ២,000 | ១,៥00 |

លោក **ប៉ុង ទេស** ជាប្រធានបណ្តាញទីផ្សារ ខេត្តបាត់ដំបង បានមានប្រសាសន៍ដែរថា *"ដើម្បីធានាបាននូវបន្លែដែលសុវត្ថិភាព សមាជិកបណ្តុំទាំងអស់ដាច់ខាតត្រូវធ្វើការដាំដុះតាមការណែនាំ សម្រាប់ផ្គត់ផ្គង់ទីផ្សារដែលកំពុងមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ន និងអនាគត ពីព្រោះបើយើងនៅតែបន្តការដាំដុះតាមចិត្តដូចមុន ពិតណាស់មិនអាច*

*ប្រកួតប្រជែងបន្លែនាំចូលបានឡើយ។ ហើយកុំបារម្ភណ៍ថា ដាំបច្ចេកទេស មិនអាចគ្រប់គ្រងកត្តាចង្រៃ ឬដំណាំមិនល្អ មិនទទួលបានផលច្រើន ខ្លាចតែយើងអ្នកដាំខមិនអនុវត្តតាមបច្ចេកទេសបាននោះទេទើបភាគច្រើនបរាជ័យ។* ក្រោយពីការអនុវត្តន៍សកម្មភាពរបស់អង្គការ EPDO ឃើញថា បណ្តុំអាជីវកម្មបន្លែទាំងអស់បានធ្វើការបង្កើនការដាំដុះ មានការពង្រីកផ្ទៃដៃដាំបន្ថែម និងការមានការសហការបានល្អប្រសើរទៀតផង។





# ករណីសិក្សាទី៥÷

## ការអនុវត្តបច្ចេកទេសចិញ្ចឹមមាន់គំរូរបស់លោក សឿង ឡាត់

ភូមិវត្តចាស់ជាភូមិមួយដែលស្ថិតនៅក្នុងឃុំតាលាស់ ស្រុកមោងរស្សី ខេត្តបាត់ដំបង ភូមិនេះមានប្រជាជនប្រមាណជា៣០០គ្រួសារដែលជាកសិករ ធ្វើស្រែ ដាំបន្លែ និងចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារទុកសំរាប់បរិភោគ និងត្រៀមទុកសំរាប់រដូវបុណ្យទានម្តងម្កាល។ ក្នុងឆ្នាំ២០១៩ភូមិវត្តចាស់ត្រូវបានជ្រើសរើសជាភូមិគោលដៅរបស់អង្គការ EPDO សំរាប់អនុវត្តន៍ គម្រោងផលិតកម្មមាន់ផ្សារភ្ជាប់នឹងទីផ្សារ ផ្តល់មូលនិធិដោយ កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE) របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង។ កាលពីខែតុលា ឆ្នាំ២០១៩ មានកសិករចំនួន៦៣គ្រួសារ បានចូលរួមជាសមាជិកចិញ្ចឹមមាន់ ក្នុងនោះមានស្ត្រី៣២គ្រួសារ។ អ្នកស្រី ចាប ផានិត អាយុ ៤៥ ឆ្នាំ មានប្តីឈ្មោះសឿង ឡាត់





អាយុ៤៨ឆ្នាំ ក្នុងបន្ទុកគ្រួសារមានកូនប្រុសចំនួន៤គ្រួសារ ប្រពន្ធលោកពូមានមុខរបបជាគ្រូបង្រៀន ថ្នាក់បឋមសិក្សា លោក សឿង ឡាត់ ជាអ្នកទទួលបន្ទុកធ្វើស្រែចំការ និងនៅផ្ទះចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារបន្ទាប់បន្សំ គាត់មានមាន់មេ១០ក្បាល និងឈ្មោល២ក្បាលប៉ុណ្ណោះ រហូតដល់ដើមឆ្នាំ២០១៧ គាត់ក៏បានចូលរៀនវគ្គបណ្តុះបណ្តាលខ្លីមួយពីការចិញ្ចឹមមាន់ ក្នុងរយៈពេល២ឆ្នាំគាត់បានបង្កើមាន់ពូជបាន២៤ក្បាល ក្នុងនោះមាន់ឈ្មោល៤ក្បាលគាត់បានដាក់ឲ្យមេក្រាបពងតាមធម្មជាតិ គ្រួសារលោក សឿង ឡាត់ ក៏ជាសមាជិកមួយក្នុងចំណោមគ្រួសារកសិករ៦៣គ្រួសារ ដែលត្រូវបានជ្រើសរើសចូលជាសមាជិកក្នុងក្រុមចិញ្ចឹមមាន់ នៅក្នុងគម្រោងផលិតកម្មមាន់ ផ្សារភ្ជាប់នឹងទីផ្សារ បន្ទាប់ពីបានរៀបចំក្រុម និងបង្កើតគោលការលក្ខន្តិកៈសមាជិកក្រុមក្នុងភូមិវត្តចាស់ក៏បានសំរេចបោះឆ្នោតជ្រើសរើស លោក សឿង ឡាត់ ជាកសិករគំរូ ជាលក្ខណៈកសិដ្ឋានខ្នាតតូចក្នុងក្រុមចិញ្ចឹមមាន់ ដែលទទួលបានការគាំទ្រពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ)ASPIRE) តាមរយៈអង្គការអភិវឌ្ឍន៍ និងការពាបរិស្ថាន(EPDO)។ លោកសឿង ឡាត់ មានប្រសាសន៍ថាដំបូងឡើយគាត់គ្រាន់តែរៀនដើម្បីចង់ដឹងពីបច្ចេកទេសខ្លះៗ ដើម្បីយកទៅអនុវត្តន៍ក្នុងការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសាររបស់គាត់ គាត់ក៏មិនបានគិតថានឹងចិញ្ចឹមច្រើនដែរព្រោះគាត់គ្មានដើមទុនច្រើនទេ ម្យ៉ាងវិញទៀតគាត់ពុំបានយល់ដឹងពីកម្មវិធីចិញ្ចឹម និងវិធីធ្វើវ៉ាក់សាំងឲ្យបានត្រឹមត្រូវនៅ



ឡើយ គឺចិញ្ចឹមទៅតាមទំលាប់ពីបូរាណ បាចស្រូវ អង្ករឲ្យមាន់ស៊ីធម្មតា និងមិនមានធ្វើវ៉ាក់សាំង និងការធ្វើទ្រុងឲ្យបានត្រឹមត្រូវទេ។

ក្រោយពីបានចូលក្នុងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធនទៅនឹងការប្រែប្រួលអាកាសធាតុ(ASPIRE) គាត់បានទទួលវគ្គបណ្តុះបណ្តាលបច្ចេកទេស ការចិញ្ចឹមមាន់ ការធ្វើទ្រុង ការថែទាំមេបា ពងមាន់ កូនមាន់ កម្មវិធីធ្វើវ៉ាក់សាំងមាន់ ការប្រើប្រាស់ថ្នាំព្យាបាល ការផ្តល់ចំណី និងវិធីការពារជីវៈសុវត្ថិភាព ការប្រើប្រាស់ទូរភ្ញាស់ពងមាន់ ទ្រីស្តី ជាការអនុវត្តផ្ទាល់ ទស្សនៈកិច្ចសិក្សាពីអង្គការEPDO និងការបង្វឹកជាប្រចាំ និងទទួលបានការឧបត្ថម្ភពីកម្មវិធី ASPIRE នូវមាន់មេពូជចំនួន១១៣ក្បាល ក្នុងនោះមាន់ឈ្មោល១៦ សម្ភារៈ និងទូរភ្ញាស់ពងមាន់១គ្រឿង ដើម្បីពង្រីកសិដ្ឋានចិញ្ចឹមមាន់ និផ្តល់កូនមាន់ជូនសមាជិកក្រុម។ បន្ទាប់ពីមានការគាំទ្រពីកម្មវិធី ធ្វើឲ្យគាត់កាន់តែចាប់អារម្មណ៍លើការចិញ្ចឹមមាន់ ដោយសារតែគម្រោងបានជួយគាំទ្រគាត់ទាំងធនធាន និងបច្ចេកទេសរួមផ្សំទាំងការតាំងចិត្តរបស់គាត់ផងដែរ។ ក្នុងសកម្មភាពដាក់ចំណីមាន់បណ្តើរ និយាយបណ្តើរ គាត់បានរៀបរាប់ថា ចាប់តាំងពីបានចូលក្នុងកម្មវិធីមកដល់ពេលបច្ចុប្បន្ននេះ គាត់មានទ្រុងសម្រាប់ចិញ្ចឹមមាន់ចំនួន៣ខ្នង រោងនិមួយៗមានទំហំ៤X៦ម មានមាន់ពូជចំនួន១៥០ក្បាល ឈ្មោល១៨ក្បាល ទូរភ្ញាស់១គ្រឿងចំណុះ៥០០គ្រាប់ មាន់សាច់ពូជម៉ុងហ្គូលចំនួន១០០ក្បាល និង



មាន់ស្រែចំនួន៤០០ក្បាល។ មាន់ពូជរបស់គាត់អាចពងបានចំនួនពី២០ទៅ៣០ពងក្នុង១ថ្ងៃ។ ចាប់តាំងពីគាត់មានទូរភ្ញាស់មកគាត់ផលិតកូនមាន់ក្នុង១ខែ បានពី៣០០ទៅ៤០០ក្បាល គាត់អាចលក់កូនមាន់បានបន្ទាប់ពីមានអាយុ២១ថ្ងៃ ដោយធ្វើវ៉ាក់សាំងរួច១ក្បាលគាត់លក់បានពី៥០០០៛ ទៅ៦០០០៛ ដូច្នេះក្នុងមួយខែគាត់អាចទទួលបានប្រាក់ពីការលក់កូនមាន់ ពី១.៧៥០.០០០៛ ទៅ ២.០០០.០០០៛។ ចំពោះមាន់សាច់គាត់ចិញ្ចឹមរយៈពេល៣ទៅ៤ខែគាត់ចាប់លក់ម្តងបានចំនួន២៥០គីឡូ ទៅ៣០០គីឡូ ក្នុងតម្លៃ១គក្រ១៨.០០០៛ ទៅ២០.០០០៛ គិតជាមធ្យមគាត់អាចទទួលបានប្រាក់ពីការលក់មាន់សាច់ប្រមាណជា១.៥០០.០០០៛។ បើគិតពីប្រាក់ចំណូលប្រចាំខែរបស់គាត់អាចរកចំណូលបានប្រហែលជាង៣.០០០.០០០៛ និងចំណាយប្រចាំខែ៧៨០.០០០៛។ មិនតែប៉ុណ្ណោះគាត់បានភ្ញាស់កូនមាន់ចែកជូនសមាជិកក្រុមរបស់គាត់បានចំនួន១៥០០ក្បាលសម្រាប់១៥នាក់។

គាត់សង្កេតឃើញថាបើប្រៀបធៀបនឹងការធ្វើស្រែគឺការចិញ្ចឹមមាន់មានជីវភាពល្អប្រសើរ គឺអាចរកចំណូលបានមួយផ្នែកធំសំរាប់គ្រួសារគាត់ ក្នុងទឹកមុខសប្បាយរីករាយគាត់និយាយថាគាត់ពិតជាអរគុណខ្លាំងណាស់ដែលគម្រោងកម្មវិធីASPIRE របស់មន្ទីរកសិកម្មខេត្តបាត់ដំបង និងអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន EPDO បានជ្រើសរើសភូមិគាត់ជាភូមិគោលដៅ និងបានជ្រើសរើសគាត់ជាកសិករគំរូម្នាក់ឲ្យគាត់បានយល់ដឹងពីការចិញ្ចឹមមាន់តាមបែបលក្ខណៈបច្ចេកទេសថ្មី ធ្វើឲ្យការចិញ្ចឹមមាន់របស់គាត់កាន់តែមានភាពរីកចំរើន ពីការចិញ្ចឹមមាន់បែបលក្ខណៈមេក្រាបពងឈានដល់ការភ្ញាស់ជាលក្ខណៈទំនើប និងក្លាយជាកសិដ្ឋានចិញ្ចឹមមាន់ខ្នាតតូច។ អ្នកមីង ចាប ផានិត ជាប្រពន្ធ លោក សឿង ឡាត់ មានប្រសាសន៍ថារាល់ថ្ងៃគឺត្រូវការចំណាយច្រើនសម្រាប់ផ្គត់ផ្គង់ ការរៀនសូត្ររបស់កូនៗនៅមហាវិទ្យាល័យនៅភ្នំពេញ។



លោក សឿង ឡាត់ និយាយបន្តទាំងទឹកមុខមឹងម៉ាត់ថា ទោះជាយ៉ាងណាក៏គាត់មិនបោះបង់ក្នុងការចិញ្ចឹមមាន់នេះទេ គាត់បានដល់ថ្ងៃនេះគឺជាការតស៊ូរបស់គាត់តាំងពីការធ្វើទ្រុងតូចមួយ រហូតដល់មានទ្រុងធំចំនួន៣ ការសន្សំពូជមាន់ល្អៗ ព្រមទាំងទទួលបាននូវចំណេះដឹង ជំនាញ រួមផ្សំជាមួយបទពិសោធន៍ដែលបានរៀន និងការអនុវត្តផ្ទាល់ ដូច្នេះគាត់មានឱកាសកាន់តែច្រើន ក្នុងការពង្រីកឲ្យកសិដ្ឋានខ្នាតតូចរបស់គាត់មួយនេះកាន់តែឈានទៅមុខបន្ថែមទៀត គាត់ក៏បានអរគុណដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងអង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន ដែលមានការគាំទ្រថវិកា និងធនធាន ជាពិសេសបានបង្រៀនគាត់ឲ្យបានចេះពីជំនាញ និងការអនុវត្តន៍ផ្ទាល់លើការចិញ្ចឹមមាន់ តាមបែបបច្ចេកទេសថ្មីធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ទាំងអស់នេះហើយដែលជំរុញទឹកចិត្តគាត់ឲ្យគាត់មានទំនុកចិត្តលើខ្លួនឯង និងខិតខំបន្តថែមទៀតលើមុខរបរចិញ្ចឹមមាន់នេះ ពីព្រោះគាត់បានដឹងថាទីផ្សារមាន់គឺធំទូលាយសំរាប់គាត់ដែលជាអ្នកចិញ្ចឹម គាត់មានក្តីសង្ឃឹម និងជឿជាក់ថាគាត់អាចទាញយកប្រាក់ចំណូលបានយ៉ាងច្រើនពីវិស័យផលិតកម្មមាន់ សំរាប់ផ្គត់ផ្គង់គ្រួសាររបស់គាត់។